# ជាតកដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយជាតក

## វគ្គទី ១ ឈ្មោះអបណ្ណកវគ្គ
## វគ្គទី ២ ឈ្មោះសីលវគ្គ

វត្តសន្តិវ័ន ស្រុកសង្កែ ខេត្តបាត់ដំបង

ព.ស.២៥៥៥

www.elibraryofcambodia.org

# ជាតកដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយជាតក

## វគ្គទី ១ ឈ្មោះអបណ្ណកវគ្គ
## វគ្គទី ២ ឈ្មោះសីលវគ្គ


ប្រែ និងរៀបរៀងដោយ :

-ភិក្ខុ មិតវិរោ ទ៊ាន់ ចិន្តា -ភិក្ខុ ណោច ណោន

-ភិក្ខុ យើយ សុខន -ភិក្ខុ ឡាយ ខៀប



វត្តសន្តិធំ ស្រុកសង្កែ ខេត្តបាត់ដំបង

ព.ស.២៥៥៥


www.elibraryofcambodia.org

# អារម្ភកថា

មនុស្សសត្វទាំងឡាយ ដែលកើតមកលើលោកនេះតែងតែប្រាថ្នាចង់បាន សេចក្តីសុខជានិច្ចគ្រប់រូបតែងមានសេចក្តីភ័យខ្លាច និងតក់ស្លុតរន្ធត់ញាប់ញ័រជាខ្លាំង នៅពេលសេចក្តីទុក្ខមកដល់ព្រះមានព្រះភាគទ្រង់ត្រាស់នូវឱវាទណែនាំឱ្យមនុស្សយើង ប្រព្រឹត្តនូវសុចរិតធម៌ ជៀសវាងអំពើបាបកម្មគ្រប់បែបយ៉ាង ហើយខំព្យាយាមសំអាតចិត្តដើម្បីស្វែងរកសេចក្តីសុខ ។

អាស្រ័យហេតុនេះហើយ បានជាខ្ញុំព្រះករុណាអាត្មាភាព ប្រែនិងរៀបរៀងព្រះអដ្ឋកថានេះឡើង ដើម្បីជាប្រទីបមួយ ជាគ្រឿងសំរាប់បំភ្លឺដល់ពុទ្ធបរិស័ទ ដែលប្រាថ្នាចង់បាននូវសេចក្តីសុខ ត្រូវសិក្សាស្វែងយល់អំពីជីវិតព្រះពោធិសត្វ ជាប្រយោជន៍តម្រង់ទិសដៅ នៃការប្រតិបត្តិឱ្យត្រឹមត្រូវទៅតាមមាគ៌ា នៃព្រះពោធិសត្វ ដែលលោកបានឆ្លងរួចមកហើយ ។

សៀវភៅនេះ ជាផ្កាលលមួយសំរាប់ជំនួយដល់ពុទ្ធបរិស័ទដែលប្រាថ្នាបន្ទុះពូជ គឺពោធិចិត្ត ឬជាគោលប្រតិបត្តិនាំមកនៅសេចក្តីសុខសន្តិភាព សុភមង្គលដល់ពុទ្ធសាសនិកជន ការសិក្សាប្រតិបត្តិទៅតាមកន្លងមាគ៌ានៃព្រះពោធិសត្វ គឺជាការកសាងនៃបារមីធម៌ ដែលព្រះសម្មា



www.elibraryofcambodia.org

សម្តុទ្ធទ្រង់បានអនុវត្តរួចមកហើយ ធ្វើឱ្យព្រះអង្គទ្រង់បានដល់នូវសម្ពោធិញ្ញាណ ។

សេចក្តីក្នុងសៀវភៅ អដ្ឋកថាជាតកនេះ ខ្ញុំព្រះករុណាអាត្មាភាពទាំងបួនព្រះអង្គបានដកស្រង់ចេញពីបិដកលេខ ៥៨ និងអដ្ឋកថាលេខ ៥៥ ដែលមានទាំងគាថាបាលីក្នុងព្រះត្រៃបិដក និងសេចក្តីពន្យល់ក្នុងអដ្ឋកថាដែលបានប្រែមកជាខេមរៈភាសា ដើម្បីជាប្រយោជន៏ដល់បុគ្គលអ្នកប្រាថ្នាយល់ដឹងក្នុងព្រះធម៌ ដែលជាសាសនធម៌ ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ខ្ញុំព្រះករុណាអាត្មាភាពទាំងបួនព្រះអង្គ និងសព្រហ្មចារីបានព្យាយាមពិនិត្យផ្ទៀងផ្ទាត់យ៉ាងល្អ តែក៏គង់នៅមានកំហុសមិនខាន ដោយសេចក្តីខ្វះសិក្សាមិនដល់ និងដោយការភ្លាំងភ្លាត់ក្នុងអក្ខរាវិរុទ្ធបក្នុងចំណុចណាមួយក្តី សូមលោកអ្នកអានជាកល្យាណធម៌ទាំងអស់ជួយកែសម្រួលឱ្យដល់ខ្ញុំព្រះករុណាអាត្មាភាពផង ដើម្បីជាប្រយោជន៏ដល់ការត្រឹមត្រូវក្នុងព្រះពុទ្ធវចនៈ និងជាប្រយោជន៏ដល់សាសនារបស់យើងទាំងអស់គ្នា ។

សូមអានុភាពនៃព្រះរតនៈត្រៃប្រតិស្ថាន ក្នុងហឫទ័យរបស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វសេចក្តីចំរើនក្នុងធម៌ដែលព្រះមានព្រះភាគទ្រង់ប្រកាសទុកល្អ ហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។



www.elibraryofcambodia.org

សៀវភៅនេះជា អដ្ឋកថាជាតក

អបណ្ណកវគ្គ ទី១ និង

សីលវគ្គ ទី ២

<u>ប្រែនិងរៀបរៀងដោយៈ</u>

ភិក្ខុ ម៉ាន់ ចិន្តា

ភិក្ខុ សា រ័ត្ន

ភិក្ខុ យើយ សុខន

ភិក្ខុ ឡាយ ខៀប



www.elibraryofcambodia.org

# ឧទ្ទិសកថា

កិច្ចនៃបុណ្យធម្មទាននេះ ខ្ញុំព្រះករុណាសូមឧទ្ទិសចំពោះ បុព្វការីជនទាំងឡាយ មាន មាតា បិតា ជីដូន ជីតា និងគ្រូឧបជ្ឈាយាចារ្យព្រមទាំងញាតិការក្នុងសង្សារវដ្ដ និង ពុទ្ធបរិស័ទទាំងអស់ មានលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស**, លោកគ្រូបណ្ឌិតធម្មាចារ្យ **រស់ សុផាត**, លោកគ្រូធម្មាចារ្យ **គាំ អ៊ីច**, ព្រមទាំងលោកអ្នកអានជា កល្យាណដែលបានសិក្សា នូវគន្ថធុរៈ និងវិបស្សនាធុរៈ ធម៌ទាំងអស់ទូទាំងសកលលោកទាំងមូល និង សូមឧទ្ទិសដល់ពពួកសព្វសត្វទាំងអស់ សូមបាននូវចំណែកបុណ្យធម្មទាននេះរបស់ខ្ញុំព្រះករុណា និងសព្រហ្មចារីដែលចូលរួមក្នុងការងារធម្មទាននេះទាំងអស់ សូមអនុមោទនា !!!

កាលបានអនុមោទនាហើយ សូមឱ្យបានជាបច្ច័យរួចចាកអំពីសេចក្ដីទុក្ខទាំងអស់គ្នា និងដល់នូវបរមសុខ គឺព្រះនិព្វានកុំបីឃ្លៀងឃ្លាតជាបការដទៃឡើយ ។

**សូមអនុមោទនាបុណ្យ!!!**



www.elibraryofcambodia.org

# សារបណ្ណ

## ព្រះសុត្តន្តបិដក ខុទ្ទកនិកាយជាតក

### ខុទ្ទកនិកាយជាតក អបណ្ណកវគ្គ វគ្គទី ១ មាន ១០ រឿង


| ល.រ | | ទំព័រ |
|---|---|---|
| 1 | អារម្ភកថា | ក |
| 2 | ឧទ្ទិសកថា | ឃ |
| 3 | ព្រះពុទ្ធសាសនាមានអង្គ ៩ | ១ |
| 1 | អបណ្ណកជាតកទី ១ | ៧ |
| | អដ្ឋកថា អបណ្ណកជាតក | ៨ |
| 2 | វណ្ណុបថជាតកទី ២ | ៤២ |
| | អដ្ឋកថា វណ្ណុបថជាតក | ៤៣ |
| 3 | អដ្ឋកថា សេរិវវាណិជជាតក | ៥៨ |
| | សេរិវវាណិជជាតកទី ៣ | ៦៨ |
| 4 | ចុល្លកសេដ្ឋីជាតកទី ៤ | ៦៨ |
| | អដ្ឋកថា ចុល្លកសេដ្ឋីជាតក | ៦៨ |
| 5 | តណ្ឌុលនាឡិជាតកទី ៥ | ៩៥ |
| | អដ្ឋកថា តណ្ឌុលនាឡិជាតក | ៩៦ |




www.elibraryofcambodia.org

6 ទេវធម្មជាតកទី ៦........................................................................១០៤

អដ្ឋកថា ទេវធម្មជាតក........................................................................១០៥

7 កដ្ឋហារិជាតកទី ៧........................................................................១២៧

អដ្ឋកថា កដ្ឋហារិជាត........................................................................១២៨

8 គាមណិជាតកទី ៨........................................................................១៣៦

អដ្ឋកថា គាមណិជាតក........................................................................១៣៦

9 មឃទេវជាតកទី ៩........................................................................១៤០

អដ្ឋកថា មឃទេវជាតក........................................................................១៤០

10 សុខវិហារិជាតកទី ១០........................................................................១៤៨

អដ្ឋកថា សុខវិហារិជាតក........................................................................១៤៩

ខុទ្ទកនិកាយជាតក សីលវគ្គទី ២ មាន ១០ រឿង..........១៥៦

1 លក្ខណជាតកទី ១........................................................................១៥៦

អដ្ឋកថា លក្ខណជាតក........................................................................១៥៦

2 និគ្រោធមិគជាតកទី ២........................................................................១៦៥

អដ្ឋកថា និគ្រោធមិគជាតក........................................................................១៦៦

3 កណ្ឌិនជាតកទី ៣........................................................................១៨៩

អដ្ឋកថា កណ្ឌិនជាតក........................................................................១៩០




www.elibraryofcambodia.org

4 វាតមិគជាតកទី ៤ ........ ១៩៦

អដ្ឋកថា វាតមិគជាតក ........ ១៩៧

5 ខរាទិយជាតកទី ៥ ........ ២០៦

អដ្ឋកថា ខរាទិយជាតក ........ ២០៦

6 តិបល្លត្ថជាតកទី ៦ ........ ២១០

អដ្ឋកថា តិបល្លត្ថជាតក ........ ២១១

7 មាលុតជាតកទី ៧ ........ ២២៣

អដ្ឋកថា មាលុតជាតក ........ ២២៤

8 មតកភត្តជាតកទី ៨ ........ ២២៧

អដ្ឋកថា មតកភត្តជាតក ........ ២២៨

9 អាយាចិតភត្តជាតកទី ៩ ........ ២៣៥

អដ្ឋកថា អាយាចិតភត្តជាតក ........ ២៣៦

10 នឡបានជាតកទី ១០ ........ ២៣៩

អដ្ឋកថា នឡបានជាតក ........ ២៤០

11 ឧទាននៃសីលវគ្គ ........ ២៤៧

(បិដកលេខ ៥៨,ទំព័រ ទី ១-១៤)



www.elibraryofcambodia.org

# ព្រះពុទ្ធសាសនាមានអង្គ ៩

☆☆☆

ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក រួមជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ មានអង្គ ៩ ប្រការគឺ :

**សុត្តៈ** បានដល់ ឧភតោវិភង្គ និទ្ទេស ខន្ធកៈ បរិវារ ព្រះសូត្រទាំងឡាយផ្សេងៗ មានមង្គលសូត្រជាដើម ។

**គេយ្យៈ** គឺព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

**វេយ្យាករណៈ** គឺព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថាលាយ និងព្រះពុទ្ធវចនៈដែលមិនទាក់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈ ។

**គាថា** គឺព្រះធម្មបទ ថេរគាថា ថេរីគាថា សុទ្ធៗ ដែលមិនឈ្មោះថា សូត្រ ក្នុងសុត្តនិបាត ។

**ឧទាន** គឺព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់បន្លឺដោយសោមនស្សញ្ញាណ ។



www.elibraryofcambodia.org

**ឥតិវុត្តកៈ** គឺព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមដោយពាក្យថា សេចក្ដីនេះសមពិតដូចដែលព្រះពុទ្ធជាម្ចាស់ត្រាស់ទុកហើយ ។

**ជាតក** គឺជាការសម្ដែងក្នុងរឿង អតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម រួមជា ៥៥០ ជាតក ។

**អព្ភូតធម៌** គឺព្រះសូត្រដែលប្រកបដោយអច្ឆរិយ អព្ភូតធម៌ដ៏ក្រៃលែងដោយគុណវិសេស ។

**វេទល្លៈ** គឺព្រះសូត្រដែលសួរ ហើយបានការត្រាស់ដឹង និងសេចក្ដីត្រេកអរក្រៃលែងឡើង មានចូឡវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ និងសក្កបញ្ហាសូត្រជាដើម ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺជាសច្ចធម៌ ដែលទ្រង់ត្រាស់សម្ដែងថា ៖

**ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាមឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែលបណ្ឌិតគប្បីដឹងបាន ។**



www.elibraryofcambodia.org

ព្រោះសភាវៈនៃធម៌ មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឱ្យជាក់ច្បាស់ ឱ្យកើតឡើងការយល់ចូលចិត្តទាំងអត្ថ និងអនុព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនៅធម៌ទាំងឡាយ តាមសេចក្តីពិតក្នុងរឿងនោះៗ ។

ស្របតាមអធ្យាស្រ័យផ្សេងៗ គ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេងៗ ដែលទ្រង់ឧបមាទុក ដូចជា ផ្កាឈូកបួនពួក ព្រះពុទ្ធជាម្ចាស់ ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ ដោយការបង្រៀនព្រះធម៌របស់ព្រះពុទ្ធជាម្ចាស់មាន ៣ ប្រការ គឺ :

**១- ទ្រង់បង្រៀនឱ្យយល់ដឹងដ៏ក្រៃលែង** ឃើញពិតក្នុងវត្ថុដែលគួរដឹងគួរឃើញ។

**២- ទ្រង់សម្តែងធម៌មានហេតុនិងផល** ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

**៣- ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ** ពីអ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍តាមសមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

www.elibraryofcambodia.org

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្ដែងព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលឧបនិស្ស័យរបស់បុគ្គលនោះដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្ដាប់នូវពុទ្ធោវាទតែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្ដែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌វិន័យទុកថាជាសាស្ដាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្ដីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឱ្យមានការបដិបត្តិផ្សេងៗ គ្នា មានសីល និងទិដ្ឋិផ្សេងៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យជ្រាបពុទ្ធាធិប្បាយ ទាំងដោយអត្ថ និងព្យញ្ជនៈ និងព្រះពុទ្ធវចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកដោយលំដាប់ មានឆន្ទៈ និងឧស្សាហ៍ដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្ដីដែលលំបាកយល់ ឱ្យកើតការ



www.elibraryofcambodia.org

ងាយយល់សម្រាប់អ្នកសិក្សា និងបតិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនាខាងក្រោយ តក្ការហូតមក មាន :

**១- ព្រះសូត្រ** គឺព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយបិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

**២- សុត្តានុលោម** គឺគម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយសេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

**៣- អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេងៗ តាំងអំពីថ្នាក់ដីកា អនុដីកា និងបុព្វាចារ្យជំនាន់ក្រោយៗ ។

**៤- អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធសាសនា ។ ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺកាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯងដោយច្រើន ទាំងនេះ អាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺព្រះត្រៃបិដក និងអដ្ឋកថា មិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈ ក្នុងភាសាបាលីតិចតួច



www.elibraryofcambodia.org

សំនួនភាសាបាលីដែលបច្ចេញមកហើយ លំបាកយល់ ចំពោះអ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។

អធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹង របស់ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុសនោះឯង ។ ព្រះត្រៃបិដកប្រៀបដូចរដ្ឋធម្មនុញ្ញ ច្បាប់ទូទៅជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញ មិនបានយ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ក៏មិនបានដូចគ្នាដូច្នេះ ។

**សូមអនុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យរបស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វសេក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគ ទ្រង់ប្រកាសទុកល្អហើយ បរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។**



www.elibraryofcambodia.org

# ព្រះសុត្តន្តបិដក ខុទ្ទកនិកាយជាតក

## អបណ្ណកវគ្គទី ១

### អបណ្ណកជាតកទី ១

**អបណ្ណកំ ឋានមេកេ ទុតិយំ អាហុ តក្កិកា**
**ឯតទញ្ញាយ មេធាវី តំ គណ្ហេ យទបណ្ណកន្តិ ។**

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) បុគ្គលពួកខ្លះជាបណ្ឌិត រមែងប្រកាន់ហេតុដែលមិនខុស បុគ្គលពួកខ្លះត្រិះរិះយកឯង រមែងប្រកាន់យកហេតុទី ២ ( ហេតុខុស ) មេធាវីបុគ្គល បានដឹងនូវហេតុដែលខុស និងហេតុដែលមិនខុសនេះហើយ គប្បីកាន់យកនូវហេតុដែលមិនខុសនោះ ។



www.elibraryofcambodia.org

# អដ្ឋកថា អបណ្ណកវគ្គទី ១

## អដ្ឋកថា អបណ្ណកជាតក

ព្រះមានព្រះភាគជាម្ចាស់ កាលស្ដេចអាស្រ័យនៅនគរសាវត្ថី ទ្រង់ប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់បានត្រាស់ **អបណ្ណក** ធម្មទេសនានេះទុក ។ សួរថា រឿងនេះកើតឡើងព្រោះប្រារព្ធនឹងនរណា ? ឆ្លើយថា ព្រោះប្រារព្ធនឹងសាវ័ករបស់តិរ្ថិយ ជាសម្លាញ់របស់អនាថបិណ្ឌិកសេដ្ឋី ។

សេចក្ដីពិស្ដារថា ថ្ងៃមួយលោកអនាថបិណ្ឌិកសេដ្ឋីបបួលពួកសាវ័កតិរ្ថិយ ៥០០ នាក់ ជាសម្លាញ់របស់ខ្លួន ឱ្យកាន់កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាបជាច្រើន និងទឹកដោះគោ ទឹកឃ្មុំ ទឹកអំពៅ និងគ្រឿងសំពត់សម្រាប់បិទបាំងទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះមានព្រះភាគជាម្ចាស់ បូជាដោយគ្រឿងក្រអូប កម្រងផ្កា ភេសជ្ជៈ និងសំពត់ ថ្វាយដល់ភិក្ខុសង្ឃហើយ អង្គុយក្នុងទីដ៏សមគួរ ដោយវៀរចាកទោសរបស់ការអង្គុយ ៦ ប្រការ ។

សាវ័ករបស់តិរ្ថិយសូម្បីទាំងនោះ ថ្វាយបង្គំព្រះតថាគត



www.elibraryofcambodia.org

ហើយ សម្លឹងមើលព្រះភក្ត្ររបស់ព្រះសាស្ដាល្អហ្មត់ហ្មង ដូចព្រះចន្ទក្នុងថ្ងៃពេញបូណ៌មី សម្លឹងមើលព្រះកាយ ដូចកាយព្រហ្មដែលប្រដាប់ដោយលក្ខណៈ និងអនុព្យញ្ជនៈ វិលជុំវិញដោយព្រះរស្មីមើលព្រះពុទ្ធរង្សីដែលបញ្ចេញមកជាវង់ៗ ( ដូចផ្កាឧប្បល ) ជាគូៗ ទើបអង្គុយក្នុងទីសមគួរ ។ លំដាប់នោះ ព្រះសាស្ដាបានត្រាស់ធម្មកថាដ៏ពីរោះពិស្ដារ វិចិត្រដោយន័យផ្សេងៗ ដោយព្រះសូរសៀងប្រៀបដូចសំឡេងព្រហ្ម គួរជាទីសណ្ដាប់ ប្រកបដោយអង្គប្រាំបីប្រការដល់សាវ័ករបស់តិត្ថិយទាំងនោះ ប្រដូចសំឡេងរាជសីហ៍ដែលបន្លឺសីហនាទលើផ្ទាំងថ្ម ដូចមេឃរដូវភ្លៀងដែលលាន់ឮខ្ទរខ្ទារ ធ្វើគង្គាលើអាកាសឱ្យធ្លាក់ចុះមក ដូចកម្រងផ្កាកែវមណី ។ សាវ័ករបស់តិត្ថិយទាំងនោះ ស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដាហើយ មានចិត្តជ្រះថ្លា ក្រោកឡើងថ្វាយបង្គំព្រះទសពល ទម្លាយសរណៈរបស់តិត្ថិយ ហើយបានដល់ព្រះពុទ្ធជាម្ចាស់ជាសរណៈ ។ ចាប់តាំងពីពេលនោះមក ពួកតិត្ថិយទាំងនោះ មានដៃកាន់គ្រឿងក្រអូប និងផ្កាឈើជាដើម ទៅកាន់ព្រះវិហារ ស្ដាប់ធម៌ ឱ្យទាន រក្សាសីល



www.elibraryofcambodia.org

និងរក្សាឧបោសថកម្ម ព្រមជាមួយនឹង អនាថបិណ្ឌិកសេដ្ឋីជានិច្ចកាល ។ លំដាប់នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ស្តេចបានយាងចាកចេញក្រុងសាវត្ថី ត្រឡប់ទៅកាន់ក្រុងរាជគ្រឹះ ។ ក្នុងវេលាដែលព្រះតថាគតស្តេចយាងទៅហើយ ពួកសាវ័កតិរ្ថិយទាំងនោះក៏បានទម្លាយសរណៈនោះចេញ ត្រឡប់ទៅជាតិរ្ថិយកាន់យកសរណៈនោះវិញទៀត នៅក្នុងឋានជាភាពដើមរបស់ខ្លួននោះឯង ចំណែកព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បានគង់នៅ ៧-៨ ខែ ទើបបានស្តេចត្រឡប់ទៅកាន់វត្តជេតពនម្តងទៀត ។ អនាថ-បិណ្ឌិកសេដ្ឋី ក៏នាំសាវតិរ្ថិយទាំងនោះទៅគាល់ព្រះសាស្តាម្តងទៀត ហើយបូជាព្រះសាស្តា ដោយគ្រឿងក្រអូប និងផ្កាឈើជាដើម រួចថ្វាយបង្គំ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លំដាប់នោះ អនាថ-បិណ្ឌិកសេដ្ឋីក្រាបទូលព្រះដ៏មានព្រះភាគជាម្ចាស់ ដល់សេចក្តីដែលពួកសាវ័កតិរ្ថិយទាំងនោះ កាលព្រះតថាគតចារិកទៅហើយ បានមកទម្លាយសរណៈដែលទទួលទុក ត្រឡប់ទៅកាន់តិរ្ថិយជាសរណៈក្នុងឋានដូចដើមទៀត ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់បើក



www.elibraryofcambodia.org

មណ្ឌលព្រះឱស្ឋ ប្រដូចបើកប្រអប់កែវដែលពេញដោយរបស់ក្រអូប ផ្សេងៗ ដែលមានក្លិនក្រអូបដោយគ្រឿងក្រអូបដ៏ជាទិព្វ ព្រោះ អនុភាពរបស់វចីសុចរិត ដែលទ្រង់បំពេញឱ្យប្រព្រឹត្តទៅមិនដែល ដាច់អស់សែនកប្បរាប់ប្រមាណមិនបាន កាលនឹងទ្រង់បញ្ចេញ ព្រះសូរសៀងដ៏ពីរោះ ត្រាស់សួរថា បានឮថា ពួកអ្នកជាឧបាសក ទម្លាយសរណៈទាំងបីចេញ ហើយដល់តិរ្ថិយជាសរណៈពិតឬ ? លំដាប់នោះ កាលពួកសាវ័កតិរ្ថិយទាំងនោះមិនអាចលាក់បាំងទុក បានក៏នាំគ្នាក្រាបទូលថា ពិតមែនហើយព្រះអង្គ ។ ទើបព្រះសាស្តា ត្រាស់ថាម្នាល ឧបាសកទាំងឡាយក្នុងលោកធាតុ ខាងក្រោមរហូត ដល់អវិចីមហានរក ខាងលើរហូតដល់ភវគ្គព្រហ្ម នឹងរកប្រមាណ មិនបាន ឈ្មោះថា បុគ្គលដូចព្រះពុទ្ធជាម្ចាស់ដោយព្រះគុណទាំង ឡាយ មានសីលជាដើម រមែងមិនមានបុគ្គលដែលក្រៃលែងជាង ព្រះពុទ្ធនឹងមានមកពីណា ហើយទ្រង់ប្រកាសគុណរបស់ព្រះរតន-ត្រ័យ ដែលទ្រង់ប្រកាសទុកក្នុងព្រះសូត្រទាំងឡាយមានយ៉ាងនេះ ថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ មានប្រមាណត្រឹមណា



www.elibraryofcambodia.org

មិនមានជើងក៏ដោយ មានជើងពីរក៏ដោយ មានជើងបួនក៏ដោយ មានជើងច្រើនក៏ដោយ ។ល។ ព្រះតថាគតយើងពោលថា ជាអ្នកលើសសត្វទាំងឡាយមានប្រមាណត្រឹមនោះ ។ ( និងព្រះសូត្រថា ) ទ្រព្យជាគ្រឿងគាប់ចិត្តយ៉ាងណាមួយក្នុងលោកនេះ ឬលោកដទៃ ។ល។ រតនៈនោះស្មើដោយព្រះតថាគតមិនមានឡើយ ( និងព្រះសូត្រថា ) កាលបុគ្គលស្គាល់ធម៌ដ៏លើស ហើយជ្រះថ្លាដោយភាពជារបស់ប្រសើរ ជ្រះថ្លាហើយក្នុងព្រះពុទ្ធជាម្ចាស់អ្នកដ៏លើស ។ល។ ហើយទើបត្រាស់ថា បុគ្គលជាឧបាសក និងឧបាសិកា អ្នកដល់ព្រះរតនត្រ័យដ៏ឧត្តម គុណយ៉ាងនេះឈ្មោះថា នឹងជាអ្នកកើតក្នុងនរកជាដើមរមែងមិនមាន ។ម្យ៉ាងទៀត នឹងផុតចាកការកើតក្នុងអបាយ ហើយនឹងកើតឡើងក្នុងទេវលោក បានសោយមហាសម្បត្តិ ព្រោះហេតុណា ទើបពួកអ្នកនាំគ្នាទម្លាយសរណៈយ៉ាងនេះ ហើយដល់តិរ្ថិយជាសរណៈ នឹងធ្វើកម្មមិនសមគួរឡើយ ។

ក៏ក្នុងទីនោះ ដើម្បីនឹងសម្តែងដល់ភាពដែលបុគ្គលអ្នកដល់ព្រះរតនត្រ័យជាសរណៈដោយអំណោចការរួចផុត និងដោយអំណោច



www.elibraryofcambodia.org

ជារតនៈដ៏ខ្ពង់ខ្ពស់ នឹងមិនមានការកើតក្នុងអបាយភូមិទាំងឡាយ បណ្ឌិតគប្បីសម្តែងព្រះសូត្រយ៉ាងនេះថា :

ជនពួកណាមួយ បានដល់ព្រះពុទ្ធជាម្ចាស់ជាសរណៈ ជនពួកនោះនឹងមិនចូលដល់អបាយភូមិ លះរាងកាយរបស់មនុស្សនេះទៅហើយ នឹងទៅកាន់កាយទេវតាដោយបរិបូណ៌ ។

ជនពួកណាមួយបានដល់ព្រះធម៌ជាសរណៈ ជនទាំងនោះនឹងមិន ទៅកាន់អបាយភូមិលះរាងកាយរបស់មនុស្សនេះ ហើយនឹងញុំាងកាយទេវតាដោយបរិបូណ៌ ។

ជនពួកណាមួយ បានដល់ព្រះសង្ឃជាសរណៈ ជនទាំងនោះនឹងមិនទៅកាន់អបាយភូមិ លុះលះរាងកាយរបស់មនុស្សនោះទៅហើយ នឹងបានជាកាយទេវតាដោយបរិបូណ៌ ។

មនុស្សទាំងឡាយជាច្រើន ត្រូវភ័យគំរាមហើយ រមែងដល់ភ្នំខ្លះ ព្រៃខ្លះ អារាម និងដើមឈើថាជាចេតិយខ្លះ យកជាសរណៈ នោះឯងមិនមែនសរណៈដ៏ក្សេម មិនមែនសរណៈដ៏ឧត្តម គេអាស្រ័យវត្ថុនោះជាសរណៈហើយ រមែងមិនផុតចាកទុក្ខទាំង



www.elibraryofcambodia.org

ពួងឡើយ ។

ចំណែកបុគ្គលណា ដល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាសរណៈ ហើយឃើញអរិយសច្ចទាំងបួនដោយបញ្ញាដ៏ប្រពៃ គឺទុក្ខ និងតណ្ហាដែលជាដែនកើតឡើងនៃទុក្ខ ( គឺសមុទយៈ ) និងការឈានកន្លងទុក្ខ ( គឺនិរោធ ) និងមគ្គមានអង្គ ៨ ដែលផុតចាកសត្រូវ ឱ្យដល់ព្រះនិព្វាន ជាកន្លែងចូលរម្ងាប់ទុក្ខ នេះឯងជាសរណៈដ៏ក្សេម នេះជាសរណៈដ៏ឧត្តម គេអាស្រ័យវត្ថុនេះហើយ រមែងផុតចាកទុក្ខទាំងពួងបាន ដូច្នេះ ។ ព្រះសាស្តាទ្រង់សម្តែងព្រះធម៌មានប្រមាណប៉ុណ្ណេះ ដល់ពួកសាវកតិរិយទាំងនោះ ម្យ៉ាងទៀត ទ្រង់បានសំម្តែងធម៌ដោយន័យមានយ៉ាងនេះថា ម្នាលឧបាសកទាំងឡាយ ដែលឈ្មោះថាពុទ្ធានុស្សតិកម្មដ្ឋាន ធម្មានុស្សតិកម្មដ្ឋាន សង្ឃានុស្សតិកម្មដ្ឋាន រមែងឱ្យសោតាបត្តិមគ្គ រមែងឱ្យសោតាបត្តិផល រមែងឱ្យសកទាគាមិមគ្គរ មែងឱ្យសកទាគាមិផល រមែងឱ្យអនាគាមិមគ្គ រមែងឱ្យអនាគាមិផល រមែងឱ្យអរហត្តមគ្គ រមែងឱ្យអរហត្តផល ។ គ្រាដែលទ្រង់សម្តែងធម៌ហើយ ទើបត្រាស់ថា



www.elibraryofcambodia.org

ពួកអ្នកទម្លាយសរណៈឈ្មោះនេះ នឹងធ្វើកម្មដែលមិនសមគួរ ។ ហើយម្យ៉ាងទៀត ពុទ្ធានុស្សតិកម្មដ្ឋានជាដើម ដែលជាផ្លូវឱ្យដល់សោតាបត្តិមគ្គជាដើមនេះ គប្បីសម្ដែងដល់ព្រះសូត្រទាំងឡាយមានអត្ថយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ឯកដែលបុគ្គលចម្រើនហើយ និងធ្វើឱ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយ ដើម្បីបន្ទោបង់នូវរាគៈ ដើម្បីកម្ចាត់នូវសេចក្ដីត្រេកអរ ដើម្បីសេចក្ដីរលត់ ដើម្បីសេចក្ដីស្ងប់រម្ងាប់ ដើម្បីដឹងដ៏ក្រៃលែង ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន តើធម៌ឯកដូចម្ដេច ? គឺពុទ្ធានុស្សតិ ដូច្នេះ ។

ឯព្រះមានព្រះភាគជាម្ចាស់ ទ្រង់ឱ្យឱវាទឧបាសកទាំង-ឡាយ ដោយប្រការផ្សេងៗ យ៉ាងនេះហើយ បានត្រាស់ថា ម្នាលឧបាសកទាំងឡាយ សូម្បីក្នុងកាលមុន មនុស្សទាំងឡាយប្រកាន់យកវត្ថុដែលមិនមែនជាសរណៈ ថាជាសរណៈ ដោយការប៉ាន់ស្មានដោយការប្រកាន់ខុស ។ បានពោលត្រូវជាផស្សាហារ ( ជាអាហារ ) របស់យក្សក្នុងផ្លូវកន្តារដែលអមនុស្សនាំ ( អូសទាញ )



www.elibraryofcambodia.org

ហើយដល់សេចក្ដីវិនាសយ៉ាងក្រៃលែង ។

ចំណែកពួកមនុស្សប្រកាន់យកធមិដ៏ប្រពៃ ប្រកាន់យកសេចក្ដីពិតប្រាកដ ប្រកាន់យកការមិនខុស បានដល់សេចក្ដីសុខក្នុងផ្លូវកន្ដារនោះឯង គ្រាត្រាស់ហើយ ក៏ទ្រង់បាននៅស្ងៀម ។ លំដាប់នោះឯង អនាថបិណ្ឌិកគហបតីក្រោកឡើងអំពីអាសនៈថ្វាយបង្គំព្រះមានព្រះភាគជាម្ចាស់ ពោលសរសើរ ហើយប្រណម្យអញ្ជលីដាក់លើក្បាល ក្រាបទូលយ៉ាងនេះថា ឥឡូវនេះកាលដែលពួកឧបាសកទាំងនេះទម្លាយសរណៈដ៏ឧត្ដម ហើយកាន់យកសរណៈដោយការប៉ាន់ស្មាន គឺប្រកាន់យកខុសប្រាកដដល់ខ្ញុំព្រះអង្គ ចំណែកក្នុងគ្រាមុននោះ អ្នកប្រកាន់ដោយការខុស មានសេចក្ដីវិនាសឯពួកមនុស្សដែលប្រកាន់ដោយប្រពៃ មានសេចក្ដីសុខក្នុងផ្លូវកន្ដារ អនាថបិណ្ឌិកក្រាបទូលថា បពិត្រព្រះអង្គ ដែលអមនុស្សអូសទាញ វង្វេងលិចលង់សម្រាប់ខ្ញុំព្រះអង្គ មិនប្រាកដដល់ខ្ញុំព្រះអង្គឡើយ ដូចខ្ញុំព្រះអង្គសូមឱកាស សូមព្រះមានព្រះភាគជាម្ចាស់ទ្រង់មេត្តាធ្វើហេតុនេះឱ្យប្រាកដ ដូចញុំាងព្រះចន្ទឱ្យពេញវង់



www.elibraryofcambodia.org

ដូច្នេះ ។

លំដាប់នោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលគហបតី តថាគតនេះឯង បំពេញបារមី ១០ ក្នុងកាលរកប្រមាណមិនបាន រហូតបានត្រាស់ព្រះសព្វញ្ញុតញ្ញាណ ក៏ដើម្បីនឹងកាត់នូវសេចក្តីសង្ស័យរបស់មនុស្សលោកនោះឯង អ្នកចូរផ្ទៀងសោតាស្តាប់ដោយគោរព ដូចបុគ្គលយកថាសមាសដាក់ពេញ ដោយទឹកដោះគោរាវដូច្នេះ ហើយទ្រង់ញ៉ាំងសតិឱ្យកើតដល់សេដ្ឋី ហើយទើបទ្រង់ធ្វើហេតុការណ៍ សូម្បីរវាងភពដែលបិទបាំងទុក ឱ្យប្រាកដដូចទម្លាយអ័ព្ទ ហើយនាំព្រះចន្ទដែលពេញវង់ឱ្យផុតចាកអ័ព្ទនោះ ដូច្នេះ។

ក្នុងអតីតកាល មានព្រះរាជាព្រះនាមថា ព្រហ្មទត្ត ក្នុងនគរពារាណសី ក្នុងដែនកាសី ។ ក្នុងកាលនោះ ព្រះពោធិសត្វបដិសន្ធិក្នុងត្រកូលអ្នកជំនួញ រហូតដល់ការចម្រើនវ័យដោយលំដាប់ បានត្រាច់ទៅធ្វើជំនួញ ដោយរទេះ ៥០០ ព្រះពោធិសត្វគ្រាខ្លះ ចេញពីដើមដែនទៅកាន់ចុងដែន គ្រាខ្លះ ក៏ចេញអំពីចុងដែនទៅកាន់ដើមដែន ។ ក៏ក្នុងក្រុងពារាណសីនោះឯង មានអ្នក



www.elibraryofcambodia.org

ជំនួញម្នាក់ទៀត អ្នកជំនួញម្នាក់នោះ ជាមនុស្សល្ងង់ មិនមានបញ្ញា មិនឆ្លាតក្នុងឧបាយ ។ ក្នុងកាលនោះ ព្រះពោធិសត្វមកយកទំនិញមានតម្លៃច្រើនអំពីក្រុងពារាណសី ដែលផ្ទុកទំនិញក្នុងរទេះទាំង ៥០០ ហើយធ្វើការត្រៀមធ្វើដំណើរទៅ ។ ចំណែកអ្នកជំនួញល្ងង់នោះ ក៏ផ្ទុកក្នុងរទេះ ៥០០ យ៉ាងនោះដូចគ្នា ហើយធ្វើការត្រៀមធ្វើដំណើរទៅ ព្រះពោធិសត្វគិតថា បើអ្នកជំនួញមនុស្សល្ងង់នឹងទៅព្រមជាមួយយើងនោះសោត ការធ្វើដំណើរទៅព្រមគ្នា សូម្បីផ្លូវក៏មិនល្មមនឹងធ្វើដំណើរ និងទឹកជាដើមរបស់ពួកមនុស្សក្តី ស្មៅដើម្បីគោក្តី នឹងរកបានដោយលំបាក អ្នកជំនួញជាមនុស្សល្ងង់នេះ ឬយើង គួរនឹងទៅមុន ។ ទើបព្រះពោធិសត្វ ហៅអ្នកជំនួញនោះមកប្រាប់សេចក្តីនោះហើយ ពោលថា យើងទាំងពីរ មិនអាចទៅរួមគ្នា លោកនឹងទៅមុន ឬទៅក្រោយ ។ អ្នកជំនួញនោះគិតថា កាលយើងទៅមុន នឹងមានផលប្រយោជន៍ច្រើន យើងនឹងទៅតាមផ្លូវនេះ ពួកគោនឹងបានស៊ីស្មៅ ដែលមិនទាន់នរណាត្រូវការ ( ដែលនៅមិនទាន់មានគេប៉ះពាល់ ) និងទឹកក៏ថ្លា យើងនឹងតាំង



www.elibraryofcambodia.org

តម្លៃទំនិញបានតាមពេញចិត្ត ។ ទើបអ្នកជំនួញពោលថា សម្លាញ់ យើងនឹងទៅមុន ។ ព្រះពោធិសត្វបានឃើញកាលទៅខាងក្រោយ ក៏គិតថា ប្រយោជន៍ច្រើន ព្រះពោធិសត្វមានការគិតយ៉ាងនេះថា មនុស្សទាំងនោះ កាលទៅមុន នឹងធ្វើកន្លែងដែលរដិបរដុបក្នុងផ្លូវ ឱ្យរាបស្មើ យើងនឹងធ្វើដំណើរទៅតាមផ្លូវ ដែលមនុស្សទាំងនោះ ទៅ ហើយកាលគោប្រើការងារ ដែលទៅមុនបរិភោគស្មៅចាស់ និងរឹង គោទាំងឡាយរបស់យើង នឹងបរិភោគស្មៅដែលឆ្ងាញ់ និង ទន់ដែលដុះឡើងថ្មី និងស្លឹកឈើខ្ចីៗ ដែលយកមកធ្វើជាអាហារ របស់ពួកមនុស្ស ដែលដុះឡើងអំពីទីដែលត្រូវកម្តៅជារបស់គួរ បរិភោគ ( ឆ្ងាញ់ ) ។ ក្នុងទីដែលមិនមានទឹក មនុស្សទាំងនោះនឹង ជីកអណ្តូង ធ្វើឱ្យទឹកកើតឡើង យើងនឹងផឹកទឹកក្នុងអណ្តូងដែល មនុស្សទាំងនោះជីកទុក ការតាំងតម្លៃ ( កំណត់ ) ទំនិញដូចជា មួយការលះបង់ជីវិតមនុស្ស យើងទៅតាមក្រោយ នឹងលក់ទំនិញ តាមតម្លៃដែលមនុស្សទាំងនោះតាំងទុក ។ ហើយព្រះពោធិសត្វ



www.elibraryofcambodia.org

ឃើញអានិសង្សមានប្រមាណប៉ុណ្ណេះ ទើបពោលថា ម្នាលសម្លាញ់ លោកទៅមុនចុះ ។

អ្នកជំនួញជាមនុស្សល្ងង់ទទួលពាក្យហើយ ទើបទឹមរទេះទាំងឡាយ ចេញទៅផុតដែនដីរបស់មនុស្សចូលទៅកាន់ផ្លូវកន្ទារដោយលំដាប់ ។

ឈ្មោះថា កន្ទារមាន ៥ យ៉ាង គឺ :

កន្ទារ ព្រោះចោរ ១

កន្ទារ ព្រោះសត្វសាហាវ ១

កន្ទារ ព្រោះអត់ទឹក ១

កន្ទារ ព្រោះអមនុស្ស ១

កន្ទារ ព្រោះអាហារតិច ១

ក្នុងកន្ទារ ៥ យ៉ាងនោះ ផ្លូវដែលពួកចោរពួនស្នាក់នៅ ឈ្មោះថា កន្ទារ ព្រោះចោរ ។

ផ្លូវដែលសីហៈជាដើម មានច្រើន ឈ្មោះថា កន្ទារ ព្រោះសត្វសាហាវ ។



www.elibraryofcambodia.org

កន្លែងមិនមានទឹកងូត ឬទឹកផឹក ឈ្មោះថា កន្តារ ព្រោះអត់ទឹក ។

ផ្លូវដែលអមនុស្សអាស្រ័យនៅ ឈ្មោះថា កន្តារ ព្រោះមានអមនុស្សនៅ ។

វៀរចាករបស់ដែលគួរ កន្លែងដែលវៀរចាករបស់ដែលគួរទំពាស៊ីកើតជាដើម ឈ្មោះថា ព្រោះអាហារតិច ។

ក្នុងកន្តារ ៥ យ៉ាងនេះ កន្តារនោះ សំដៅយកកន្តារព្រោះការអត់ទឹក និងកន្តារព្រោះអមនុស្សនៅ ។ ព្រោះដូច្នេះ អ្នកជំនួញជាមនុស្សល្ងង់នោះ ទើបតាំងពាងដ៏ធំទុកលើរទេះទាំងឡាយ ដាក់ពេញទៅដោយទឹក ធ្វើដំណើរតាមផ្លូវកន្តារ ៦០ យោជន៍ ។

ក្នុងវេលាដែលអ្នកជំនួញ ជាមនុស្សល្ងង់ខ្លៅនោះទៅដល់ពាក់កណ្តាលផ្លូវកន្តារ យក្សដែលអាស្រ័យនៅក្នុងផ្លូវកន្តារ គិតថា យើងនឹងឱ្យពួកមនុស្សទាំងនោះ ចោលទឹកដែលដាក់មកឱ្យអស់ ធ្វើឱ្យច្របូកច្របល់ ( មិនមានទឹកផឹក ) ហើយស៊ីពួកវាទាំងអស់ ទើបនិម្មិតយានដ៏ល្អ គួរឱ្យរីករាយដែលទឹមដោយគោពណ៌សសុទ្ធ



www.elibraryofcambodia.org

និងហែហាមដោយអមនុស្ស ១២ នាក់ បរិបូណ៌ដោយទឹក និងគ្រឿងបរិភោគ កាន់អាវុធ ព្រមទាំងរបាំងជាដើម ប្រដាប់ដោយផ្កាឧប្បល និងផ្កាកុមុទមានសក់ទទឹក និងសំពត់ទទឹកអង្គុយលើយាននោះ មានកង់យានប្រឡាក់ដោយភក់ ធ្វើដំណើរតាមផ្លូវមក ។

ចំណែកពួកអមនុស្សជាបរិវាររបស់យក្សនោះ ដើរទៅមកខាងមុខ និងខាងក្រោយ មានសក់ទទឹក និងសំពត់សើម ប្រដាប់ដោយផ្កាឧប្បល និងផ្កាកុមុទ កាន់បាច់ផ្កាបុទុម និងផ្កា( បណ្ឌិក ) ទំពាស៊ីមើមឈូក មានតំណក់ទឹក និងភក់ បាននាំគ្នាដើរទៅ ។ ធម្មតាអ្នកជំនួញទាំងឡាយ កាលណាខ្យល់ផាត់មកខាងមុខ ក្នុងកាលនោះ នឹងអង្គុយលើយានហែហាមដោយអ្នកជាឧបដ្ឋាក គេចចេញពីធ្លៀងក្នុងផ្លូវខាងមុខ ក្នុងកាលណា ខ្យល់ផាត់មកខាងក្រោយ ក្នុងកាលនោះ ក៏គេចចេញពីផ្លូវខាងក្រោយ ដោយន័យនេះឯង ។ ក៏ក្នុងកាលនោះមានខ្យល់ផាត់មកខាងមុខ ព្រោះដូច្នេះអ្នកជំនួញជាមនុស្សល្ងង់នោះ ទើបបានទៅខាងមុខ ។

យក្សនោះឃើញអ្នកជំនួញនោះកំពុងមកខាងមុខ ទើបឱ្យ



www.elibraryofcambodia.org

**សាច់ និងឈាម ក្នុងរាងកាយរបស់យើងទាំងអស់នេះ ចូររីងស្ងួតទៅ នៅសល់តែស្បែក និងឆ្អឹងក៏ដោយ ។**

បទថា វិន្ទេ ហានយស្ស សន្តិ សេចក្តីថា រមែងប្រសព្វ គឺបានចំពោះអរិយធម៌ ពោល គឺឈាន និងវិបស្សនា អភិញ្ញា និងអរហត្តមគ្គញ្ញាណ ដែលដល់ការរាប់ថា សន្តិ ព្រោះធ្វើសេចក្តីស្ងប់ក្នុងចិត្ត និងហទយរូប ។

ពិតណាស់ ព្រះដ៏មានព្រះភាគជាម្ចាស់ពណ៌នាការនៅជាទុក្ខរបស់មនុស្សដែលខ្ជិលច្រអូស និងការនៅជាសុខរបស់មនុស្សអ្នកប្រារព្ធសេចក្តីព្យាយាមដោយព្រះសូត្រទាំងឡាយ មិនតិចយ៉ាងនេះថា :

ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកខ្ជិលច្រអូសតែងឃ្លុកឃ្លុង ដោយអកុសលធម៌ដ៏លាមក រមែងនៅជាទុក្ខ និងធ្វើប្រយោជន៍ខ្លួនដែលក្រៃលែងឱ្យសាបសូន្យទៅ ។



www.elibraryofcambodia.org

ម្នាលភិក្ខុទាំងឡាយ ចំណែកបុគ្គលអ្នកប្រារព្ធសេចក្ដីព្យាយាម ស្វាត់ចាកអកុសលធម៌ដ៏លាមក រមែងនៅជាសុខ និងធ្វើប្រយោជន៍ខ្លួនដ៏ធំឱ្យបរិបូណ៌ ម្នាលភិក្ខុទាំងឡាយ ការសម្រេចប្រយោជន៍ រមែងមិនមានដោយការព្យាយាមដ៏លាមក ។

ឥឡូវនេះ កាលនឹងទ្រង់សម្ដែងការនៅជាសុខនោះឯង ដែលបុគ្គលអ្នកប្រារព្ធសេចក្ដីព្យាយាម អ្នកមិនធ្វើការប្រកាន់មាំ អ្នកឃើញច្បាស់នឹងគប្បីសម្រេចបានដោយកម្លាំង និងសេចក្ដីព្យាយាម ទើបត្រាស់ថា **មុនី** អ្នកប្រកបដោយសេចក្ដីព្យាយាម និងកម្លាំងមិនខ្ជិលច្រអូស គប្បីបានសេចក្ដីស្ងប់ក្នុងចិត្តដូច្នេះ ។

លោកពោលពាក្យអធិប្បាយនេះទុកថា អ្នកជំនួញទាំងនោះមិនខ្ជិលច្រអូសជីកក្នុងផ្លូវខ្សាច់ រមែងបានទឹក យ៉ាងណា ភិក្ខុក្នុងសាសនានេះក៏ដូច្នោះ ជាអ្នកឈ្លាសមិនខ្ជិលច្រអូស មានសេចក្ដីព្យាយាម រមែងបាននូវសេចក្ដីស្ងប់ក្នុងចិត្តដោយបឋមជ្ឈានជាដើម ។

ម្នាលភិក្ខុ ក្នុងកាលមុន អ្នកឯងធ្លាប់បានធ្វើសេចក្ដីព្យាយាមដើម្បីត្រូវការផ្លូវទឹក ឥឡូវនេះ ហេតុអ្វី ទើបអ្នកលះបង់សេចក្ដី



www.elibraryofcambodia.org

ព្យាយាមក្នុងសាសនាជាគ្រឿងនាំចេញចាកទុក្ខ ដើម្បីប្រយោជន៍ដល់មគ្គផលនោះទៅវិញ ។

ព្រះសាស្តា ទ្រង់សម្តែងព្រះធម្មទេសនាយ៉ាងនេះហើយ ទើបទ្រង់ប្រកាសសច្ចៈ ៤ ក្នុងវេលាចប់សច្ចៈ ភិក្ខុអ្នកលះបង់សេចក្តីព្យាយាម តាំងនៅក្នុងអរហត្ត ដែលជាផលដ៏លើស។ ព្រះសាស្តាត្រាស់បន្តអនុសន្ធិ ហើយទ្រង់ប្រជុំជាតកថា អ្នកបម្រើជាមនុស្សដែលមិនលះបង់សេចក្តីព្យាយាម បានវាយថ្មឱ្យទឹកដល់មហាជនក្នុងសម័យនោះ បានជាភិក្ខុអ្នកលះបង់សេចក្តីព្យាយាមរូបនេះ ក្នុងកាលឥឡូវនេះ បរិស័ទទាំងអស់ក្នុងសម័យនោះ បានជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯប្រធានអ្នកជំនួញរទេះ បានជាតថាគត ដូច្នេះហើយបានឱ្យព្រះធម្មទេសនានេះចប់ដោយត្រឹមប៉ុណ្ណេះ ។

**វណ្ណុបថជាតកទី ២ ចប់**



www.elibraryofcambodia.org

**សេរិវវាណិជជាតកទី ៣**

ឥធ ចេ នំ វិរាធេសិ សទ្ធម្មស្ស និយាមកំ
ចិរំ ត្វំ អនុតប្បេសិ សេរិវាយំវ វាណិជោតិ។

( ព្រះសម្មាសម្ពុទ្ធត្រាស់ថា ) បើអ្នកធ្វើនូវសោតាបត្តិមគ្គ ជាគ្រឿងកំណត់នូវព្រះសទ្ធម្មនោះ ឱ្យឃ្លាតចាកសាសនា នេះហើយ អ្នករមែងក្តៅក្រហាយរឿយៗ អស់កាលយូរ ដូចជាពាណិជ ឈ្មោះសេរិវៈនេះ ។

**អដ្ឋកថា សេរិវវាណិជជាតក**

ព្រះដ៏មានព្រះភាគ កាលប្រថាប់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធភិក្ខុមួយរូប អ្នកលះបង់សេចក្តីព្យាយាមដូចគ្នា ទើបត្រាស់ព្រះធម្មទេសនានេះថា **ឥធ ចេ នំ វិរាធេសិ** ដូច្នេះជាដើម ។

ព្រះសាស្តា ទ្រង់ឃើញភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយនាំមក



www.elibraryofcambodia.org

ដូចន័យមុននោះឯង ទើបត្រាស់ថា ម្នាលភិក្ខុ អ្នកបួសក្នុងសាសនា ដែលអាចឱ្យមគ្គ និងផលកើតឡើង ការលះសេចក្ដីព្យាយាមចេញ នឹងសោកសៅអស់កាលដ៏យូរ ដូចសេរិវពាណិជសាបសូន្យចាក ថាសមាសដែលមានតម្លៃមួយសែនកហាបណៈ ដូច្នោះ ។

ភិក្ខុទាំងឡាយ ទូលសូមព្រះដ៏មានព្រះភាគជាម្ចាស់ដើម្បី ទ្រង់សម្ដែងរឿងនោះឱ្យជាក់ច្បាស់។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បានធ្វើហេតុរវាំងភពដែលបិទបាំងនោះឱ្យប្រាកដ ។

ក្នុងអតីតកាលក្នុងកប្បទី ៥ រាប់អំពីភទ្ទកប្បនេះទៅ ព្រះ ពោធិសត្វបានជាអ្នកលក់របស់ឈ្មោះថា សេរិវៈក្នុងដែន ( សេរិវ-រដ្ឋ )។ សេរិវពាណិជក្នុងកាលនោះ ទៅដើម្បីត្រូវការលក់ទំនិញជា មួយអ្នកជំនួយម្នាក់ទៀត ។ ពាណិជឈ្មោះសេរិវៈ បានឆ្លងទន្លេ ឈ្មោះថា នីលពាហៈ ហើយចូលទៅកាន់នគរឈ្មោះថា អរិដ្ឋបុរៈ ក៏បែកផ្លូវគ្នាក្នុងនគរនោះ ( ទៅម្នាក់មួយផ្លូវ ) ហើយត្រាច់ទៅ លក់របស់ក្នុងផ្លូវដែលខ្លួនបានទៅ ។



www.elibraryofcambodia.org

ឯពាណិជម្នាក់ទៀត កាន់យកផ្លូវដែលខ្លួនបានទៅ ក៏ក្នុងនគរនោះ មានត្រកូលសេដ្ឋីមួយ ជាត្រកូលសេដ្ឋីយូរមកហើយ បុត្របង ប្អូន និងទ្រព្យសម្បត្តិទាំងពួង ត្រូវបានអស់ទៅហើយ ។ មានក្មេងស្រីម្នាក់ដែលរស់នៅជាមួយយាយ ។ យាយ និងចៅទាំងពីរនាក់នោះធ្វើការស៊ីឈ្នួលអ្នកដទៃដើម្បីចិញ្ចឹមជីវិត ។ ក៏ក្នុងផ្ទះមានថាសមាសដែលមហាសេដ្ឋីរបស់យាយ និងចៅនោះ ធ្លាប់ប្រើប្រាស់បានទុកជាមួយនឹងភាជនដទៃ កាលមិនបានប្រើប្រាស់មកជាយូរស្នៀខ្មៅក៏ចាប់ ។ យាយ និងចៅតែងមិនដឹងថា ថាសនេះ គឺជាថាសមាសទេ សម័យនោះ ពាណិជឡេះឡោះអំពាវនាវលក់របស់ថាថូរកាន់យកគ្រឿងប្រដាប់ បានទៅដល់ខ្លោងទ្វារនោះ កុមារិកានោះបានឃើញពាណិជនោះហើយ ពោលនឹងយាយថា យាយ សូមយាយទិញគ្រឿងប្រដាប់នោះឱ្យខ្ញុំ យាយពោលថា ចៅអើយ យើងជាអ្នកក្រ នឹងបានអ្វីទៅទិញ ចៅស្រីពោលថា ពួកយើងមានថាសមួយនេះ ជារបស់ពួកយើងសល់មកអំពីមុន ទុកទៅ វាក៏មិនបានប្រយោជន៍អ្វីដល់ពួកយើងដែរ សូមយាយឱ្យថាសនោះ ហើយកាន់



www.elibraryofcambodia.org

យកគ្រឿងប្រដាប់ឱ្យចៅ។ ទើបយាយហៅនាយពាណិជមក ហើយឱ្យអង្គុយលើអាសនៈ បានឱ្យថាសមាស ហើយពោលថា នាយចូរកាន់យកថាសនេះចុះ ហើយឱ្យគ្រឿងប្រដាប់អ្វី១ ក៏បាន ដល់ចៅស្រីរបស់ខ្ញុំ។ នាយពាណិជយកដៃចាប់ថាសនោះហើយ គិតថា វាជាថាសមាស ទើបត្រឡប់ថាសផ្កាប់យកម្ជុលឆ្លូតបាតថាស ដឹងច្បាស់ថា ជាថាសមាស ទើបគិតថា យើងនឹងមិនឱ្យអ្វី១ ដល់មនុស្សទាំងនេះឡើយ នាំយកថាសនេះទៅហើយ ពោលថា ថាសនេះមិនមានតម្លៃអ្វីសូម្បីកន្លះមាសកក៏មិនបានផង។ ឈ្មួញកំហូចបានបោះថាសមាសទៅលើដី ហើយក្រោកចាកអាសនៈ ចៀសចេញទៅ ។

ព្រះពោធិសត្វ បានដើរលក់របស់របរនោះ១ រហូតទៅដល់ផ្លូវដែលនាយពាណិជឡេះឡោះកំហូចបានដើរ ទើបចូលទៅកាន់ផ្លូវនោះ ស្រែកលក់របស់ថា ចូរកាន់យកនូវគ្រឿងប្រដាប់ ដូច្នេះ ហើយបានទៅដល់ខ្លោងទ្វារផ្ទះនោះឯង កុមារិការនោះបានពោលនឹងជីដូនដូចមុនទៀត ។ លំដាប់នោះ យាយបានពោលនឹងនាង



www.elibraryofcambodia.org

កុមារិកានោះថា ចៅអើយ ឈ្មួញដែលបានមកដល់ផ្ទះនេះ បានបោះថាសនោះទៅនឹងដី ហើយឥឡូវនេះ យើងបានអ្វីឱ្យគេទៀតដើម្បីបានគ្រឿងប្រដាប់។ ចៅពោលថា អើ ឈ្មួញមុននោះនិយាយសំឡេងគ្រោតគ្រាតណាស់ ឯឥឡូវនេះ ឈ្មួញនេះ គួរឱ្យស្រឡាញ់ និយាយដោយសំឡេងទន់ភ្លន់ គាត់មុខជានឹងទទួលយកមិនខាន។ យាយពោលថា បើយ៉ាងនោះ ចូរហៅគេមក។ ចៅស្រី ក៏បានស្រែកហៅនាយពាណិជដែលជាព្រះបរមពោធិសត្វ។ លំដាប់នោះយាយ និងចៅ បានយកថាសមាសនោះ ឱ្យដល់ព្រះបរមពោធិសត្វដែលបានចូលមកអង្គុយក្នុងផ្ទះ។ ព្រះបរមពោធិសត្វដឹងថា ជាថាសមាស ទើបពោលថា ម៉ែ ! ថាសនេះ មានតម្លៃដល់ទៅរាប់សែនកហាបណៈ ឯរបស់ដែលមានតម្លៃស្មើនឹងថាសនេះ មិនមានក្នុងដៃរបស់ខ្ញុំបាទឡើយ ទើបយាយ និងចៅពោលថា នែនាយដ៏មានបុណ្យអើយ នាយពាណិជដែលមកមុននោះ បានពោលថា ថាសនេះមានតម្លៃមិនដល់កន្លះមាសកផង ហើយគ្រវែងថាសនេះចោលទៅនឹងដី ប៉ុន្តែថាសនេះ បានកើតជាថាសមាស ព្រោះបុណ្យរបស់



www.elibraryofcambodia.org

លោក លោកឱ្យអ្វី១ ដល់ពួកយើងក៏បានដែរ ។ ខណៈនោះ ទើបព្រះបរមពោធិសត្វឱ្យកហាបណៈ ៥០០ ដែលមាននៅនឹងដៃ ព្រមទាំងគ្រឿងរបស់ទាំងអស់ ដែលតម្លៃស្មើនឹង ៥០០ កហាបណៈផងដែរ សូមទុកត្រឹមតែ ៨ កហាបណៈ ។ អ្នកទាំងពីរចូរឱ្យជញ្ជីងនិងបាវ ព្រមទាំងកហាបណៈ ៨ កហាបណៈនេះដល់ខ្ញុំបាទ រួចហើយក៏បានកាន់យកថាសនោះឯង រូតរះទៅកាន់កំពង់ទឹក ។ ព្រះបរមពោធិសត្វប្រញាប់ទៅកាន់មាត់ទន្លេឱ្យម្ចាស់ទូក ៨ កហាបណៈ ហើយក៏ឡើងកាន់ទូកទៅ ។ ចំណែកនាយពាណិជពាល ក៏ត្រឡប់ទៅកាន់ផ្ទះនោះម្ដងទៀត ហើយពោលថា អ្នកចូរនាំថាសមាសនោះមក យើងនឹងឱ្យរបស់ខ្លះដល់អ្នក ។ ស្ត្រីនោះ បានបរិភាសតិះដៀលនាយឈ្មួញពាលនោះ ហើយពោលថា លោកបានធ្វើថាសមាស ដែលមានតម្លៃច្រើនរបស់ពួកយើងឱ្យមានតម្លៃកន្លះមាសក ប៉ុន្តែនាយពាណិជដែលមានធម៌ បានឱ្យទ្រព្យមួយពាន់កហាបណៈ ហើយកាន់យកថាសមាសនោះទៅហើយ ។ នាយពាណិជកំហូចបានស្ដាប់ពាក្យនោះហើយ គិតថា យើងជាអ្នកវិនាសចាកថាស



www.elibraryofcambodia.org

មាសដែលមានតម្លៃទាំងសែនកហាបណៈ ពាណិជ្ជនោះ បានធ្វើសេចក្តីវិនាសដ៏ធំដល់យើងហ្ន៎ រួចហើយ នាយពាណិជកំហូចកើតសេចក្តីសោកដ៏មានកម្លាំង មិនអាចនឹងតាំងស្មារតីបាន ក៏ដួលសន្លប់ទៅនឹងដី ដឹងខ្លួនឡើងវិញ បានចោលកហាបណៈ ដែលនៅនឹងដៃព្រមទាំងអីវ៉ាន់ទាំងអស់ នៅនឹងមុខផ្ទះនោះឯង ចោលទាំងសំពត់ស្លៀកដណ្តប់ កាន់តែដងជញ្ជីង ធ្វើជាដំបង រត់ទៅតាមស្នាមជើងរបស់ព្រះពោធិសត្វ ។ ទៅដល់មាត់ទន្លេ ឃើញព្រះបរមពោធិសត្វកំពុងទៅហើយ ទើបពោលថា នែ៎ម្ចាស់ទូកដ៏ចម្រើន អ្នកចូរត្រឡប់ទូកមកវិញ ។

ព្រះពោធិសត្វហាមថាកុំត្រឡប់ ។ កាលនាយពាណិជពាលនោះ ឃើញព្រះបរមពោធិសត្វទៅឆ្ងាយហើយ កើតសេចក្តីសោកដ៏ខ្លាំងក្លា មានហឫទ័យក្តៅផ្សា ក៏ក្អួតឈាមស្រស់ៗ ចេញអំពីមាត់បែកទ្រូងដូចជាបែកភក់ក្នុងបឹង ដូច្នោះ ។ នាយពាណិជ្ជពាលនោះក៏ចងពៀរជាមួយព្រះពោធិសត្វ ដល់នូវការអស់ជីវិតក្នុងទីនោះឯង ។ នេះជាការចងពៀរនឹងព្រះពោធិសត្វ របស់ព្រះទេវទត្តក្នុងគ្រា



www.elibraryofcambodia.org

ដំបូង។ ព្រះបរមពោធិសត្វធ្វើបុណ្យ មានទានបារមីជាដើម ហើយក៏បានទៅតាមយថាកម្ម។ ព្រះសម្មាសម្ពុទ្ធកាលដែលព្រះអង្គត្រាស់ព្រះធម្មទេសនានេះហើយ ទ្រង់បានត្រាស់សម្ដែងព្រះគាថានេះថា

**បើអ្នកធ្វើនូវសោតាបត្តិមគ្គ ជាគ្រឿងកំណត់នូវព្រះសទ្ធម្មនោះ ឱ្យឃ្លាតចាកសាសនានេះហើយ អ្នករមែងក្ដៅក្រហាយរឿយៗ អស់កាលយូរ ដូចជាពាណិជ្ជ ឈ្មោះសេរិវៈនេះ ។**

បណ្ដាបទទាំងនោះ បទថា *យទិ ចេ តំ វិភាវេសិ សទ្-ធម្មស្ស និយាមកំ* សេចក្ដីថា បើអ្នកឃ្លាតចាកអំពីសោតាបត្តិមគ្គពោល គឺសភាវៈពិតប្រាកដនៃព្រះសទ្ធម្មយ៉ាងនេះក្នុងព្រះសាសនា។

អធិប្បាយថា កាលបើអ្នកលះបង់នូវសេចក្ដីព្យាយាម អ្នកនឹងមិនបានសម្រេច ។

បទថា *ចិរំ តំ អនុតប្បេសិ* សេចក្ដីថា កាលបើដូច្នោះ



www.elibraryofcambodia.org

អ្នករមែងសោយសោក ហើយនឹងក្តៅក្រហាយក្នុងកាលជាខាងក្រោយ រហូតអស់កាលដ៏យូរ ឈ្មោះថា នឹងក្តៅក្រហាយក្នុងចិត្តជាខាងក្រោយ ក្នុងកាលគ្រប់កាល ។

ក្នុងបទនេះ មានសេចក្តីអធិប្បាយថា អ្នកកើតក្នុងនរកជាដើម សោយទុក្ខមានប្រការផ្សេងៗ អស់កាលជាយូរអង្វែង ។

ដែលថានឹងក្តៅក្រហាយចិត្តក្នុងកាលជាខាងក្រោយ គឺថានឹងលំបាកព្រោះភាពជាអ្នកលះបង់នូវសេចក្តីព្យាយាម ធ្វើឱ្យឃ្លាងចាកអំពីអរិយមគ្គ ។

សួរថា តើក្តៅក្រហាយក្នុងកាលជាខាងក្រោយដូចម្តេច ?

ឆ្លើយថា នឹងក្តៅក្រហាយក្នុងកាលជាខាងក្រោយ ដូចនាយពាណិជឈ្មោះសេរិវៈ ។ លោកពោលពាក្យអធិប្បាយនេះទុកថា កាលមុន ពាណិជ្ជឈ្មោះសេរិវៈបានថាសមាសមានតម្លៃមួយសែន ប៉ុន្តែមិនធ្វើសេចក្តីព្យាយាមដើម្បីនឹងកាន់យកថាសមាសនោះ ទើបវិនាសចាកថាសមាសនោះឯង ហើយក្តៅក្រហាយក្នុងកាលជាខាងក្រោយ យ៉ាងណា សូម្បីអ្នកក៏យ៉ាងនោះ ។ កាលដែលមិនបានសម្រេចនូវអរិយមគ្គ ដូចជាថាសមាស ដែលគេត្រៀមទុកឱ្យក្នុង



www.elibraryofcambodia.org

ព្រះសាសនា ព្រោះលះបង់នូវសេចក្តីព្យាយាម ក៏ជាអ្នកវិនាសចាក អរិយមគ្គនោះ នឹងក្តៅក្រហាយក្នុងកាលជាខាងក្រោយ រហូតអស់កាលជាអង្វែង ។ ប្រសិនបើអ្នកមិនលះបង់នូវសេចក្តីព្យាយាមទេ អ្នកនឹងបានសម្រេចនូវលោកុត្តរធម៌ គឺមគ្គទាំង ៤ ក្នុងសាសនារបស់តថាគត ដូចនាយពាណិជដែលជាបណ្ឌិត បាននូវថាសមាសនោះ ដូច្នោះឯង ។

ព្រះបរមសាស្តាទ្រង់កាន់យកនូវកំពូលធម៌ គឺព្រះអរហត្ត សម្តែងធម្មទេសនានេះដល់ភិក្ខុនោះយ៉ាងដូច្នោះឯង ហើយទ្រង់ប្រកាសនូវសច្ចៈទាំង ៤ ។ ក្នុងវេលាចប់សច្ចកថា ភិក្ខុជាអ្នកលះបង់នូវសេចក្តីព្យាយាម ក៏បានតាំងនៅក្នុងអរហត្ត ជាផលដ៏កំពូល ។ ព្រះអង្គទ្រង់ប្រជុំជាតកថា ពាណិជពាលក្នុងកាលនោះ បានជាភិក្ខុទេវទត្តក្នុងកាលនេះឯង ឯនាយពាណិជដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ទ្រង់ក៏បញ្ចប់នូវព្រះធម្មទេសនានេះ ។

**សេរិវវាណិជជាតកទី ៣ ចប់**



www.elibraryofcambodia.org

## ចុល្លកសេដ្ឋីជាតកទី ៤

អប្បកេនបិ មេធាវី បាភតេន វិចក្ខណោ
សមុដ្ឋាបេតិ អត្តានំ អណុំ អគ្គឹវ សន្ធមំ។

( ព្រះសាស្តាទ្រង់ត្រាស់ថា ) អ្នកប្រាជ្ញឈ្លាសវៃ រមែងតាំងខ្លួនបានដោយទ្រព្យជាដើមទុន សូម្បីមានប្រមាណតិច ដូចបុគ្គលបង្កាត់ភ្លើងដ៏តូច ។

## អដ្ឋកថា ចុល្លកសេដ្ឋីជាតក

ព្រះដ៏មានព្រះភាគជាម្ចាស់ ស្តេចចូលទៅអាស្រ័យក្នុងក្រុងរាជគ្រឹះ ប្រថាប់នៅក្នុងជីវកម្ពវ័ន ទ្រង់ប្រារព្ធព្រះចុល្លបន្ថកត្ថេរ ទើបត្រាស់ព្រះធម៌ទេសនានេះថា **អប្បកេន បិ មេធាវី** ជាដើម ។

ទើបពោលការកើតឡើង និងការបព្វជ្ជារបស់ព្រះចុល្លបន្ថកៈ ក្នុងអម្ពវ័ននោះ មានតាមលំដាប់ដូចតទៅនេះ :



www.elibraryofcambodia.org

បានឮថា ក្នុងក្រុងរាជគ្រឹះ មានធីតារបស់សេដ្ឋីជាអ្នកមានទ្រព្យច្រើន បានធ្វើសេចក្តីស្និទ្ធស្នាលជាមួយនឹងទាសៈរបស់ខ្លួនឯង ហើយខ្លាចអ្នកដទៃដឹងនូវអំពើរបស់ខ្លួន ទើបពោលយ៉ាងនេះថា បើមាតារបស់យើងដឹង ទោសនេះនឹងធ្វើយើងឱ្យជាកំណាត់តូចកំណាត់ធំ ( គឺធ្វើឱ្យវិនាស ) ពួកយើងនឹងទៅនៅស្រុកផ្សេង ។ ហើយយករបស់សំខាន់ដែលអាចយកទៅបាន

ហើយក៏ចេញទៅតាមទ្វារស្ងាត់ៗ ។ អ្នកទាំងពីរនាក់បាននាំគ្នាទៅដោយគិតថា នឹងទៅកាន់កន្លែងដែលមនុស្សមិនស្គាល់ ហើយនៅក្នុងទីណាមួយ ។ ពីរនាក់ប្តីប្រពន្ធនោះ ក៏នៅក្នុងទីកន្លែងមួយព្រោះអាស្រ័យការនៅរួមគ្នា ធីតាសេដ្ឋីក៏តាំងគភ៌ ។ ធីតាសេដ្ឋីនោះអាស្រ័យគភ៌ ទើបពិភាក្សាជាមួយស្វាមី ហើយពោលថា គភ៌របស់យើងចាស់ ( ខែ ) ហើយ ឈ្មោះថាការប្រសូតបុត្រ ក្នុងទីកន្លែងដែលឆ្ងាយអំពីញាតិ និងបងប្អូន រមែងជាទុក្ខពិតៗ សម្រាប់យើងទាំងពីរ ពួកយើងនឹងទៅកាន់ផ្ទះរបស់ពួកយើង ។

ស្វាមីនោះគិតថា បើយើងនឹងទៅឥឡូវនេះ ជីវិតរបស់



www.elibraryofcambodia.org

ពួកយើងនឹងមិនមាន ទើបពន្យាពេលថា នឹងទៅពេលក្រោយ សេដ្ឋីធីតានោះគិតថា ស្វាមីនេះជាមនុស្ស ( ខ្លាច ) ហើយមិនចង់ទៅ ព្រោះទោសរបស់ខ្លួនមានច្រើន ធម្មតាថា មាតា បិតា មានប្រយោជន៍ច្រើនដល់បុត្រធីតា ស្វាមីនឹងទៅ ឬមិនទៅក៏ដោយ យើងគួរនឹងទៅ កាលស្វាមីនោះចេញពីផ្ទះ ទើបនាងរៀបចំបរិក្ខារក្នុងផ្ទះ ប្រាប់ដល់អ្នកស្រុកនៅជិតខាងហើយ ធ្វើដំណើរទៅ។ គ្រានោះ បុរសនោះមកផ្ទះ មិនឃើញប្រពន្ធ ទើបសួរមនុស្សដែលធ្លាប់ស្គាល់ បានឮថា នាងទៅផ្ទះរបស់នាងហើយ ទើបប្រញាប់តាមទៅ ក៏ទាន់ក្នុងវេលាពាក់កណ្តាលផ្លូវ ។

ចំណែកសេដ្ឋីធីតានោះ ប្រសូត្របុត្រក្នុងពាក់កណ្តាលផ្លូវនោះឯង ស្វាមីនោះសួរថា ម្នាលនាងដ៏ចម្រើន នេះអ្វី ?

ចំណែកធីតានោះពោលថា កូនរបស់យើងកើតហើយ ស្វាមីពោលថា ឥឡូវនេះ ពួកយើងនឹងធ្វើអ្វី ? សេដ្ឋីធីតា ពួកយើងនឹងត្រឡប់ទៅវិញ ។ ទាំងពីរអ្នកជាអ្នកមានការគិតដូចគ្នា ហើយក៏ត្រឡប់ទៅវិញ។ ព្រោះទារកនោះកើតពាក់កណ្តាលផ្លូវ ទើបមាតា



www.elibraryofcambodia.org

បិតាដាក់ឈ្មោះឱ្យថា បន្ថកៈ ។ មិនយូរប៉ុន្មាន នាងក៏តាំងគភ៌ទៀត ។ រឿងរ៉ាវទាំងពួង គប្បីឱ្យពិស្តារដោយន័យមុននោះឯង ។ ក៏ព្រោះទារកនោះកើតក្នុងកណ្តាលផ្លូវ ទើបមាតាបិតាដាក់ឈ្មោះបុត្រអ្នកកើតលើកដំបូងថាជា មហាបន្ថកៈ ដាក់ឈ្មោះបុត្រទីពីរថា ចុល្លបន្ថកៈ ។ ស្វាមីភរិយានោះ នាំទារកទាំងពីរមកកាន់ទីលំនៅរបស់ខ្លួននោះឯង ។

កាលស្វាមីភរិយាទាំងពីរនៅក្នុងទីនោះ មហាបន្ថកទារកបានស្តាប់មនុស្សដទៃៗ និយាយគ្នាថា តា និយាយគ្នាថា យាយ ទើបសួរមាតាថា ម៉ែពួកក្មេងៗ ដទៃ និយាយថា តា យាយ ញាតិរបស់ពួកយើងមានឬ ?

មាតាពោលថា ក្នុងទីនេះញាត្តិរបស់យើងមិនមាន តែនៅនគររាជគ្រឹះនោះមានច្រើន តា ឈ្មោះថា មហាធនសេដ្ឋី។ មហាបន្ថកៈពោលថា ព្រោះហេតុអ្វី ទើបពួកយើងមិនទៅក្រុងរាជគ្រឹះនោះម៉ែ ? នាងមិនប្រាប់ហេតុដែលខ្លួនមកដល់កូន ។ កាលកូនទាំងពីររំអុកសួរ ទើបពោលនឹងស្វាមីថា ក្មេងទាំងពីរនេះ ធ្វើយើង



www.elibraryofcambodia.org

ឱ្យលំបាកខ្លាំងណាស់ មាតាបិតាឃើញយើងហើយ នឹងស៊ីសាច់ឬ ? មកពួកយើងនឹងទៅកាន់ត្រកូលរបស់តាយាយទាំងឡាយ ។ ស្វាមីពោលថា យើងមិនអាចទៅ យើងនឹងមិនអាចប្រឈមមុខ តែយើងនឹងនាំទៅ ភរិយាពោលថាល្អ ពួកក្មេងៗ គួរនឹងឃើញត្រកូលរបស់តានោះឯងដោយវិធីណាមួយ ។ ជនទាំងពីរនាក់នោះ នាំទារកទាំងពីរនាក់ទៅដល់ក្រុងរាជគ្រឹះដោយលំដាប់ ហើយសម្រាកក្នុងសាលាមួយជិតទ្វារក្រុង ឱ្យគេប្រាប់ដល់មាតាបិតា ដែលមាតារបស់ទារកនាំយកទារកទាំងពីរអ្នកមក ។ តាយាយទាំងពីរស្ដាប់ដំណឹងនោះហើយ ពោលថា មនុស្សដែលឈ្មោះថាមិនមែនបុត្រ មិនមែនធីតា រមែងមិនមានដល់យើងទាំងឡាយ អ្នកត្រាច់ទៅក្នុងសង្សារវដ្ដ មនុស្សទាំងនោះ មានកំហុសច្រើនដល់ពួកយើង មនុស្សទាំងនោះ មិនអាចតាំងនៅក្នុងក្រសែភ្នែករបស់យើងបានឡើយ ជនទាំងពីរចូរកាន់យកទ្រព្យមានប្រមាណប៉ុណ្ណេះ ទៅកាន់ទីដែលសុខស្រួលចិញ្ចឹមជីវិតចុះ តែចូរឱ្យទារកទាំងពីរនាក់មកទីនេះចុះ ។ ធីតាកាន់យកទ្រព្យសម្បត្តិដែលបិតាផ្ញើមក ហើយក៏ផ្ញើទារកឱ្យទៅក្នុងក្រុង



www.elibraryofcambodia.org

តាមពួកទូតដែលមកនោះឯង។ ទារកទាំងពីរចម្រើនវ័យធំឡើងក្នុងត្រកូលរបស់ជីតា ។

បណ្ដាទារកទាំងពីរនោះចុល្លបន្ថកៈ នៅមានវ័យតូចពេក ចំណែកមហាបន្ថកៈ ទៅស្ដាប់ធម្មកថារបស់ព្រះទសពលជាមួយតា។ កាលមហាបន្ថកៈនោះស្ដាប់ធម៌ក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះសាស្ដាជានិច្ច ចិត្តក៏នាំទៅដើម្បីបព្វជ្ជា ។ ទើបមហាបន្ថកៈពោលនឹងតាថា ប្រសិនបើតាព្រម ខ្ញុំនឹងបួស។ តាពោលថា ចៅនិយាយអ្វី ? ចៅជាទីស្រឡាញ់របស់តា ការបព្វជ្ជារបស់ចៅប៉ុណ្ណោះ ល្អជាងការបព្វជ្ជាសូម្បីរបស់ក្នុងលោកទាំងអស់ បើចៅអាច ចូរបួសចុះ។ គ្រាដែលទទួលពាក្យនោះហើយ ទើបទៅកាន់សម្នាក់ព្រះសាស្ដា ។ ព្រះសាស្ដាត្រាស់ថា លោកមហាសេដ្ឋី លោកអនុញ្ញាតទារកនេះឬ ? មហាសេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទារកនេះជាចៅរបស់ខ្ញុំព្រះអង្គ គេនិយាយថា នឹងបួសក្នុងសម្នាក់ព្រះអង្គ ។ ព្រះសាស្ដា ទ្រង់ឱ្យភិក្ខុអ្នកបិណ្ឌបាតជាវត្តមួយអង្គថា អ្នកកចូរឱ្យទារកនេះបួសចុះ។ ព្រះថេរៈប្រាប់ពីកម្មដ្ឋាន



www.elibraryofcambodia.org

គឺតចបញ្ចកកម្មដ្ឋាន ដល់មហាបន្ថកៈនោះ ហើយឱ្យបួស ។ មហាបន្ថកៈរៀនពុទ្ធវចនៈជាច្រើន មានវស្សាបរិបូណ៌ហើយ បានឧបសម្បទា ធ្វើកម្មដ្ឋានដោយយោនិសោមនសិការ បានសម្រេចជាព្រះអរហន្តហើយ ។ ព្រះមហាបន្ថកៈ បាននៅដោយសេចក្ដីសុខក្នុងឈាន និងសេចក្ដីសុខក្នុងមគ្គ ទើបគិតថា យើងអាចធ្វើយ៉ាងណាហ្ន៎ ដើម្បីឱ្យសុខនេះដល់ចុល្លបន្ថកៈ លំដាប់នោះ ព្រះមហាបន្ថកត្ថេរធ្វើដំណើរទៅកាន់សម្នាក់របស់លោកសេដ្ឋី ដែលជាជីតាពោលថា លោកមហាសេដ្ឋី ប្រសិនបើលោកយល់ព្រម អាត្មាភាពនឹងឱ្យចុល្លបន្ថកៈបួស ។ មហាសេដ្ឋីពោលថា ឱ្យបួសចុះលោកម្ចាស់ដ៏ចម្រើន ។ ព្រះថេរៈឱ្យចុល្លបន្ថកទារកបួស ហើយឱ្យតាំងនៅក្នុងសីល ១០ ។ ចុល្លបន្ថកសាមណេរបួសហើយ ជាមនុស្សល្ងង់ សមដូចដែលលោកពោលថាដោយ វេលា៤ខែ មិនអាចរៀនគាថាមួយនេះថា ៖



www.elibraryofcambodia.org

បទុមំ យថា កោកនទំ សុគន្ធំ ចាតោសិយា
ផុល្លមវីតគន្ធំ អង្គីរសំបស្ស វិរោចមានំ
តបន្តមាទិច្ចមិ វន្តលិក្ខេ ។

ផ្កាឈូកក្រហម មានក្លិនក្រអូប រីកឡើងពេលព្រលឹម
ដោយមិនប្រាសចាកក្លិន យ៉ាងណាអ្នកចូរមើលព្រះអង្គ
( គឺព្រះពុទ្ធ ) មានរស្មីដ៏រុងរឿង ដូចព្រះអាទិត្យបំភ្លឺពួងដ៏
អាកាស ដូច្នោះ ។

បានឮថា ព្រះចុល្លបន្ថកៈនោះ បួសក្នុងកាលនៃព្រះកស្សបសម្មាសម្ពុទ្ធជាម្ចាស់ ជាអ្នកមានបញ្ញា បានធ្វើការសើចចំអកក្នុងវេលាដែលភិក្ខុមួយរូបរៀនឧទ្ទេស ។ ភិក្ខុនោះឯងអៀន ព្រោះការសើចចំអកនោះ ទើបមិនរៀនឧទ្ទេសមិនធ្វើការស្វាធ្យាយ ។ ព្រោះកម្មនោះ ទើបព្រះចុល្លបន្ថកៈនេះបួសប៉ុណ្ណោះ កើតជាមនុស្សល្ងង់ កាលលោករៀនរឿយៗ ទៅ បទដែលរៀនហើយ ក៏ភ្លេចអស់ទៅ ។



www.elibraryofcambodia.org

ចុល្លបន្ថកៈព្យាយាមរៀនគាថានោះអស់ ៤ ខែ ក៏នៅតែមិនចាំ ។ លំដាប់នោះ ទើបព្រះមហាបន្ថកៈអូសចុល្លបន្ថកៈនោះ ចៀសចេញពីវិហារ ដោយពោលថា ចុល្លបន្ថកៈ លោកជាអ្នកអភព្វក្នុងសាសនានេះ ដោយ ៤ ខែ មិនអាចរៀនគាថានេះបាន លោកនឹងធ្វើកិច្ចនៃបព្វជិតឱ្យដល់ទីបំផុតបានដូចម្ដេច ចូរចៀសចេញពីវិហារ ។ ព្រះចុល្លបន្ថកៈមិនប្រាថ្នាជាគ្រហស្ថ ព្រោះសេចក្ដីស្រឡាញ់ព្រះពុទ្ធសាសនា ។

ក្នុងគ្រានោះ ព្រះមហាបន្ថកៈបានជាភត្តុទ្ទេសក៍ ( អ្នកចែកភត្ត ) ។ ពេទ្យជីវកកោមារភត្យកាន់គ្រឿងក្រអូប និងផ្កាឈើជាច្រើន ទៅកាន់អម្ពវ័នរបស់ខ្លួន បូជាព្រះសាស្ដា ស្ដាប់ធម៌ហើយក្រោកចាកអំពីអាសនៈ ថ្វាយបង្គំព្រះទសពល ហើយចូលទៅរកព្រះមហាបន្ថកៈសួរថា លោកម្ចាស់ដ៏ចម្រើន ក្នុងសម្នាក់ព្រះសាស្ដាមានភិក្ខុប៉ុន្មានអង្គ ? ព្រះមហាបន្ថកៈពោលថា មានព្រះភិក្ខុប្រមាណ ៥០០ អង្គ ។

ពេទ្យជីវកពោលថា លោកម្ចាស់ដ៏ចម្រើន ថ្ងៃស្អែក សូម



www.elibraryofcambodia.org

លោកម្ចាស់នាំភិក្ខុ ៥០០ អង្គ មានព្រះពុទ្ធជាប្រធាន ទៅទទួលភិក្ខាក្នុងសម្នាក់របស់ខ្ញុំ។ ព្រះថេរៈពោលថា ឧបាសក ឈ្មោះចុល្ល-បន្ថកៈជាអ្នកល្ងង់ មានធម៌មិនលូតលាស់ បរិសុទ្ធអាត្មាភាពនឹងនិមន្តភិក្ខុដ៏សេស វៀរតែភិក្ខុចុល្លបន្ថកៈនោះ ។ ព្រះចុល្លបន្ថកៈបានស្តាប់ដូច្នោះ ទើបគិតថា ព្រះថេរៈបងប្រុសរបស់យើង កាលទទួលនិមន្តដើម្បីភិក្ខុទាំងឡាយ មានប្រមាណប៉ុណ្ណេះ ក៏ទទួលចំណែកយើងទុកផ្នែកខាងក្រៅ បងប្រុសរបស់យើងនឹងមិនពេញចិត្តដោយឥតសង្ស័យ ឥឡូវនេះ យើងមានប្រយោជន៍អ្វីដោយព្រះសាសនានេះ យើងនឹងទៅជាគ្រហស្ថ នឹងធ្វើបុណ្យ មានទានជាដើម ហើយចិញ្ចឹមជីវិត ។ យប់ថ្ងៃស្អែកព្រះចុល្លបន្ថកៈនោះ ធ្វើដំណើរទៅពីព្រលឹម ដោយគិតថា នឹងជាគ្រហស្ថក្នុងវេលាទៀបភ្លឺ ។

ព្រះសាស្តាទ្រង់ប្រមើលមើលសត្វលោក បានឃើញហេតុនោះៗ ឯង ទើបស្តេចយាងទៅមុនស្រេច ហើយបានប្រថាប់ឈរនៅខ្លោងទ្វារផុតផ្លូវ ដែលចុល្លបន្ថកៈទៅ ។ ព្រះចុល្លបន្ថកៈ កាលនឹងដើរទៅផ្ទះឃើញព្រះសាស្តា ទើបចូលគាល់ ហើយថ្វាយបង្គំ ។



www.elibraryofcambodia.org

លំដាប់នោះ ព្រះសាស្ដាទ្រង់ត្រាស់នឹងព្រះចុល្លបន្ថកៈនោះថា ចុល្លបន្ថកៈ អ្នកទៅណាក្នុងវេលានេះ ។ ព្រះចុល្លបន្ថកៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បងប្រុសរបស់ខ្ញុំព្រះអង្គ បណ្ដេញខ្ញុំអង្គចេញ ហេតុនោះហើយ ខ្ញុំព្រះអង្គនឹងទៅជាគ្រហស្ថ ។ ព្រះ-សាស្ដាទ្រង់ត្រាស់ថា ចុល្លបន្ថកៈ ឈ្មោះថា ការបព្វជ្ជារបស់អ្នកក្នុងសម្នាក់របស់តថាគត ត្រូវបងប្រុសបណ្ដេញទៅ ព្រោះហេតុអ្វីទើបមិនមកនៅក្នុងសម្នាក់របស់តថាគត មកចុះ ប្រយោជន៍អ្វីអ្នកនឹងគ្រហស្ថ ។ អ្នកចូរនៅក្នុងសម្នាក់របស់តថាគត ហើយទ្រង់នាំព្រះចុល្លបន្ថកៈទៅ ឱ្យព្រះចុល្លបន្ថកៈនោះអង្គុយខាងមុខព្រះគន្ធកុដិត្រាស់ថា ចុល្លបន្ថកៈ អ្នកចូរបែរមុខទៅទិសខាងកើត ចូរនៅក្នុងទីនេះចុះ ហើយអង្អែលសំពត់ចាស់ទៅថា **រជោ ហរណំ រជោ ហរណំ** សំពត់ជាគ្រឿងនាំធូលីទៅៗ ហើយទ្រង់ប្រទានសំពត់ចាស់ដ៏បរិសុទ្ធ ដែលទ្រង់តាក់តែងដោយរិទ្ធ ។ កាលគេក្រាបទូលវេលាទទួលភត្តាហារឱ្យទ្រង់ជ្រាប ទើបហែហមដោយភិក្ខុសង្ឃស្ដេចទៅកាន់និវេសន៍របស់ពេទ្យជីវក ប្រថាប់លើអាសនៈដែលគេ



www.elibraryofcambodia.org

ក្រាលទុកហើយ ឯព្រះចុល្លបន្ថកៈសម្លឹងមើលទៅព្រះអាទិត្យ ហើយអង្គុយអង្អែលសំពត់ចាស់នោះថា រជោហរណំ រជោហរណំ កាលព្រះចុល្លបន្ថកៈ កំពុងតែស្ទាបអង្អែលសំពត់ចាស់នោះ ស្រាប់តែសំពត់នោះសៅហ្មងទៅ ពេលនោះ ទើបព្រះចុល្លបន្ថកៈគិតថា សំពត់ចាស់ផ្ទាំងនោះបរិសុទ្ធក្រៃលែង តែព្រោះអាស្រ័យអត្តភាពនេះ ទើបសំពត់ដែលនៅជាប្រក្រតី ទៅជាសៅហ្មងយ៉ាងនេះ សង្ខារទាំងឡាយមិនទៀងហ្ន៎ ផ្ដើមវិបស្សនាដោយការអស់ទៅនិងការវិនាសទៅ។ ព្រះសាស្តាទ្រង់ជ្រាបថា ចិត្តរបស់ចុល្លបន្ថកៈឡើងកាន់វិបស្សនាហើយ ទើបទ្រង់ត្រាស់ថា ចុល្លបន្ថកៈ អ្នកកុំធ្វើសេចក្តីសម្គាល់ថា សំពត់ចាស់នោះប៉ុណ្ណោះជារបស់សៅហ្មងដោយផង់ធូលី តែធូលី គឺរាគៈជាដើមនោះមាននៅខាងក្នុង អ្នកចូរនាំធូលី គឺរាគៈជាដើមនោះចេញ ទ្រង់បញ្ចេញពន្លឺជាអ្នកមានព្រះរូបកាយឆោមប្រាកដ ដូចគង់ប្រថាប់នៅខាងមុខ បានត្រាស់ព្រះគាថានេះថា :



www.elibraryofcambodia.org

**រាគះ** ហៅថា ធូលី តែលម្អងធូលី មិនហៅ
ថាធូលីទេ ពាក្យថា ធូលីនេះ ជាឈ្មោះរបស់រាគៈ
ភិក្ខុទាំងឡាយលះធូលីនោះបានហើយ រមែងនៅក្នុង
សាសនារបស់ព្រះពុទ្ធ ជាអ្នកប្រាសចាកធូលី **ទោសះ**
ហៅថា ធូលី តែលម្អងមិនហៅថា ធូលីទេ ពាក្យថា
ធូលីនេះ ជាឈ្មោះរបស់ទោសៈ ភិក្ខុទាំងឡាយ លះ
ធូលីនោះបានហើយ រមែងនៅក្នុងសាសនារបស់ព្រះ
ពុទ្ធ ជាអ្នកប្រាសចាកធូលី **មោហះ** ហៅថា ធូលី
តែលម្អងធូលី មិនហៅថា ធូលីទេ ពាក្យថា ធូលីនេះ
ជាឈ្មោះរបស់មោហៈ ភិក្ខុទាំងឡាយ លះធូលីនោះ
បានហើយ រមែងនៅក្នុងសាសនារបស់ព្រះពុទ្ធ ជា
អ្នកប្រាសចាកធូលី ។

ក្នុងវេលាចប់ព្រះគាថា ព្រះចុល្លបន្ថកៈសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទា បិដកទាំង ៣ មកប្រាកដដល់ព្រះចុល្លបន្ថកៈនោះ ព្រមដោយបដិសម្ភិទាទាំងឡាយ ។



www.elibraryofcambodia.org

បានឮថា ក្នុងកាលមុនព្រះចុល្លបន្ថកៈនោះជាព្រះរាជា កំពុងធ្វើប្រទក្សិណព្រះនគរ កាលញើសបានហូរចេញពីព្រះនលាដ( ថ្ងាស) ទើបយកសំពត់សាដកដែលបរិសុទ្ធជូតព្រះនលាដ សំពត់សាដក ក៏បានសៅហ្មងទៅ ព្រះរាជានោះទ្រង់បានអនិច្ចសញ្ញា ដោយភាពមិនទៀងថា សំពត់សាដកដែលបរិសុទ្ធបែបនេះ លះប្រក្រតីដើមទៅជាសៅហ្មងព្រោះអាស្រ័យរាងកាយនេះ សង្ខារទាំងឡាយមិនទៀងហ្ន៎ ដោយហេតុនោះ សំពត់ជាគ្រឿងនាំធូលីចេញទៅប៉ុណ្ណោះ ក៏កើតជាបច្ច័យដល់ព្រះចុល្លបន្ថកៈនោះ ។

ចំណែកពេទ្យជីវកកោមារភច្ច នាំយកទឹកទក្ខិណោទកចូលទៅថ្វាយព្រះទសពលព្រះសាស្តា ទ្រង់យកព្រះហស្តបិទបាត្រ ដោយត្រាស់ថា ជីវក ក្នុងវិហារមិនមានភិក្ខុឬ ? ព្រះមហាបន្ថកៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងវិហារមានភិក្ខុឬ ព្រះអង្គ ? ព្រះសាស្តាត្រាស់ថា ជីវក មានភិក្ខុ ។ ទើបពេទ្យជីវកបញ្ជូនបុរសម្នាក់ទៅដោយពាក្យថា នាយ ប្រសិនបើយ៉ាងនោះ អ្នកចូរទៅម្យ៉ាងទៀត ចូរដឹងថា ក្នុងវិហារមានភិក្ខុ ឬមិនមាន ខណៈនោះ



www.elibraryofcambodia.org

ព្រះចុល្លបន្ថកៈគិតថា បងប្រុសយើងនិយាយថា ក្នុងវិហារមិនមានភិក្ខុ យើងនឹងប្រកាសភាពដែលភិក្ខុទាំងឡាយ មាននៅក្នុងវិហារដល់បងប្រុសរបស់យើងនោះ ហើយបណ្តាលឱ្យអម្ពវ័នទាំងអស់ពេញទៅដោយភិក្ខុទាំងឡាយប៉ុណ្ណោះ ភិក្ខុមួយពួកធ្វើចីវរកម្ម ភិក្ខុមួយពួកធ្វើកម្ម គឺជ្រលក់ចីវរ ភិក្ខុមួយពួកធ្វើការស្វាធ្យាយ លោកនិម្មិតភិក្ខុ ១០០០ រូប ដែលដូចគ្នានិងគ្នាយ៉ាងនេះ បុរសនោះឃើញភិក្ខុច្រើនសន្ធឹកសន្ធាប់ក្នុងវិហារ ទើបត្រឡប់ទៅប្រាប់ពេទ្យជីវកថា បពិត្រអ្នកប្រុស ក្នុងអម្ពវ័នទាំងមូលពេញដោយភិក្ខុទាំងឡាយនោះឯង ។

ព្រះថេរៈ **កំនិម្មិតអត្តភាពទាំងពាន់ ( សុទ្ធតែ ) ព្រះចុល្លបន្ថកៈ គង់នៅក្នុងអម្ពវ័នដ៏រុងរោចន៍ រហូតដល់ប្រកាសវេលា ( ភត្ត ) ឱ្យជ្រាបកាល ។**

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងបុរសនោះថា អ្នកចូរទៅវិហារ ពោលថា ព្រះសាស្តាត្រាស់ហៅភិក្ខុឈ្មោះចុល្លបន្ថកៈ កាលបុរសនោះទៅពោលយ៉ាងនេះហើយ មាត់ទាំងមួយពាន់តាំងឡើង



www.elibraryofcambodia.org

ថា អាត្មាឈ្មោះចុល្លបន្ថកៈ។ បុរសចូលទៅក្រាបទូលថាបពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងនោះឈ្មោះចុល្លបន្ថកៈទាំងអស់។ ព្រះ-សាស្តាត្រាស់ថា ប្រសិនបើយ៉ាងនោះ អ្នកចូរទៅចាប់ដៃភិក្ខុដែលនិយាយថា អាត្មាឈ្មោះថាចុល្លបន្ថកៈ ភិក្ខុដ៏សេសនឹងអន្តរធានទៅ បុរសនោះបានធ្វើតាមយ៉ាងនេះ ក្នុងពេលនោះឯង ភិក្ខុប្រមាណ ១០០០ បានអន្តរធានបាត់ទៅ ព្រះថេរៈបានទៅជាមួយបុរសនោះ ក្នុងវេលាដែលសម្រេចភត្តកិច្ច ព្រះសាស្តាត្រាស់ហៅពេទ្យជីវកមកថា ជីវក អ្នកចូរទទួលបាត្ររបស់ចុល្លបន្ថកៈ ព្រះចុល្លបន្ថកៈនឹងធ្វើអនុមោទនាដល់អ្នក។ ពេទ្យជីវកបានធ្វើតាមយ៉ាងនោះ ព្រះថេរៈបន្លឺនូវសីហនាទ ដូចជារាជសីហ៍ដ៏មានកម្លាំង ញុំាងបិដកទាំងបីឱ្យកម្រើកញាប់ញ័រ ធ្វើអនុមោទនា ព្រះសាស្តាស្តេចក្រោកចាកអាសនៈ មានភិក្ខុសង្ឃជាបរិវារយាងទៅកាន់ព្រះវិហារ កាលភិក្ខុទាំងឡាយសម្តែងវត្តស្រេចហើយ ស្តេចក្រោកចាកអាសនៈ ទ្រង់ប្រថាប់ឈរពីមុខព្រះគន្ធកុដិ ព្រះសុគតសាស្តាប្រទានឱវាទដល់ភិក្ខុសង្ឃ ហើយប្រាប់ព្រះកម្មដ្ឋាន ទ្រង់ឱ្យភិក្ខុសង្ឃទៅហើយ



www.elibraryofcambodia.org

ទ្រង់ចូលទៅកាន់ព្រះគន្ធកុដិ ដែលអប់ដោយគ្រឿងក្រអូប ដ៏មានក្លិនក្រអូប ហើយទ្រង់ចូលសីហសេយ្យា ដោយទ្រង់ផ្ទៀងទៅខាងស្តាំ ។

គ្រាមួយ ក្នុងវេលាល្ងាច ភិក្ខុទាំងឡាយប្រជុំគ្នាគ្រប់ផ្នែកក្នុងរោងធម្មសភា អង្គុយដូចជាវាំងននសំពត់កម្ពលក្រហម ប្រារព្ធរឿងព្រះគុណរបស់ព្រះសាស្តាថា អាវុសោទាំងឡាយ ព្រះមហាបន្ថកៈ មិនដឹងអធ្យាស្រ័យរបស់ព្រះចុល្លបន្ថកៈ មិនអាចឱ្យរៀនគាថាមួយ ក្នុងវេលា ៤ ខែ ទាញចេញពីវិហារ ដោយពោលថា ព្រះចុល្លបន្ថកៈនេះល្ងង់ខ្លៅមិនឆ្លាត តែព្រះសម្មាសម្ពុទ្ធជាម្ចាស់បានប្រទានព្រះអរហត្តព្រម ដោយបដិសម្ភិទាដល់ព្រះចុល្លបន្ថកៈនោះ ក្នុងចន្លោះសម្រេចភត្តកិច្ច ព្រោះព្រះអង្គជាព្រះធម្មរាជាដ៏កំពូល បិដកទាំង ៣ មកព្រមដោយបដិសម្ភិទា គួរអស្ចារ្យ ឈ្មោះថា ពុទ្ធបល្ល័ង្កធំមហាសាល ។ លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីនៃរឿងនេះ ក្នុងរោងធម្មសភា ទ្រង់ព្រះតម្រិះថា ថ្ងៃនេះ តថាគតគួរទៅ ទើបស្តេចក្រោកចាកពុទ្ធសេយ្យា ទ្រង់



www.elibraryofcambodia.org

ដណ្តប់ចីវរពីរជាន់ដែលមានពណ៌ក្រហមល្អ ទ្រង់ចងវិតន្ទូវវត្ថពន្ធ ដូចផ្លេកបន្ទោរ ទ្រង់ហ៊ុមមហាចីវរខ្នាតព្រះសុគតជាមួយនឹងសំពត់កម្ពលពណ៌ក្រហម ទ្រង់ចេញចាកពីព្រះគន្ធកុដិដ៏មានក្លិនក្រអូបយាងទៅកាន់រោងធម្មសភា ដោយសភាពស្អាតស្អំ មានដំណើរដូចជាដំរីដ៏ប្រសើរ និងដូចជារាជសីហ៍ ដោយពុទ្ធលីលា ដែលមិនមានទីបំផុត ទើបស្តេចចូលទៅកាន់ពុទ្ធាសនៈ ដែលគេក្រាលទុក ហើយបានបញ្ចេញឆព្វណ្ណរង្សីមានពណ៌ ៦ ប្រការ ដូចទ្រង់ញ៉ាំងផ្ទៃទន្លេឱ្យរញ្ជួយ និងដូចពន្លឺព្រះអាទិត្យបញ្ចេញរស្មីដ៏ស្រទន់ លើកំពូលភ្នំយុគន្ធរ ដូច្នោះ។ ហើយទ្រង់ប្រថាប់នៅលើអាសនៈ កាលព្រះ-សម្មាសម្ពុទ្ធជាម្ចាស់ស្តេចយាងមកដល់ ទើបភិក្ខុសង្ឃបញ្ឈប់ការពិភាក្សា ហើយក៏នៅស្ងៀម ។

ព្រះសាស្តា ទ្រង់សម្លឹងមើលបរិស័ទដោយព្រះទ័យករុណា ទ្រង់ព្រះតម្រិះថា បរិស័ទនេះល្អ ហើយសំឡេងក្អកកណ្តាសរបស់ភិក្ខុមួយរូបក៏មិនមាន ភិក្ខុទាំងពួងនេះមានសេចក្តីគោរព ដោយសេចក្តីគោរពក្នុងព្រះពុទ្ធជាម្ចាស់ ដែលតេជះរបស់ព្រះពុទ្ធជាម្ចាស់



www.elibraryofcambodia.org

គ្រប់គ្រងហើយ កាលតថាគតអង្គុយមិនពោលអស់កប្ប ភិក្ខុទាំងឡាយក៏មិននិយាយឡើង ពោលឡើងមុន តថាគតគួរដឹងច្បាស់តថាគតនឹងពោលមុន ទើបត្រាស់ហៅភិក្ខុទាំងឡាយ ដោយព្រះសូរសៀងដូចជាសំឡេងព្រហ្មដ៏ពីរោះ ត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ឥឡូវនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី រឿងអ្វីដែលពួកអ្នកនិយាយគ្នាមិនទាន់ដាច់ស្រេច ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយអង្គុយនៅទីនេះ មិនពោលតិរច្ឆានកថាយ៉ាងដទៃឡើយ តែអង្គុយពណ៌នាព្រះគុណទាំងឡាយរបស់ព្រះអង្គប៉ុណ្ណោះថា អាវុសោទាំងឡាយ ព្រះមហា-បន្ថកៈមិនដឹងនូវអធ្យាស្រ័យរបស់ព្រះចុល្លបន្ថកៈ មិនអាចឱ្យរៀនគាថាមួយដោយ ៤ ខែ ទាញចេញពីវិហារដោយពោលថា ចុល្ល-បន្ថកៈនេះខ្លង់ខ្លៅ តែព្រះសម្មាសម្ពុទ្ធបានប្រទានព្រះអរហត្ត ព្រមទាំងបដិសម្ភិទាដល់ព្រះចុល្លបន្ថកៈនោះ ក្នុងចន្លោះភត្តនោះតែម្តង ព្រោះព្រះអង្គជាធម្មរាជាដ៏កំពូល គួរអស្ចារ្យ ឈ្មោះថា កម្លាំងរបស់ព្រះពុទ្ធទាំងឡាយធំក្រៃលែង ព្រះសាស្តាទ្រង់បានស្តាប់ពាក្យ



www.elibraryofcambodia.org

របស់ភិក្ខុទាំងឡាយហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចុល្លបន្ថកៈសម្រេចដល់ភាពជាធំក្នុងធម៌ ក្នុងធម៌ទាំងឡាយឥឡូវនេះព្រោះអាស្រ័យតថាគត តែក្នុងកាលមុន ចុល្លបន្ថកៈនេះដល់ភាពជាធំក្នុងភោគៈទាំងឡាយ ក៏ព្រោះអាស្រ័យតថាគត ។ ទើបភិក្ខុទាំងឡាយទូលអារាធនាព្រះមានព្រះភាគ ដើម្បីត្រាស់សម្តែងរឿងនោះឱ្យជាក់ច្បាស់ ព្រះមានព្រះភាគទ្រង់បានធ្វើហេតុក្នុងរវាងភពដែលបិទបាំងឱ្យប្រាកដដូចតទៅ :

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រប់គ្រងរាជសម្បត្តិនៅក្នុងក្រុងពារាណសី ក្នុងដែនកាសី ព្រះពោធិសត្វកើតនៅក្នុងត្រកូលសេដ្ឋី ចម្រើនវ័យហើយ បានទទួលតំណែងជាសេដ្ឋី បានឈ្មោះថា ចុល្លកសេដ្ឋី ចុល្លបន្ថកសេដ្ឋីនោះជាបណ្ឌិត ឈ្លាសវៃ ដឹងក្នុងនិមិត្តទាំងពួង ថ្ងៃមួយ ចុល្លកសេដ្ឋីនោះទៅកាន់ទីបម្រើព្រះរាជា ឃើញកណ្តុរងាប់កណ្តាលថ្នល់ គិតគេនក្ខត្តឫក្សខណៈនោះហើយពោលពាក្យនេះថា កុលបុត្តអ្នកមានភ្នែក គឺបញ្ញា អាចយកកណ្តុរមួយនេះទៅធ្វើការចិញ្ចឹមភរិយា នឹងប្រកបការងារបាន ។



www.elibraryofcambodia.org

កុលបុត្តអ្នកក្រខ្សត់ម្នាក់ ឈ្មោះថា ចូឡន្តេវាសិកៈ បានស្តាប់ពាក្យរបស់សេដ្ឋីនោះហើយ គិតថា លោកសេដ្ឋីនេះមិនដឹងនឹងមិននិយាយ ទើបយកកណ្តុរទៅលក់ឯផ្សារមួយកន្លែង ដើម្បីជាចំណីឆ្មា បានទ្រព្យមួយកាកណិក ទើបទិញស្ករអំពៅដោយទ្រព្យមួយកាកណិកនោះ ហើយយកក្អមមួយដួសទឹកទៅ តែឃើញពួកអ្នកក្រងផ្កាមកអំពីព្រៃ ទើបឱ្យចំណិតស្ករអំពៅម្នាក់មួយដុំៗ ហើយឱ្យផឹកទឹកម្នាក់មួយបោយ ពួកអ្នកក្រងផ្កាទាំងនោះបានឱ្យផ្កា ម្នាក់មួយកម្សង់ដល់គេ ។

សូម្បីក្នុងថ្ងៃស្អែកឡើង គេក៏យកតម្លៃផ្កាឈើនោះទិញស្ករអំពៅ និងទឹកផឹកមួយឆ្នាំងទៅកាន់សួនផ្កាមួយកន្លែង ពួកអ្នកក្រងផ្កា បានឱ្យបាច់ផ្កាឈើពាក់កណ្តាលបាច់ដល់គេ ក្នុងថ្ងៃនោះហើយក៏ទៅ មិនយូរប៉ុន្មានគេក៏ប្រាក់ ៨ កហាបណៈ ដោយឧបាយនេះ ។

ក្នុងថ្ងៃដែលមានភ្លៀងលាយខ្យល់ ឈើស្ងួត មែកឈើ និងស្លឹកឈើជាច្រើន ក្នុងព្រះរាជឧទ្យាន ត្រូវបក់ផាត់ចុះមកទៀត



www.elibraryofcambodia.org

អ្នករក្សាឧទ្យានមិនឃើញឧបាយនឹងចោល គេទៅក្នុងព្រះរាជ-ឧទ្យាននោះហើយ ពោលនឹងរក្សាឧទ្យានថា បើលោកនឹងឱ្យឈើ និងស្លឹកឈើទាំងនោះដល់ខ្ញុំ ខ្ញុំនឹងនាំរបស់ទាំងអស់ចេញពីសួននេះរបស់លោក អ្នករក្សាឧទ្យាននោះទទួលពាក្យថា យកទៅចុះនាយ ។ ទើបចូឡន្តេវាសិកៈទៅកាន់ទីធ្លាលេនរបស់ពួកក្មេងៗ ឱ្យស្ករអំពៅឱ្យជញ្ជូនឈើ និងស្លឹកឈើទាំងអស់ចេញទៅដោយវេលាមួយភ្លែត ឱ្យគរទុកត្រង់ទ្វារឧទ្យាន ក្នុងកាលនោះ ស្មូនឆ្នាំងព្រះរាជាស្វែងរកឧសដើម្បីដុតភាជនៈដីរបស់ព្រះរាជា ឃើញឈើ និងស្លឹកឈើទាំងនោះត្រង់ទ្វារឧទ្យាន ទើបយកអំពីដៃរបស់ចូឡន្តេវាសិកៈនោះ ថ្ងៃនោះចូឡន្តេវាសិកៈបានទ្រព្យ ១៦ កហាបណៈ និងភាជនៈ ៥ យ៉ាងមានពាងជាដើម ដោយការលក់ឈើ ។

កាលមានទ្រព្យ ២៤ កហាបណៈទើបចូឡន្តេវាសិកៈនោះ គិតថា យើងមានឧបាយនេះ ហើយតាំងពាងទឹកផឹកមួយពាងទុកក្នុងទីមិនឆ្ងាយពីទ្វារព្រះនគរ ដើម្បីអ្នករែកស្មៅ ៥០០ នាក់បានបរិភោគ ។ អ្នករែកស្មៅទាំងនោះពោលថា សម្លាញ់ លោកមានឧបការៈច្រើន



www.elibraryofcambodia.org

ដល់ពួកយើង ពួកយើងនឹងធ្វើអ្វីដល់លោកខ្លះ ចូឡន្តេវាសិកៈនោះពោលថា កាលកិច្ចកើតឡើងដល់យើង លោកទាំងឡាយនឹងធ្វើ ហើយត្រាច់ទៅខាងនោះខាងនេះ បានធ្វើស្និទ្ធស្នាល ដោយភាពជាមិត្រជាមួយអ្នកធ្វើការ ផ្លូវគោក និងអ្នកធ្វើការផ្លូវទឹក ។

អ្នកធ្វើការតាមផ្លូវគោកប្រាប់ដល់ចូឡន្តេវាសិកៈនោះថា ស្អែកនេះ អ្នកជួញសេះនឹងនាំសេះ ៥០០ ក្បាលមកកាន់នគរនេះ ។ នាយចូឡន្តេវាសិកៈនោះបានស្តាប់ពាក្យនោះហើយ ទើបពោលនឹងពួក អ្នករែកស្មៅថា ថ្ងៃនេះ លោកចូលឱ្យស្មៅដល់យើងម្នាក់ៗ កន្លះបាច់ ហើយកាលយើងនៅមិនទាន់បានលក់ស្មៅ លោកទាំងឡាយកុំលក់ស្មៅរបស់ខ្លួនឡើយអ្នករែកស្មៅទាំងនោះទទួលពាក្យហើយ នាំយកស្មៅ ៥០០ បាច់ទៅទុកត្រង់ទ្វារផ្ទះរបស់ចូឡន្តេវាសិកៈនោះ ។ ឈ្មួញសេះមិនបានអាហារសម្រាប់សេះក្នុងព្រះនគរទាំងអស់ ទើបឱ្យទ្រព្យ ១០០០ ដល់ចូឡន្តេវាសិកៈ ហើយកាន់យកស្មៅនោះទៅ ។

កាលកន្លងទៅ ២-៣ ថ្ងៃ សម្លាញ់អ្នកធ្វើការងារតាមផ្លូវទឹកប្រាប់ដល់ចូឡន្តេវាសិកថា ទូកធំមកចតនៅត្រង់កំពង់ហើយ ។ ចូឡន្តេ-



www.elibraryofcambodia.org

វាសិកៈគិតថា មានឧបាយនេះ ។ ទើបយកប្រាក់ ៨ កហាបណៈ ទៅជួលរថ ដែលបរិបូណ៌ដោយបរិវារទាំងពួង ហើយទៅកាន់កំពង់ដោយយសធំ ឱ្យចិញ្ចៀនមួយវង់ជាបញ្ចាំដល់នាយទូក ឱ្យហើយអង្គុយក្នុងទីមិនឆ្ងាយហើយបានផ្តាំថា កាលដែលមេឈ្មួញនៅខាងក្រៅមក ពួកលោកចូរប្រាប់ដោយការប្រញាប់ប្រញាល់ថា យើងកក់រួចហើយ ។ ម្ចាស់ឈ្មួញប្រមាណជា ១០០ នាក់ មកពីក្រុងពារាណសីបានស្តាប់ថា ទូកមកហើយ ទើបពោលឡើងថា ពួកយើងនឹងទិញយកទំនិញ ។ នាញទូកពោលថា ពួកលោកនឹងមិនបានទិញ ម្ចាស់ឈ្មួញធំនៅក្នុងទីឈ្មោះនោះ បានកក់ទុករួចហើយ ម្ចាស់ឈ្មួញទាំងនោះបានស្តាប់ពាក្យនោះហើយ ទើបត្រឡប់មកសម្នាក់របស់ចូឡន្តេវាសិកនោះ ។ មនុស្សដែលបានទទួលប្រើជិតស្និទ្ធ ទើបប្រាប់សេចក្តីដែលពួកឈ្មួញទាំងនោះមក ដល់ចូឡន្តេវាសិកអំពីពួកឈ្មួញទាំងនោះ មេឈ្មួញប្រមាណជា ១០០ នាក់នោះឱ្យកហាបណៈម្នាក់ ១ ពាន់ៗ ដែលជាអ្នកមានភាគហ៊ុនទូកជាមួយនឹងចូឡន្តេ-វាសិកៈនោះរួចស្រេចហើយ ឱ្យម្តងទៀតក្នុងម្នាក់ ១០០០ បាន



www.elibraryofcambodia.org

ចែករួចរាល់អស់ហើយ បានទិញទៅជារបស់ខ្លួនចំណែកចូឡន្តេ-វាសិកបានកាន់យកប្រាក់ចំនួន ២ សែន ត្រឡប់មកក្រុងពារាណសី គិតថា យើងគួរជាមនុស្សកតញ្ញូ ទើបឱ្យកាន់យកប្រាក់ ១ សែន ទៅទីជិតចុល្លកសេដ្ឋី លំដាប់នោះ ទើបចុល្លកសេដ្ឋីសួរចូឡន្តេវា-សិកៈនោះ ថាម្នាលអ្នក តើលោកធ្វើអ្វីទើបបានទ្រព្យសម្បត្តិនេះ ។ ចូឡន្តេវាសិកនោះពោលថា ខ្ញុំបានតាំងនៅក្នុងឧបាយដែលលោកប្រាប់ ទើបបានទ្រព្យក្នុង ៤ ខែ យ៉ាងនេះ ហើយបានប្រាប់រឿងរ៉ាវទាំងអស់ តាំងពីកណ្ដុរស្លាប់ជាដើមទៅ ។

ចុល្លកមហាសេដ្ឋី បានស្ដាប់ពាក្យរបស់ចូឡន្តេវាសិកនោះហើយ គិតថា ឥឡូវនេះ យើងនឹងធ្វើទារកឃើញពេលនេះឱ្យជារបស់យើងទើបគួរ ទើបឱ្យធីតារបស់ខ្លួនដែលចម្រើនវ័យ និងឱ្យធ្វើជាម្ចាស់ទ្រព្យទាំងអស់ ។ កាលលោកសេដ្ឋីធ្វើកាលមរណៈទៅហើយ ចូឡន្តេវាសិកនោះ ក៏បានតំណែងជាសេដ្ឋីក្នុងនគរនោះ ឯព្រះពោធិសត្វក៏បានទៅតាមយថាកម្មរបស់ខ្លួនទៅ ។

ព្រះសម្មាសម្ពុទ្ធ កាលត្រាស់ធម្មទេសនានេះ ទ្រង់ជាអ្នក



www.elibraryofcambodia.org

ត្រាស់ដឹងដោយព្រះអង្គឯង បានត្រាស់ព្រះគាថានេះថា :

**អ្នកប្រាជ្ញឈ្លាសវៃ រមែងតាំងខ្លួនបានដោយទ្រព្យ ជាដើមទុន សូម្បីមានប្រមាណតិច ដូចបុគ្គលបង្កាត់ភ្លើងដ៏តូច ។**

បណ្តាបទទាំងនោះ បទថា **អប្បកេនបិ** ប្រែថា សូម្បីតិច គឺសូម្បីតិចតួច។

បទថា **មេធាវី** ប្រែថា អ្នកមានបញ្ញា ។

បទថា **ទាភតេន** បានដល់ ដោយដើមទុនរបស់ទំនិញ ។

បទថា **វិចក្ខណោ** បានដល់ អ្នកឈ្លាសក្នុងវោហារ ។

បទថា **សមុដ្ឋាបេតិ អត្តានំ** សេចក្តីថា ញ៉ាំងទ្រព្យ និងយសធំឱ្យកើតឡើង ហើយតាំងខ្លួន គឺញ៉ាំងខ្លួនឱ្យតាំងនៅក្នុងទ្រព្យ និងយសនោះ។ សួរថា ដូចអ្វី ? ឆ្លើយថា ដូចមនុស្សបង្កាត់ភ្លើងតូច ឱ្យទៅជាធំបាន ។



www.elibraryofcambodia.org

អធិប្បាយថា បុរសអ្នកជាបណ្ឌិត ដាក់អាចម៍គោ និងកម្ទេចជាដើម ផ្លុំដោយខ្យល់មាត់ បង្កាត់ភ្លើងតូចឡើង គឺឱ្យធំឡើង បានដល់ ធ្វើឱ្យជាគំនរភ្លើងធំដោយលំដាប់ដូច្នេះ យ៉ាងណា បណ្ឌិតក៏ដូច្នោះ បានទ្រព្យដែលជាដើមទុនតិចតួច ហើយទៅប្រកបដោយឧបាយផ្សេងៗ រមែងធ្វើឱ្យទ្រព្យ និងយសឱ្យកើតឡើង គឺឱ្យរីងរឹតតែចម្រើនឡើង លុះឱ្យចម្រើនឡើង ក៏តាំងខ្លួនទុកក្នុងទ្រព្យ និងយសនោះ ឬថា រមែងតាំងខ្លួនទុក គឺធ្វើឱ្យល្អប្រសើរ គឺឱ្យប្រាកដនៅក្នុងទ្រព្យ និងយសនោះឯង ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ព្រះធម្មទេសនានេះយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ចុល្លបន្ថកៈអាស្រ័យតថាគតហើយ ដល់នូវភាពជាធំក្នុងធម៌ ព្រោះធម៌ទាំងឡាយក្នុងកាលឥឡូវនេះក៏មិនមែន ក្នុងកាលមុន ក៏អាស្រ័យតថាគត ទើបដល់នូវភាពជាធំក្នុងភោគៈ ព្រោះភោគៈទាំងឡាយ ហើយបានត្រាស់រឿង ២ រឿង បន្តអនុសន្ធិ ហើយទ្រង់ប្រជុំជាតកថា ចូឡន្តេវាសិកៈ



www.elibraryofcambodia.org

ក្នុងកាលនោះ បានជាចុល្លបន្ថកៈ ក្នុងកាលឥឡូវនេះ ចំណែក ចុល្លកមហាសេដ្ឋីក្នុងកាលនោះ បានជាតថាគតនេះឯង ។

## តណ្ឌុលនាលិជាតកទី ៥

កិមគ្ឃតី តណ្ឌុលនាឡិកាច
ពារាណសីអន្តរពាហិរានិ
អស្សុបញ្ចសតោនានិ
ឯកា តណ្ឌុលនាឡិកាតិ ។

(អាមាត្យពោធិសត្វ សួរថា) អង្ករមួយនាឡិថ្លៃ (ស្មើនឹង) ក្រុងពារាណសីទាំងខាងក្នុងទាំងខាងក្រៅ ឬ (ស្មើនឹង) សេះ ៥០០ នេះ ថ្លៃត្រឹមតែអង្ករមួយនាឡិ ទេឬ ។



www.elibraryofcambodia.org

# អដ្ឋកថា តណ្ឌុលនាឡិជាតក

ព្រះសាស្តា កាលប្រថាប់គង់នៅក្នុងព្រះជេតពនមហាវិហារ ទ្រង់ប្រារព្ធព្រះលោឡុទាយិត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **កិមគ្ឃតី តណ្ឌុលនាឡិកា** ច ដូច្នេះ ។

សម័យនោះ ព្រះទព្វមល្លបុត្របានជាភត្តុទ្ទេសកៈរបស់សង្ឃ កាលព្រះទព្វមល្លបុត្រនោះ ចែកសលាកភត្តជាដើមអំពីព្រឹក គ្រាខ្លះ ភត្តល្អក៏បានដល់ព្រះឧទាយិត្ថេរ គ្រាខ្លះ ភត្តក៏សៅហ្មង ។ ក្នុងថ្ងៃដែលបានភត្តសៅហ្មង ព្រះឧទាយិត្ថេរនោះ ក៏ធ្វើរោងស្លាកឱ្យរាត់រាយរប៉ាត់រប៉ាយ ពោលថា ព្រះទព្វៈតែប៉ុណ្ណោះដឹងដើម្បីឱ្យស្លាកឬ ពួកយើងមិនដឹងឬ ។ កាលព្រះឧទាយីនោះធ្វើឱ្យរោងស្លាករាត់រាយ ភិក្ខុទាំងឡាយបានឱ្យប្រដាប់ដាក់ស្លាកដោយពាក្យថា យកទៅចុះ លោកចូរជាអ្នកឱ្យស្លាកដល់សង្ឃចុះ ។ ចាប់តាំងពីពេលនោះមក ព្រះឧទាយីនោះបានឱ្យស្លាកនោះដល់សង្ឃ ។ ក្នុងកាលដែលឱ្យ រមែងមិនដឹងថា នេះជាភត្តប្រណីត ឬសៅហ្មង



www.elibraryofcambodia.org

ឡើយ ឬមិនដឹងថា ភត្តល្អតាំងទុកត្រង់រោងនោះឬ? ភត្តសៅហ្មងតាំងទុកត្រង់រោងនោះឬ ? រមែងមិនកំណត់ថា បញ្ជីប្រាប់ចំនួននៅក្នុងនោះ ? ក្នុងពេលដែលភិក្ខុទាំងឡាយឈរ ក៏គូសត្រង់ផ្ទៃដីឬទីជញ្ជាំង ដែលឱ្យបានដឹងថា ក្នុងទីនេះ បញ្ជីទីតាំងលំដាប់ឈរក្នុងទីនេះ បញ្ជីដែលតាំងលំដាប់ឈរ ។ ថ្ងៃស្អែកឡើង មានភិក្ខុតិចជាងខ្លះ ច្រើនជាងខ្លះ។ កាលភិក្ខុតិចជាង គំនូសក៏នៅខាងក្រោម ពេលភិក្ខុច្រើនជាង គំនូសក៏នៅខ្ពស់។ ព្រះឧទាយីនោះកាលមិនដឹងបញ្ជីដែលតាំងលំដាប់ ទើបឱ្យស្លាកទៅតាមស្នាមគំនូស ។

លំដាប់នោះ ទើបភិក្ខុទាំងឡាយពោលនឹងព្រះឧទាយីនោះថា នែអាវុសោឧទាយី ធម្មតា ស្នាមគំនូសនឹងនៅទាប ឬនៅខ្ពស់ក៏ដោយចុះ តែភត្តល្អដែលតាំងនៅកន្លែងរោងនោះ ភត្តសៅហ្មងក៏តាំងនៅកន្លែងរោងនោះដែរ។ ព្រះឧទាយី កាលនឹងឆ្លើយតបភិក្ខុទាំងឡាយ ទើបពោលថា បើយ៉ាងនោះ ព្រោះហេតុអ្វី ទើបស្នាមគំនូសតាំងនៅយ៉ាងនេះ យើងជឿតាមលោកបានដូចម្ដេច យើង



www.elibraryofcambodia.org

ជឿតាមគំនូសនេះ ។ លំដាប់នោះ ទើបភិក្ខុកំលោះ និងសាមណេរទាំងឡាយ ពោលនឹងព្រះឧទាយីនោះថា លោកម្ចាស់ឧទាយី កាលលោកឱ្យស្លាក ភិក្ខុទាំងឡាយខាតលាភ លោកមិនសមគួរឱ្យស្លាកឡើយ សូមចេញទៅអំពីរោងស្លាក ហើយអូសទាញចេញពីរោងស្លាកទៅ ។ ខណៈនោះ ក្នុងរោងស្លាកមានសភាពរាត់រាយ ។

ព្រះសាស្តា ទ្រង់បានព្រះសណ្តាប់ដូច្នេះហើយ ទើបត្រាស់សួរព្រះអានន្ទត្ថេរថា អានន្ទ ក្នុងរោងស្លាកមានសភាពរាយរតាត់រតាយ នុ៎ះជាសំឡេងអ្វី ។ ព្រះថេរៈបានក្រាបទូលរឿងនោះដល់ព្រះតថាគត ។ ព្រះសាស្តាត្រាស់ថា អានន្ទ ឧទាយីធ្វើសេចក្តីសាបសូន្យលាភដល់ជនដទៃ ព្រោះការដែលខ្លួនជាមនុស្សល្ងង់ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏បានធ្វើហើយដូចគ្នា ។ ព្រះថេរៈទូលអារាធនាព្រះដ៏មានព្រះភាគ ដើម្បីត្រាស់រឿងនោះឱ្យជាក់ច្បាស់ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អំពីហេតុការណ៍ដែលមានរវាងភព ដែលបិទបាំងទុកនោះ ឱ្យប្រាកដជាក់ច្បាស់យ៉ាងនេះថា :



www.elibraryofcambodia.org

ក្នុងអតីតកាល ដែលមានព្រះរាជាព្រះនាមថា ព្រហ្មទត្ត នៅក្នុងនគរពារាណសី ក្នុងដែនកាសី ក្នុងកាលនោះ ព្រះពោធិសត្វ របស់យើងទាំងឡាយ បានជាភ្នាក់ងារខាងកាត់ក្ដីវាយតម្លៃរបស់ ព្រះបាទព្រហ្មទត្តនោះ បានវាយតម្លៃដំរី និងសេះ កែវមណី និង មាសពេជ្រជាដើម លុះវាយតម្លៃហើយ ឱ្យមូលតម្លៃសមគួរដល់ ភណ្ឌៈនោះឯង ដល់ម្ចាស់របស់ភណ្ឌៈទាំងឡាយ តែព្រះរាជាជា មនុស្សលោភ ព្រោះភាពជាអ្នកលោភ ទើបព្រះរាជាទ្រង់ព្រះ-តម្រិះយ៉ាងនេះថា ភ្នាក់ងារវាយតម្លៃនេះ កាលវាយតម្លៃយ៉ាង នេះ មិនយូរឡើយ ទ្រព្យក្នុងវាំងរបស់យើង នឹងដល់នូវអស់ទៅ យើងនឹងតាំងអ្នកដទៃ ឱ្យជាភ្នាក់ងារវាយតម្លៃ ព្រះរាជានោះទ្រង់ ឱ្យបើកសីហបញ្ជរ ទតមើលព្រះលានហ្លួង ទ្រង់ឃើញបុរសអ្នក ស្រុកម្នាក់ ជាមនុស្សឡេះឡោះ និងជាមនុស្សល្ងង់ខ្លៅ ទើបទ្រង់ ព្រះតម្រិះថា អ្នកនេះអាចធ្វើការងារក្នុងតំណែងភ្នាក់ងារ វាយ តម្លៃរបស់យើងបាន ទើបបញ្ជាឱ្យហៅចូលមក ហើយត្រាស់ថា អ្នកអាចធ្វើការងារក្នុងតំណែងភ្នាក់ងារ វាយតម្លៃរបស់យើងបាន



www.elibraryofcambodia.org

ទេ ? បុរសនោះទូលថា អាច ទើបព្រះរាជាតាំងបុរសល្ងង់ខ្លៅនោះ ទុកក្នុងតំណែងនៃអ្នកវាយតម្លៃ ដើម្បីរក្សាទ្រព្យសម្បត្តិរបស់ព្រះអង្គ។ តាំងអំពីពេលនោះ បុរសអ្នកល្ងង់ខ្លៅនោះ កាលនឹងវាយតម្លៃដំរី និងសេះជាដើម បានវាយតម្លៃ យកតាមការពេញចិត្ត ធ្វើឱ្យខូចតម្លៃ។ ព្រោះគេតាំងនៅក្នុងតំណែង គេពោលពាក្យណា ពាក្យនោះឯងជាតម្លៃ។ គ្រានោះ ឈ្មួញសេះម្នាក់ បាននាំសេះ ៥០០ ក្បាល មកពីដែនឧត្តរាបថៈ ព្រះរាជាប្រើបម្រើឱ្យហៅបុរសនោះមកដើម្បីឱ្យវាយតម្លៃសេះ បុរសនោះបានតាំងតម្លៃសេះ ៥០០ ក្បាល ដោយតម្លៃស្មើនឹងអង្ករមួយនាឡិប៉ុណ្ណោះ លុះវាយតម្លៃហើយ ទើបពោលថា អ្នកទាំងឡាយ ចូរឱ្យអង្ករមួយនាឡិ ដល់ឈ្មួញសេះ ហើយឱ្យនាំសេះទុកក្នុងរោងសេះ ។

ទើបឈ្មួញសេះ ទៅកាន់សម្នាក់របស់ភ្នាក់ងារវាយតម្លៃអំពីដើម ប្រាប់រឿងរ៉ាវនេះ ហើយសួរថា ឥឡូវនេះ គួរធ្វើដូចម្តេច ? ភ្នាក់ងារវាយតម្លៃអំពីដើមនោះពោលថា លោកទាំងឡាយ ចូរឱ្យសំណូកដល់បុរសនោះ ហើយសួរថា សេះទាំងឡាយរបស់ពួកខ្ញុំ



www.elibraryofcambodia.org

មានតម្លៃស្មើអង្កររមួយនាឡិ រឿងនេះលោកដឹងហើយពីមុន តែខ្ញុំចង់ដឹងតម្លៃរបស់អង្កររមួយនាឡិ ព្រោះអាស្រ័យលោក លោកអាចឈរនៅក្នុងសម្នាក់របស់ព្រះរាជា ហើយនិយាយថា អង្កររមួយនាឡិនេះមានតម្លៃឈ្មោះនេះ បើគេនិយាយថា អាច ពួកលោកចូរនាំគេទៅសម្នាក់ព្រះរាជា សូម្បីយើងក៏ទៅទីនោះដែរ ។ ឈ្មួញទទួលពាក្យព្រះពោធិសត្វ ហើយឱ្យសំណូកដល់អ្នកវាយតម្លៃ ហើយប្រាប់សេចក្តីនោះ។ អ្នកវាយតម្លៃនោះបានសំណូកប៉ុណ្ណោះ ក៏ពោលថា យើងអាចវាយតម្លៃអង្កររមួយនាឡិបាន។ ឈ្មួញសេះពោលថា បើដូច្នោះ ពួកយើងនាំគ្នាទៅកាន់រាជត្រកូល ហើយបាននាំគ្នាទៅកាន់សម្នាក់ព្រះរាជា។ ព្រះពោធិសត្វក្តី អាមាត្យដទៃជាច្រើនក្តីបាននាំគ្នាទៅហើយ ឈ្មួញសេះថ្វាយបង្គំព្រះរាជា ហើយទូលសួរថា បពិត្រសម្មតិទេព ខ្ញុំព្រះអង្គបានជ្រាបថា សេះ ៥០០ ក្បាលមានតម្លៃស្មើនឹងអង្កររមួយនាឡិ តើអង្កររមួយនាឡិមានតម្លៃប៉ុន្មានណោបពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ព្រះមេត្តាត្រាស់សួរដល់ភ្នាក់ងារអ្នកវាយតម្លៃ ព្រះអង្គ ។ ខ្ញុំព្រះរាជាមិនជ្រាបការប្រព្រឹត្ត



www.elibraryofcambodia.org

ទៅនោះ ទើបត្រាស់សួរថា អ្នកវាយតម្លៃដ៏ចម្រើន សេះ ៥០០ ក្បាល មានតម្លៃប៉ុន្មាន ? អ្នកវាយតម្លៃក្រាបទូលថា មានតម្លៃអង្ករមួយនាឡិ ព្រះអង្គ ព្រះរាជាត្រាស់សួរថា អើ នាយ សេះទាំងឡាយមានតម្លៃស្មើនឹងអង្ករមួយនាឡិ តើអង្ករមួយនាឡិមានតម្លៃប៉ុន្មាន ? បុរសល្ងង់នោះក្រាបទូលថា អង្ករមួយនាឡិ មានតម្លៃស្មើនឹងក្រុងពារាណសី ទាំងខាងក្នុង និងខាងក្រៅ ព្រះអង្គ ។

បានឮថា ក្នុងកាលមុន បុរសល្ងង់នោះអនុវត្តតាមព្រះរាជា ទើបបានវាយតម្លៃសេះទាំងឡាយ ដោយអង្ករមួយនាឡិ បានសំណូកអំពីដៃរបស់ឈ្មួញ ត្រឡប់វាយតម្លៃក្រុងពារាណសី ទាំងខាងក្នុង និងខាងក្រៅ ដោយអង្ករមួយនាឡិនោះ ។ ក្នុងកាលនោះ ក្រុងពារាណសីបានហ៊ុមព័ទ្ធដោយកំពែងប្រមាណ ១២ យោជន៍ ដែនទាំងខាងក្នុង និងខាងក្រៅក្រុងពារាណសីនេះប្រមាណ ៣០០ យោជន៍ បុរសល្ងង់នោះ បានវាយតម្លៃក្រុងពារាណសីទាំងខាងក្នុង និងខាងក្រៅដ៏ធំយ៉ាងនេះ ដោយអង្ករមួយនាឡិ ដូច្នេះ ។

ព្រះពោធិសត្វបានស្តាប់ដូច្នោះ កាលនឹងសួរ ទើបពោល



www.elibraryofcambodia.org

គាថានេះថា :

**អង្ករមួយនាឡិ មានតម្លៃប៉ុនណា ក្រុង**
**ពារាណសី ទាំងខាងក្នុង ទាំងខាងក្រៅ មាន**
**តម្លៃប៉ុនណា អង្ករមួយនាឡិ មានតម្លៃស្មើនឹង**
**សេះ ៥០០ ក្បាលនេះឬ ?**

អាមាត្យទាំងឡាយបានស្តាប់ដូច្នោះ ទើបនាំគ្នាទះដៃសើច ធ្វើការចំអកថា កាលមុន ពួកយើងមានការសម្គាល់ថា ផែនដី និងរាជសម្បត្តិ កាត់ថ្លៃមិនបាន មានន័យថា រាជសម្បត្តិក្នុងក្រុងពារាណសី ព្រមទាំងព្រះរាជាដ៏ធំយ៉ាងនេះ មានតម្លៃត្រឹមតែអង្ករមួយនាឡិ ឱ ! ការដល់ព្រមរបស់ភ្នាក់ងារវាយតម្លៃ លោកជាភ្នាក់ងារវាយតម្លៃ តាំងនៅរហូតកាលមានប្រមាណប៉ុណ្ណេះ សមគួរដល់ព្រះរាជារបស់ពួកយើងតែមម្យ៉ាង។ គ្រានោះ ព្រះរាជាទ្រង់ខ្មាស ឱ្យអូសបុរសល្ងង់នោះចេញទៅ ហើយបានព្រះរាជទានតំណែងវាយតម្លៃដល់ព្រះពោធិសត្វដូចដើម ។ ព្រះពោធិសត្វបានទៅតាមយថាកម្ម ។



www.elibraryofcambodia.org

ព្រះសាស្តា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់រឿងបន្តអនុសន្ធិតទៅ ហើយទ្រង់ប្រជុំជាតកថា ភ្នាក់ងារវាយតម្លៃជាមនុស្សល្ងង់ ក្នុងកាលនោះ បានជាព្រះលូឡុទាយី ក្នុងឥឡូវនេះ ឯភ្នាក់ងារវាយតម្លៃ ជាបណ្ឌិតក្នុងកាលនោះ បានជាតថាគតនេះឯង ។

**តណ្ឌុលនាឡិជាតកទី ៥ ចប់**

## ទេវធម្មជាតកទី ៦

> ហិរិឱត្តប្បសម្បន្នា
> សុក្កធម្មសមាហិតា
> សន្តោ សប្បុរិសា លោកេ
> ទេវធម្មាតិ វុច្ចរេតិ ។



www.elibraryofcambodia.org

( ព្រះមហិសាសរាជកុមារពោធិសត្វពោលថា )

ពួកសប្បុរស អ្នកមានចិត្តស្ងប់រម្ងាប់ បរិបូណ៌
ដោយហិរិ និងឱត្តប្បៈ តាំងមាំហើយក្នុងធម៌ស
លោកពោលថា មានទេវធម៌ ក្នុងលោក ។

## អដ្ឋកថា ទេវធម្មជាតក

ព្រះមានព្រះភាគ កាលគង់ប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកមានភណ្ឌៈច្រើន ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ហិរិឱត្តប្បសម្បន្នា** ដូច្នេះ ។

បានឮថា **កុដុម្ពិកៈ** អ្នកក្រុងសាវត្ថីម្នាក់ កាលភរិយាស្លាប់ក៏បួស កុដុម្ពិកៈនោះ កាលនឹងបួស បានធ្វើបរិវេណរោងភ្លើង និងបន្ទប់រក្សាវត្ថុរបស់របរ ធ្វើបន្ទប់រក្សាផ្ទុករបស់ពេញដោយទឹកដោះថ្លា និងអង្ករជាដើមសម្រាប់ខ្លួនហើយ ទើបបួស លុះបួសហើយ ឱ្យហៅទាសៈរបស់ខ្លួនមក ឱ្យចំអិនអាហារតាមពេញចិត្ត



www.elibraryofcambodia.org

ច្រើននេះមកហើយឬ ? ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះ មានភណ្ឌៈច្រើន មានបរិក្ខារច្រើន ព្រះអង្គ ព្រះសាស្ដាត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកមានភណ្ឌៈច្រើនពិតឬ ? ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិត ព្រះអង្គ។ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុ ហេតុអ្វី ទើបជាអ្នកមានភណ្ឌៈច្រើន តថាគតពោលគុណេ នៃភាពជាអ្នកប្រាថ្នាតិច ភាពជាអ្នកសន្ដោស ការស្ងប់ស្ងាត់ និងការប្រារព្ធសេចក្ដីព្យាយាមមិនមែនឬ។ ភិក្ខុនោះ បានស្ដាប់ព្រះតម្រាស់របស់ព្រះសាស្ដាហើយ ក៏ក្រោធ គិតថា ឥឡូវនេះ អញនឹងត្រាច់ទៅដោយទំនងនេះ ទើបចោលសំពត់ដណ្ដប់ មានចីវរមួយផ្ទាំង ឈរនៅកណ្ដាលបរិស័ទ។ លំដាប់នោះ ព្រះសាស្ដា កាលនឹងទ្រង់ឧបត្ថម្ភភិក្ខុនោះ ទើបត្រាស់ថា ម្នាលភិក្ខុ កាលមុន សូម្បីក្នុងកាលជាអារក្ខទឹក អ្នកស្វែងរកហិរិនិងឱត្តប្បៈអស់ ១២ ឆ្នាំ កាលបើដូច្នោះ ព្រោះហេតុអ្វី ឥឡូវនេះ អ្នកបួសក្នុងសាសនាដ៏ជាទីគោរពយ៉ាងនេះ ទើបចោលសំពត់ដណ្ដប់ នៅកណ្ដាលបរិស័ទ លះបង់ហិរិឱត្តប្បៈ នៅឈរហ៎។ ភិក្ខុនោះ



www.elibraryofcambodia.org

បានស្តាប់ព្រះតម្រាស់របស់ព្រះអង្គហើយ បានញ៉ាំងហិរិឱត្តប្បៈឱ្យតាំងឡើង ទើបដណ្តប់ចីវរនោះ ហើយថ្វាយបង្គំព្រះសាស្តាអង្គុយនៅក្នុងចំណែកម្ខាង ភិក្ខុទាំងឡាយ ទូលអារាធនាព្រះមានព្រះភាគ ដើម្បីញ៉ាំងរឿងនោះឱ្យជាក់ច្បាស់។ ព្រះមានព្រះភាគទ្រង់បានធ្វើហេតុដែលបិទដោយចន្លោះនៃភពឱ្យប្រាកដតទៅ :

ក្នុងអតីតកាល មានព្រះរាជាព្រះនាមថា ព្រហ្មទត្ត ក្នុងនគរពារាណសី ដែនកាសី។ ក្នុងកាលនោះ ព្រះពោធិសត្វបដិសន្ធិក្នុងព្រះគភ៌ របស់ព្រះអគ្គមហេសីនៃព្រះបាទព្រហ្មទត្តនោះ។ លុះគ្រប់ដប់ខែហើយ ព្រះនាងប្រសូតព្រះឱរស។ ក្នុងថ្ងៃប្រទានព្រះនាមរបស់ព្រះឱរសនោះ ព្រះញាតិទាំងឡាយបានតាំងព្រះនាមថា មហិសុរាសកុមារ ក្នុងកាលដែលព្រះកុមារនោះទ្រង់ចេះរត់លេងបាន ព្រះឱរសអង្គដទៃទៀតក៏ប្រសូត ព្រះញាតិទាំងឡាយប្រទានព្រះនាមព្រះឱរសនោះថា ចន្ទកុមារ។ ក្នុងពេលដែលព្រះចន្ទកុមារនោះទ្រង់ចេះរត់លេងបាន ព្រះមាតារបស់ព្រះពោធិសត្វក៏សោយទិវង្គត ព្រះរាជា ទ្រង់តាំងព្រះស្ត្រីដទៃទុកក្នុងតំណែងព្រះអគ្គ



www.elibraryofcambodia.org

មហេសី ។ ព្រះអគ្គមហេសីនោះ បានជាទីស្រឡាញ់ប្រោសប្រាណនៃព្រះរាជា ។ ព្រះអគ្គមហេសីនោះ ទ្រង់អាស្រ័យការនៅរួមគ្នា ក៏ប្រសូតព្រះឱរសមួយអង្គ ។ ព្រះញាតិទាំងឡាយបានតាំងព្រះនាមថា សុរិយកុមារ ។ ព្រះរាជាទ្រង់ឃើញព្រះឱរសហើយ មានព្រះទ័យត្រេកអរ ត្រាស់ថា នាងដ៏ចម្រើន យើងឱ្យពរដល់បុត្ររបស់នាង ។ ព្រះទេវីរក្សាទុក នឹងទទួលយកក្នុងវេលាត្រូវការពរនោះ ។ កាលព្រះឱរសចម្រើនវ័យហើយ ព្រះនាងក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ក្នុងកាលដែលព្រះឱរសរបស់ខ្ញុំម្ចាស់ប្រសូត ទ្រង់ប្រទានពរទុកមិនមែនឬ សូមព្រះអង្គប្រទានរាជសម្បត្តិដល់ព្រះឱរសរបស់ខ្ញុំម្ចាស់ ព្រះរាជាទ្រង់ហាមថា ព្រះឱរសទាំងពីព្រះអង្គរបស់យើងរុងរឿងដូចជាដុំភ្លើង យើងមិនអាចឱ្យរាជសម្បត្តិដល់ឱរសរបស់នាងឡើយ ទ្រង់យល់ឃើញព្រះនាងអង្វររឿយៗ ទ្រង់ព្រះតម្រិះថា ព្រះនាងនេះ នឹងគប្បីគិតនូវកម្មដ៏លាមកដល់ឱរសទាំងពីររបស់យើង ទើបបញ្ជាឱ្យហៅព្រះឱរសទាំងពីរមក ហើយត្រាស់ថា កូនទាំងពីរក្នុង ពេលដែលសុរិយកុមារប្រសូត បិតាបាន



www.elibraryofcambodia.org

ឱ្យពរដល់គេ ឥឡូវនេះ មាតារបស់សុរិយកុមារនោះ ទូលសុំរាជសម្បត្តិ បិតាមិនបំណេងនឹងឱ្យសុរិយកុមារនោះទេ ធម្មតា មាតុគ្រាម នឹងគប្បីគិតនូវរឿងដែលលាមកមកដល់ពួកកូន កូនទាំងពីរទៅកាន់ព្រៃចុះ កាលបិតាសោយទីវង្គតហើយ ចូរគ្រងរាជសម្បត្តិក្នុងនគរដែលជារបស់មាននៅក្នុងនគរ ហើយទ្រង់ព្រះកន្សែងសោយសោក ទ្រង់បញ្ជូនទៅ។ សុរិយកុមារទ្រង់លេងក្នុងព្រះលានហ្លួង ឃើញព្រះឱរសទាំងពីរនោះថ្វាយបង្គំព្រះរាជបិតា ហើយចុះអំពីប្រាសាទ ទ្រង់ឃើញហេតុនោះ ទើបគិតថា សូម្បីយើងក៏ទៅជាមួយម្ចាស់បងទាំងពីរ ទើបចេញទៅព្រមជាមួយនឹងព្រះឱរសទាំងពីរនោះឯង ព្រះឱរសទាំនោះស្ដេចចូលទៅកាន់ព្រៃហិមពាន្ត ។

ព្រះពោធិសត្វចេញអំពីផ្លូវ ប្រថាប់គង់ត្រង់គល់ឈើ ហើយទ្រង់ ហៅសុរិយកុមារមកថា ប្អូនសុរិយៈ ប្អូនទៅកាន់ស្រះនោះងូត និងសោយ ហើយចូរយកស្លឹកឈូកដាក់ទឹកមកឱ្យយើងទាំងពីរផង ស្រះនោះជាស្រះដែលមានអារក្ខទឹកមួយរូប បានពរអំពីសម្នាក់ស្ដេចវេស្សវ័ណ្ណ ត្រាស់នឹងអារក្ខទឹកនោះថា អ្នកនឹងបាន



www.elibraryofcambodia.org

បរិភោគអ្នកដែលចុះមកកាន់ស្រះទឹកនេះ វៀរតែអ្នកដែលចេះទេវធម៌ប៉ុណ្ណោះ អ្នកមិនអាចបរិភោគអ្នកដែលមិនបានចុះឡើយ តាំងពីពេលនោះមក ទើបអារក្សទឹកនោះសួរទេវធម៌នឹងអ្នកដែលចុះកាន់ស្រះនោះ ហើយស៊ីអ្នកដែលមិនចេះទេវធម៌ ។

លំដាប់នោះឯង សុរិយកុមារទៅកាន់ស្រះនោះ ចុះទៅដោយមិនបានពិចារណា ។ លំដាប់នោះ អារក្សទឹកចាប់សុរិយកុមារនោះ ហើយសួរថា អ្នកចេះទេវធម៌ឬ? សុរិយកុមារនោះ ពោលថា អើ ខ្ញុំចេះ ព្រះចន្ទ និងព្រះអាទិត្យ ឈ្មោះថា ទេវធម៌ លំដាប់នោះទើបអារក្សទឹកពោលនឹងសុរិយកុមារនោះថា លោកមិនស្គាល់ទេវ-ធម៌ឡើយ ហើយក៏នាំទៅលាក់ទុកកន្លែងរបស់ខ្លួន ។

ឯព្រះពោធិសត្វចាំសុរិយកុមារបាត់យូរពេក ទើបប្រើចន្ទ-កុមារទៅ អារក្សទឹកក៏ចាប់ចន្ទកុមារនោះ ហើយសួរថា អ្នកចេះទេវធម៌ទេ? ចន្ទកុមារពោលថា ខ្ញុំចេះ ទិសទាំង ៤ ឈ្មោះថាទេវធម៌ ។ អារក្សទឹកពោលថា អ្នកមិនចេះទេវធម៌ទេ ហើយនាំចន្ទ-កុមារនោះ ទៅទុកឯទីកន្លែងនោះឯង ។



www.elibraryofcambodia.org

កាលចន្ទកុមារបាត់យូរ ព្រះពោធិសត្វគិតថា អន្តរាយនឹងគប្បីកើតមានដល់ប្អូនទាំងពីររបស់អញ ទើបទៅកាន់ស្រះនោះដោយព្រះអង្គឯង ឃើញដានជើងចុះទឹករបស់ព្រះអានុជទាំងពីរ ទើបព្រះអង្គត្រិះរិះថា ស្រះនេះ គង់ជាស្រះដែលអារក្ខទឹកហួងហែង ទើបស៊កព្រះខ័នកាន់ធ្នូ នៅឈរ អារក្ខឃើញព្រះពោធិសត្វមិនចុះទឹក ទើបបញ្ចេញសំឡេងដូចជាអ្នកធ្វើការងារនៅក្នុងព្រៃពោលនឹងព្រះពោធិសត្វថា អ្នកដំចម្រើន អ្នកនឿយហត់ហើយហេតុអ្វី ទើបអ្នកមិនចុះកាន់ស្រះនេះ ងូត ផឹក ទឹកបរិភោគមើមឈូក និងប្រដាប់ផ្កាឈើទៅតាមសប្បាយទៅ ។

ព្រះពោធិសត្វឃើញដូច្នោះ ដឹងថា អ្នកជាយក្ខ ទើបសួរថា លោកចាប់ប្អូនប្រុសរបស់យើងឬ ? អារក្ខទើបពោលថា អើ យើងចាប់មក។ ព្រះពោធិសត្វសួរថា ព្រោះហេតុអ្វី ? អារក្ខទើបពោលថា យើងតែងចាប់អ្នកដែលចុះមកកាន់ស្រះទឹកនេះ ។ ព្រះពោធិសត្វសួរថា លោកចាប់ទាំងអស់តែម្តងឬ ? អារក្ខនិយាយថា យើងចាប់ទាំងអស់ វៀរតែអ្នកចេះទេវធម៌ប៉ុណ្ណោះ។



www.elibraryofcambodia.org

ព្រះពោធិសត្វត្រាស់សួរថា លោកត្រូវការឬ ? អារក្ខទឹកពោលថា អើ យើងត្រូវការ ។ ព្រះពោធិសត្វត្រាស់ថា បើដូច្នោះយើងនឹងសម្តែងទេវធម៌ដល់លោក ។ អារក្ខទឹកពោលថា បើដូច្នោះលោកចូរសម្តែង យើងនឹងស្តាប់ទេវធម៌ ។

ព្រះពោធិសត្វត្រាស់ថា តែយើងមានខ្លួនមិនស្អាត ទើបយក្ខឱ្យព្រះពោធិសត្វងូតទឹក ឱ្យផឹកទឹក ហើយប្រដាប់ផ្កាឈើ និងលាបលនដោយគ្រឿងក្រអូប បានរៀបបល្ល័ង្កឱ្យកណ្តាលបារាំដែលប្រដាប់ហើយ ។ ព្រះពោធិសត្វប្រថាប់លើអាសនៈ ឱ្យយក្ខអង្គុយទាបជិតអាសនៈ ហើយត្រាស់ថា បើដូច្នោះ លោកចូរផ្ទៀងសោតាស្តាប់ព្រះធម៌ដោយគោរពចុះ ទើបព្រះពោធិសត្វ ត្រាស់នូវព្រះគាថានេះថា :

**សប្បុរសអ្នកមានចិត្តស្ងប់រម្ងាប់ បរិបូណ៌ដោយ**
**ហិរិ និងឱត្តប្បៈ តាំងមាំហើយក្នុងធម៌ស លោក**
**ពោលថា អ្នកមានទេវធម៌ក្នុងលោក ។**



www.elibraryofcambodia.org

បណ្តាបទទាំងនេះបទថា **ហិរិឱត្តប្បសម្បន្នា** ប្រែថា អ្នកប្រកបដោយហិរិ និងឱត្តប្បៈ បណ្តាហិរិ និងឱត្តប្បៈទាំងនោះ ដែលឈ្មោះថា ហិរិ ព្រោះខ្មាសចំពោះកាយទុច្ចរិតជាដើម ពាក្យថា ហិរិ នេះ ជាឈ្មោះនៃការខ្មាស ។ ដែលឈ្មោះថា ឱត្តប្បៈ ព្រោះខ្លាចចំពោះកាយទុច្ចរិតជាដើមនោះឯង ពាក្យថា ឱត្តប្បៈនេះ ជាឈ្មោះនៃការខ្លាចចំពោះបាប បណ្តា ហិរិ និងឱត្តប្បៈនោះ ហិរិ មានសមុដ្ឋានតាំងឡើងខាងក្នុង ឱត្តប្បៈ មានសមុដ្ឋានតាំងឡើងខាងក្រៅ ហិរិ មានខ្លួនជាធំ ឱត្តប្បៈ មានលោកជាធំ ហិរិតាំងនៅក្នុងសភាវៈដែលគួរខ្មាស ឱត្តប្បៈតាំងនៅក្នុងសភាវៈដែលគួរខ្លាច ហិរិ មានលក្ខណៈកោតក្រែង ឱត្តប្បៈ មានលក្ខណៈឃើញទោស និងភ័យ ។

បណ្តាហិរិ និងឱត្តប្បៈនោះ បុគ្គលតែងញុំាងហិរិដែលមានសមុដ្ឋានជាខាងក្នុង ឱ្យតាំងឡើងដោយហេតុ ៤ ប្រការ ព្រោះពិចារណាដល់ជាតិកំណើត ១ ពិចារណាដល់វ័យ ១ ពិចារណាដល់សេចក្តីក្លៀវក្លា ១ ពិចារណាដល់ភាពជាពហុស្សូត ១ ។



www.elibraryofcambodia.org

ពិចារណាដូចម្ដេច ? បុគ្គលពិចារណាដល់ជាតិកំណើតដូច្នេះថា ឈ្មោះថា ការធ្វើបាបនេះ មិនជាកម្មនៃអ្នកដែលបរិបូណ៌ដោយជាតិ ជាកម្មរបស់អ្នកមានជាតិថោកទាប មានព្រានជាដើមគប្បីធ្វើ បុគ្គលអ្នកបរិបូណ៌ដោយជាតិ មិនគួរនឹងធ្វើកម្មនេះ ហើយមិនធ្វើបាប មានបាណាតិបាតជាដើម ឈ្មោះថា ញ៉ាំងហិរិឱ្យកើតឡើង ។

ម្យ៉ាងទៀត បុគ្គលពិចារណាដល់វ័យយ៉ាងនេះថា ឈ្មោះថា ការធ្វើបាបនេះ ជាកម្មដែលមនុស្សតូចៗ គប្បីធ្វើ កម្មនេះ លោកអ្នកដែលតាំងនៅក្នុងវ័យដូច្នេះមិនគួរធ្វើ ហើយមិនគួរធ្វើបាប មានបាណាតិបាតជាដើម ឈ្មោះថា រញ៉ាំងហិរិឱ្យតាំងឡើង ។

ម្យ៉ាងទៀត បុគ្គលពិចារណាដល់ភាពជាអ្នកក្លៀវក្លាយ៉ាងនេះថា ឈ្មោះថា ការធ្វើបាបនេះ ជាកម្មរបស់មនុស្សដែលមានជាតិអន់ថយ កម្មនេះ បុគ្គលដែលបរិបូណ៌ដោយភាពក្លៀវក្លាដូច្នេះ លោកមិនធ្វើឡើយ ហើយមិនធ្វើបាប មានបាណាតិបាតជាដើម ឈ្មោះថា ជាអ្នកញ៉ាំងហិរិឱ្យកើតឡើង ។

ម្យ៉ាងទៀត បុគ្គលអ្នកពិចារណាដល់ភាពជាពហុស្សូតយ៉ាង



www.elibraryofcambodia.org

នេះថា ឈ្មោះថា ការធ្វើបាបនេះ ជាកម្មរបស់មនុស្សពាល កម្ម នេះ បុគ្គលជាពហូសូត ជាបណ្ឌិត លោកមិនគប្បីធ្វើ ហើយមិនធ្វើ បាប មានបាណាតិបាតជាដើម ឈ្មោះថា ញ៉ាំងហិរិឱ្យតាំងឡើង បុគ្គល ឈ្មោះថា ញ៉ាំងហិរិដែលមានសមុដ្ឋានខាងក្នុងឱ្យកើតឡើង ដោយហេតុ ៤ ប្រការ ដូច្នេះ ។ លុះឱ្យតាំងឡើងហើយ ញ៉ាំង ហិរិឱ្យចូលទៅក្នុងចិត្ត មិនធ្វើបាប ហិរិ ឈ្មោះថា មានសមុដ្ឋាន ខាងក្នុងដូច្នេះ ។

ឱត្តប្បៈ ឈ្មោះថា មានសមុដ្ឋានខាងក្រៅដូចម្តេច ? បុគ្គល ពិចារណាថា បើលោកនឹងធ្វើបាបសោត លោកនឹងជាអ្នកត្រូវ តិះដៀលក្នុងបរិស័ទទាំង ៤ និងថា

**វិញ្ញូជនទាំងឡាយ នឹងតិះដៀលអ្នក ដូចអ្នក ក្រុងតិះដៀលរបស់មិនស្អាត ម្នាលភិក្ខុ លោកអ្នក មានសីលទាំងឡាយ វៀរឆ្ងាយហើយ លោកនឹង ធ្វើអ្វី** ដូច្នេះ ។



www.elibraryofcambodia.org

រមែងមិនធ្វើបាបកម្ម ព្រោះឱត្តប្បៈតាំងឡើងខាងក្រៅ ឱត្តប្បៈ ឈ្មោះថាមានសមុដ្ឋានខាងក្រៅ ដូច្នេះ ។

ហិរិ ឈ្មោះថា មានខ្លួនជាធំដូចម្តេច ? កុលបុត្រពួកខ្លះក្នុងលោកនេះ ធ្វើខ្លួនឱ្យជាធំ ឱ្យជាប្រធាន មិនធ្វើបាប ដោយគិតថា បុគ្គលដែលបួសដោយសទ្ធា ជាពហូសូត មានវាទៈក្នុងការកម្ចាត់កិលេសដូចជាលោក មិនគួរធ្វើបាបកម្ម ហិរិ ឈ្មោះថា មានខ្លួនជាធំដូច្នេះ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា បុគ្គលនោះធ្វើខ្លួនឯងនុ៎ះឯងឱ្យជាធំ លះអកុសល ចម្រើនកុសល លះធម៌ដែលមានទោស ចម្រើនធម៌ដែលមិនមានទោស រក្សាខ្លួនឱ្យត្រឹមត្រូវហ្មត់ចត់ ។

ឱត្តប្បៈ ឈ្មោះថា មានលោកជាធំដូចម្តេច ? កុលបុត្រពួកខ្លះក្នុងលោកនេះ ធ្វើលោកឱ្យជាធំ ជាប្រធាន ហើយមិនធ្វើបាបកម្ម សមដូចព្រះតម្រាស់ថា លោកសន្និវាសនេះធំកន្លង ម្យ៉ាងទៀត សមណព្រាហ្មណ៍ទាំងឡាយ អ្នកមានឫទ្ធិមាន មានទិព្វចក្ខុ ដឹងចិត្តរបស់អ្នកដទៃ នៅក្នុងលោកសន្និវាសនេះច្រើនក្រៃលែង



www.elibraryofcambodia.org

សមណព្រាហ្មណ៍ទាំងនោះ រមែងដឹងយើងដូច្នេះថា លោកដ៏ចម្រើន លោកទាំងឡាយចូរមើលកុលបុត្រនេះ គេមានសទ្ធាចេញចាកផ្ទះ បួសជាបព្វជិត ខ្លាចដោយអកុសលធម៌ដ៏លាមក ទេវតាទាំងឡាយ ដែលមានឫទ្ធិ មានទិព្វចក្ខុ ដឹងនូវចិត្តរបស់អ្នកដទៃមាន ទេវតាទាំង នោះ រមែងឃើញដល់ទីជិតខ្លះ ទីឆ្ងាយខ្លះ តែងដឹងចិត្តដោយចិត្តខ្លះ សូម្បីទេវតាទាំងនោះក៏ដឹងថា លោកដ៏ចម្រើន លោកទាំងឡាយចូរ មើលកុលបុត្រនេះ គេមានសទ្ធាចេញចាកផ្ទះ បួសជាបព្វជិត ខ្លាច ដោយអកុសលធម៌ដ៏លាមក គេធ្វើលោកនោះឯងឱ្យជាធំ លះអកុសល ចម្រើនកុសល លះធម៌ដែលមានទោស ចម្រើនធម៌ដែលមិនមាន ទោស រក្សាខ្លួនឱ្យល្អហ្មត់ចត់ ឱត្តប្បៈ ឈ្មោះថា មានលោកជាធំ ដូច្នេះ ។

ក្នុងពាក្យថា ហិរិតាំងនៅក្នុងសភាវៈគួរខ្មាស ឱត្តប្បៈ តាំងនៅក្នុងសភាវៈគួរខ្លាច នេះ មានវិនិច្ឆ័យដូចតទៅនេះ :

អាការខ្មាស ឈ្មោះថា ការខ្មាស ហិរិតាំងនៅដោយសភាវៈ នោះ ការខ្លាចចំពោះអបាយ ឈ្មោះថា ភ័យ ឱត្តប្បៈតាំងនៅដោយ



www.elibraryofcambodia.org

សភាវៈនោះ។ ហិរិ និងឱត្តប្បទាំងពីរនោះ រមែងប្រាកដក្នុងការវៀរចាកបាប ពិតណាស់ បុគ្គលខ្លះឈានចុះកាន់ធម៌ គឺការខ្មាសដែលជាខាងក្នុង មិនធ្វើបាបកម្ម ដូចជាកុលបុត្រកាលនឹងបន្ទោបង់ឧច្ចារបស្សាវៈជាដើម ឃើញមនុស្សដែលគួរខ្មាស គប្បីជាអ្នកដល់នូវអាការខ្មាស មិនអាចឧច្ចារបស្សាវៈបាន ដូច្នោះ បុគ្គលពួកខ្លះខ្លាចភ័យក្នុងអបាយ ទើបមិនធ្វើបាបកម្ម ក្នុងសេចក្តីនេះ មានការឧបមាដូចតទៅនេះ :

ឧទាហរណ៍ ក្នុងដុំដែក ២ ដុំ មួយដុំត្រជាក់ តែប្រឡាក់លាមក មួយដុំទៀតក្តៅ ។ ដែកទាំងពីរដុំនោះ បណ្ឌិតខ្ពើមមិនចាប់ដុំត្រជាក់ព្រោះប្រឡាក់លាមក មិនចាប់ដុំដែលក្តៅ ព្រោះខ្លាចរលាក យ៉ាងណា។ ក្នុងសេចក្តីដែលពោលដោយហិរិ និងឱត្តប្បៈក៏ដូច្នោះ គប្បីជ្រាបការឈានចុះកាន់លជ្ជីធម៌ ដែលជាចំណែកខាងក្នុង ហើយមិនធ្វើបាបកម្ម ដូចបណ្ឌិតខ្ពើមដុំដែកត្រជាក់ដែលប្រឡាក់លាមក ទើបមិនចាប់ ហើយគប្បីជ្រាបថាការមិន



www.elibraryofcambodia.org

ធ្វើបាប ព្រោះខ្លាចភ័យក្នុងអបាយ ដូចបណ្ឌិតដែលមិនចាប់ដុំដែកក្តៅ ព្រោះខ្លាចរលាកដូច្នេះ ។

បទទាំងពីរនេះ ដែលថា ហិរិមានលក្ខណៈកោតក្រែងឱត្តប្បៈមានលក្ខណៈខ្លាចទោស និងឃើញភ័យ ដូច្នេះ រមែងប្រាកដក្នុងការវៀរចាកបាបប៉ុណ្ណោះ ។ ពិតណាស់ អ្នកខ្លះញ៉ាំងហិរិដែលមានលក្ខណៈកោតក្រែងឱ្យកើតឡើងដោយហេតុ ៤ ប្រការ គឺពិចារណាដល់ភាពជាធំដោយជាតិ ១ ពិចារណាដល់ភាពជាធំនៃព្រះសាស្តា ១ ពិចារណាដល់ភាពជាធំដោយទ្រព្យមតិក ១ និងពិចាណាដល់ភាពជាធំនៃសព្រហ្មចារី ១ ហើយ ទើបមិនធ្វើបាប ។

អ្នកខ្លះញ៉ាំងឱត្តប្បៈ ដែលមានលក្ខណៈខ្លាចទោស និងឃើញភ័យឱ្យតាំងឡើងដោយហេតុ ៤ ប្រការ គឺភ័យក្នុងការតិះដៀលខ្លួន ១ ភ័យក្នុងការដែលអ្នកដទៃតិះដៀល ១ ភ័យពីអាជ្ញា ១ និងភ័យក្នុងទុគ្គតិ ១ ហើយមិនធ្វើបាប ក្នុងប្រការដែលពោលដោយហិរិឱត្តប្បៈនោះ គប្បីពិចារណាភាពជាធំដោយជាតិ និងភ័យក្នុងការតិះដៀលខ្លួនជាដើមឱ្យពិស្តារ សេចក្តីពិស្តារនៃការពិចារណា



www.elibraryofcambodia.org

ភាពជាធំដោយជាតិជាដើមនោះ បានពោលទុកហើយក្នុងអដ្ឋកថាអង្គុត្តរនិកាយ ។

បទថា **សុក្កធម្មសមាហិតា** សេចក្ដីថា កុសលធម៌ដែលគួរធ្វើ មានហិរិឱត្តប្បៈនេះឯងជាដើម ឈ្មោះថា កុសលធម៌ ធម៌ស កាលពោលដោយន័យដែលរួមយកទាំងអស់ កុសលធម៌នោះ គឺធម៌ដែលជាលោកិយ និងលោកុត្តរដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដែលប្រកបព្រមហើយ ដោយហិរិឱត្តប្បៈទាំងពីរនោះ។ បទថា **សន្តោ សប្បុរិសា លោកេ** សេចក្ដីថា ឈ្មោះថា អ្នកស្ងប់រម្ងាប់ ព្រោះកាយកម្មជាដើមស្ងប់រម្ងាប់ហើយ ឈ្មោះថា ជាសប្បុរស ព្រោះជាបុរសដែលប្រព្រឹត្តល្អ ដោយកតញ្ញូកតវេទី ។

ក្នុងបទថា **លោកេ** នេះ លោកមានច្រើន លោក គឺសង្ខារលោក សត្វលោក ឱកាសលោក ខន្ធលោក អាយតនលោក និងធាតុលោក។ ក្នុងលោកទាំងនោះ សង្ខារលោក លោកពោលទុកក្នុងប្រយោគនេះថា លោកមួយ គឺសត្វទាំងពួងតាំងនៅបានដោយអាហារ ។ល។ លោក ១៨ គឺធាតុ ១៨ ។ លោក មានខន្ធលោក



www.elibraryofcambodia.org

ជាដើមរួមទៅក្នុងសង្ខារលោកនេះឯង ។ ឯសត្វលោក លោកពោល ទុកក្នុងប្រយោគជាដើមថា លោកនេះ លោកខាងមុខ ទេវលោក មនុស្សលោក ។

ឱកាសលោក លោកពោលទុកក្នុងប្រយោគនេះថា :

**មួយពាន់លោកធាតុ មានប្រមាណ ដែលព្រះចន្ទ និងព្រះអាទិត្យ ជះពន្លឺទៅគ្រប់ទិស អំណាចរបស់ព្រះអង្គ រមែងផ្សាយទៅក្នុងពាន់លោកធាតុនោះ ។**

បណ្តាលោកទាំងនោះ ក្នុងទីនេះ បំណងយកសត្វលោក ពិតណាស់ សត្វលោកប៉ុណ្ណោះ មានសប្បុរសដូច្នេះ សប្បុរសទាំងនោះលោកពោលថា មានទេវធម៌ ។

បទថា ទេវ ក្នុងបទថា ទេវធម្មា នោះ ទេពមាន ៣ ប្រភេទ គឺសម្មតិទេព ១ ឧប្បត្តិទេព ១ និងវិសុទ្ធិទេព ១ បណ្តាទេពទាំងនោះ ព្រះរាជា និងព្រះរាជកុមារជាដើម ឈ្មោះថា សម្មតិទេព ព្រោះមនុស្សលោកសន្មតថា ជាទេព ចាប់ផ្តើមតាំងអំពីព្រះមហាសម្មតិរាជ ។ ទេវតាដែលឧប្បត្តិក្នុងទេវលោក ឈ្មោះ



www.elibraryofcambodia.org

ថា ឧប្បត្តិទេព ។ ព្រះខីណាស្រព ឈ្មោះថា វិសុទ្ធិទេព ។

សមពិតដូចដែលត្រាស់ទុកថា ព្រះរាជា ព្រះរាជទេវី ព្រះរាជកុមារ ឈ្មោះថា សម្មតិទេព, ទេពខ្ពស់ៗ តាំងពីភុម្មទេវតាឡើងទៅ ឈ្មោះថា ឧប្បត្តិទេព, ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រព ឈ្មោះថា វិសុទ្ធិទេព ។

ធម៌របស់ទេពទាំងនេះ ឈ្មោះថា ទេវធម៌ ។

បទថា *វុច្ចរេ* ប្រែថា រមែងពោល ពិតណាស់ កុសលធម៌ទាំងឡាយមានហិរិឱត្តប្បៈជាមូល ឈ្មោះថា ជាធម៌របស់ទេពទាំង ៣ ប្រភេទនេះ ព្រោះអត្ថថា ជាហេតុនៃកុសលសម្បទា នៃការកើតក្នុងទេវលោក និងសេចក្ដីល្អ ព្រោះហេតុនោះ ទើបឈ្មោះថា ទេវធម៌ សូម្បីបុគ្គលដែលប្រកបដោយទេវធម៌ទាំងនោះ ក៏ជាអ្នកមានទេវធម៌ ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងធម៌ទាំងនោះ ដោយទេសនាដែលជាបុគ្គលាធិដ្ឋាន ទើបត្រាស់ថា សប្បុរសអ្នកស្ងប់រម្ងាប់ ហៅថា អ្នកមានទេវធម៌ក្នុងលោក ។



www.elibraryofcambodia.org

អារក្ខទឹកលុះបានស្តាប់ធម៌ទេសនានេះ មានសេចក្តីជ្រះថ្លា ទើបពោលនឹងព្រះពោធិសត្វថា នែបណ្ឌិត យើងជ្រះថ្លាចំពោះលោក នឹងឱ្យប្អូនប្រុសម្នាក់ តើឱ្យនាំម្នាក់ណាមក ? ព្រះពោធិសត្វត្រាស់ថា លោកចូរនាំប្អូនប្រុសតូចមក។ អារក្ខទឹកពោលថា នែបណ្ឌិត លោកដឹងទេវធម៌តែម្យ៉ាងប៉ុណ្ណោះ តែមិនប្រព្រឹត្តក្នុងទេវធម៌ទាំងនោះ។ ព្រះពោធិសត្វត្រាស់សួរថា ព្រោះហេតុអ្វី ? អារក្ខទឹកពោលថា ព្រោះហេតុដែលលោកវៀរបងប្រុសចេញ ឱ្យនាំប្អូនប្រុសមក ឈ្មោះថា មិនធ្វើកម្ម គឺការគោរពរាប់អានចំពោះអ្នកចម្រើនទីបំផុត ព្រះបរមពោធិសត្វត្រាស់ថា ម្នាលយក្ខ យើងដឹងទេវធម៌ និងប្រព្រឹត្តក្នុងទេវធម៌ទាំងនោះ ព្រោះថា យើងទាំងឡាយចូលមកព្រៃ ព្រោះអាស្រ័យប្អូនប្រុសរបស់ខ្ញុំនេះ ព្រោះថា ព្រះមាតារបស់ប្អូនប្រុសនេះ ទូលសូមរាជសម្បត្តិនឹងបិតារបស់ពួកយើង ដើម្បីប្រយោជន៍ដល់ប្អូនប្រុសនេះ តែព្រះបិតារបស់ពួកយើងមិនឱ្យពរនោះ ដើម្បីនឹងទ្រង់រក្សាពួកយើង ទើបទ្រង់អនុញ្ញាតឱ្យនៅក្នុងព្រៃ ព្រះកុមារនោះតាមមកជាមួយនឹងពួកយើង។ ទោះជាពួកយើងពោលថា យក្ខក្នុងព្រៃនឹងស៊ីព្រះរាជកុមារហើយយ៉ាង



www.elibraryofcambodia.org

នេះ មិនជឿនរណា១ ឡើយ ដោយហេតុនោះ យើងខ្លាចដល់ភ័យ ពីការតិះដៀល ទើបឱ្យនាំប្អូនប្រុសតូចនោះឯងមក ។ យក្ខមានចិត្ត ជ្រះថ្លាឱ្យសាធុការដល់ព្រះពោធិសត្វថា សាធុ សាធុ លោកជា បណ្ឌិត លោកចេះទេវធម៌ ទាំងបដិបត្តិក្នុងទេវធម៌នោះ ដូច្នេះ ហើយ ទើបនាំប្អូនប្រុសទាំងពីរនាក់មកឱ្យ ។ លំដាប់នោះ ព្រះ បរមពោធិសត្វត្រាស់នឹងអារក្ខទឹកនោះថា សម្លាញ់ លោកកើតជា អារក្ខទឹក មានសាច់ និងឈាមរបស់អ្នកដទៃមកជាអាហារ ព្រោះ បាបកម្មដែលខ្លួនធ្វើទុកក្នុងជាតិមុន ឥឡូវនេះ លោកធ្វើបាបនោះ ថែមទៀតឬ ? ដោយសារបាបកម្ម នឹងមិនឱ្យផុតអំពីនរកជាដើម ព្រោះដូច្នោះ ពីថ្ងៃនេះទៅ លោកចូរលះបង់អំពើបាប ហើយធ្វើតែ កុសល ។ បានឱ្យអារក្ខនោះតាំងនៅក្នុងសីល ៥ ។

ព្រះពោធិសត្វកាលញ៉ាំងអារក្ខទឹកនោះ ឱ្យតាំងនៅក្នុងអំពើ ល្អហើយ ក៏ជាអ្នកអារក្ខទឹកនោះត្រូវថែរក្សានៅក្នុងទីនោះឯង ។ ថ្ងៃមួយ ព្រះពោធិសត្វមើលនក្ខត្តឫក្ស ដឹងថា ព្រះជនកសោយ ទិវង្គត ទើបនាំអារក្ខទឹកទៅកាន់ក្រុងពារាណសី ទទួលយករាជ-សម្បត្តិ ប្រទានតំណែងឧបរាជដល់ព្រះចន្ទកុមារ ប្រទានតំណែង



www.elibraryofcambodia.org

សេនាបតីដល់សុរិយកុមារ ឱ្យសាងកន្លែងនៅគួរជាទីរីករាយឱ្យដល់អារក្សទឹក ទ្រង់បានធ្វើដោយប្រការផ្សេងៗ ដល់អារក្ខទឹកនោះ ដោយបូជាដ៏ប្រសើរ ដូចជាបានបូជា កម្រងផ្កាដ៏ប្រសើរ គ្រឿងក្រអូបដ៏ប្រសើរ ផ្លែឈើដ៏ប្រសើរ ភត្តដ៏ប្រសើរ ។ ព្រះ-ពោធិសត្វគ្រងរាជសម្បត្តិដោយធម៌ ស្តេចបានទៅតាមយថាកម្ម ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈ ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់បន្តអនុសន្ធិ ហើយទ្រង់ប្រជុំជាតកថា អារក្សទឹកក្នុងកាលនោះ បានជាភិក្ខុអ្នកមានភណ្ឌៈច្រើន ក្នុងកាលឥឡូវនេះ សុរិយកុមារបានជាព្រះអានន្ទ ចន្ទកុមារបានជាព្រះសារីបុត្រ ឯមហិសុរាសកុមារជាជេដ្ឋា គឺជាតថាគត ។

**ទេវធម្មជាតកទី ៦ ចប់**



www.elibraryofcambodia.org

## កដ្ឋហារិជាតកទី ៧

បុត្តោ ត្យាហំ មហារាជ
ត្វំ មំ បោស ជនាធិប
អញ្ញេបិ ទេវោ បោសេតិ
កិញ្ច ទេវោ សកំ បជន្តិ។

( ព្រះរាជកុមារពោធិសត្វពោលថា ) បពិត្រមហារាជ ខ្ញុំជាបុត្ររបស់ព្រះអង្គ បពិត្រព្រះអង្គជាធំជាងពួកជន សូមព្រះអង្គចិញ្ចឹមខ្ញុំផង ព្រះសម្មតិទេពទ្រង់ចិញ្ចឹមពួកជនដទៃបាន ម្តេចព្រះសម្មតិទេពក៏មិនចិញ្ចឹមសត្វ ដែលជាបុត្ររបស់ព្រះអង្គផង ។



www.elibraryofcambodia.org

# អដ្ឋកថា ភទ្ទសាលជាតក

ព្រះសាស្តា កាលគង់ប្រថាប់នៅក្នុងជេតពនមហាវិហារ ទ្រង់ប្រារព្ធព្រះនាងវាសភខត្តិយា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **បុត្តោ ត្យាហំ មហារាជ** ជាដើម ។

រឿងព្រះនាងវាសភខត្តិយា នឹងមានជាក់ច្បាស់ក្នុង ភទ្ទ-សាលជាតក ទ្វាទសកនិបាត។ បានឮថា ព្រះនាងវាសភខត្តិយា ជាព្រះធីតារបស់សក្យមហានាម ប្រសូតក្នុងគភ៌របស់ទាសីឈ្មោះ **នាគមណ្ឌា** (តមក) បានជាព្រះអគ្គមហេសីរបស់ព្រះបាទកោសល ព្រះនាងប្រសូតព្រះរាជឱរស។ ខាងក្រោយមក ព្រះរាជាទ្រង់ជ្រាបថា ព្រះនាងជាទាសី ទើបទ្រង់ដកពីតំណែង សូម្បីវិឌូឌភៈ ជាព្រះរាជឱរសក៏ត្រូវដកពីតំណែងដូចគ្នា ។ ម៉ែកូនទាំងពីរក៏នៅក្នុងព្រះរាជនិវេសន៍របស់ព្រះរាជានោះឯង ។

ព្រះសាស្តា ទ្រង់ជ្រាបហេតុនោះ លុះដល់វេលាល្ងាច ទ្រង់ហែហាមដោយភិក្ខុ ៥០០ រូប យាងទៅកាន់រាជនិវេសន៍របស់ព្រះ



www.elibraryofcambodia.org

រាជា ទ្រង់ប្រថាប់លើអាសនៈដែលក្រាលទុក ហើយត្រាស់ថា ព្រះនាងវាសភខត្តិយា ប្រថាប់នៅទីណា។ ទើបព្រះរាជាក្រាបទូលហេតុនោះឱ្យទ្រង់ជ្រាប ព្រះសាស្តាត្រាស់សួរថា មហាបពិត្រ ព្រះនាងវាសភខត្តិយាជាធីតារបស់អ្នកណា ? ព្រះរាជាទូលថា នាងជាធីតារបស់ព្រះមហានាមព្រះអង្គ។ ព្រះសាស្តាត្រាស់សួរថា កាលព្រះនាងវាសភខត្តិយាស្តេចមក១ ហើយដើម្បីនរណា ? ព្រះរាជាក្រាបទូលថា ដើម្បីខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា មហាបពិត្រព្រះនាងវាសភខត្តិយានេះ ជាធីតារបស់ព្រះរាជា ហើយមកដើម្បីព្រះរាជា ព្រោះអាស្រ័យព្រះរាជានោះឯង ទើបបានព្រះឱរសព្រោះហេតុអ្វី ទើបព្រះឱរសនោះមិនបានជាម្ចាស់របស់រាជសម្បត្តិដែលជារបស់ព្រះរាជបិតា ព្រះរាជាក្នុងកាលមុន បានព្រះឱរសក្នុងគភ៌របស់ស្ត្រីរកឧសជាភរិយា ពេលខ្លះ ក៏បានព្រះរាជទានរាជសម្បត្តិដល់ព្រះឱរស។ ព្រះរាជាទ្រង់អារាធនាឱ្យព្រះមានព្រះភាគត្រាស់រឿងនេះឱ្យជាក់ច្បាស់។ ព្រះមានព្រះភាគទ្រង់បានធ្វើហេតុដែលបិទបាំងដោយចន្លោះនៃភព ឱ្យប្រាកដ ។



www.elibraryofcambodia.org

ក្នុងអតីកាល ព្រះរាជាព្រះនាមថា ព្រហ្មទត្ត ក្នុងក្រុងពារាណសី ស្តេចយាងទៅកាន់ព្រះឧទ្យានដោយព្រះយសដ៏ធំ ស្តេចត្រាច់ទៅព្រះរាជឧទ្យាននោះ ព្រោះទ្រង់ត្រេកអរផ្កាឈើ និងផ្លែឈើ ទ្រង់ឃើញស្ត្រីម្នាក់ទៅកាប់ឧសក្នុងព្រៃមិនឆ្ងាយពីព្រះរាជឧទ្យាន ទ្រង់មានចិត្តប្រតិព័ទ្ធនឹងស្ត្រីនោះ ទើបទ្រង់សម្រេចកាមនៅរួមគ្នាក្នុងខណៈនោះឯង ព្រះពោធិសត្វបដិសន្ធិក្នុងគភ៌របស់ស្ត្រីនោះ ភ្លាមនោះគភ៌របស់នាងធំឡើងតាមលំដាប់ ដូចដុំពេជ្រ។ នាងដឹងថា នាងតាំងគភ៌ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់តាំងគភ៌ហើយ ព្រះរាជាបានប្រទានព្រះទម្រង់ ហើយត្រាស់ថា បើជាធីតា នាងចូរចំណាយព្រះទម្រង់ចិញ្ចឹមចុះ តែបើជាបុត្រា នាងចូរនាំមកកាន់សម្នាក់របស់យើងព្រមជាមួយនឹងព្រះទម្រង់នេះផង កាលត្រាស់ហើយ ទើបស្តេចចៀសចេញទៅ ចំណែកស្ត្រីនោះ មានគភ៌គ្រប់ខែហើយ ក៏ប្រសូតព្រះពោធិសត្វ ក្នុងវេលាដែលព្រះពោធិសត្វនោះ រត់លេងក្នុងទីធ្លា មានមនុស្សពោលយ៉ាងនេះថា ពួកយើងត្រូវមនុស្សមិនមានឪពុកវាយហើយ



www.elibraryofcambodia.org

ព្រះពោធិសត្វបានស្តាប់ពាក្យគេថាដូច្នោះ ទើបទៅរកមាតាហើយសួរថា អ្នកម៉ែ នរណាជាឪពុករបស់កូន ?

មាតាពោលថា កូនអើយ ឪពុករបស់កូន គឺព្រះបាទពារាណសី ព្រះពោធិសត្វពោលថា តើមានអ្វីជាភស្តុតាង មាតាពោលថា កូនអើយ ព្រះរាជាប្រទានចិញ្ចៀននេះទុកឱ្យ ហើយត្រាស់ថា បើជាធីតា គប្បីចំណាយចិញ្ចៀននេះចិញ្ចឹមចុះ តែបើជាបុត្រា គប្បីនាំមកជាមួយចិញ្ចៀននេះ ត្រាស់ដូច្នេះស្តេចក៏ចេញទៅ ។

ព្រះពោធិសត្វពោលថា ម៉ែ កាលបើដូច្នោះ ហេតុអ្វី ទើបម៉ែមិននាំខ្ញុំទៅកាន់សម្នាក់របស់ព្រះបិតា នាងដឹងអធ្យាស្រ័យរបស់បុត្រ ទើបទៅកាន់ខ្លោងទ្វារព្រះរាជវាំង ឱ្យមនុស្សក្រាបទូលដល់ព្រះរាជាឱ្យទ្រង់ជ្រាប ព្រះរាជាបញ្ជាឱ្យចូលគាល់ ទើបចូលទៅថ្វាយបង្គំព្រះរាជា ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេពនេះជាឱរសរបស់ព្រះអង្គ ព្រះរាជាទ្រង់ជ្រាប ទ្រង់ខ្មាស ព្រោះនៅកណ្តាលប្រជុំជន ទើបត្រាស់ថា មិនមែនបុត្ររបស់យើងទេ ស្ត្រីនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព នេះព្រះទម្រង់របស់



www.elibraryofcambodia.org

ព្រះអង្គ ព្រះអង្គគង់នឹងទ្រង់ចាំព្រះទម្រង់នេះបាន ព្រះរាជាទ្រង់ត្រាស់ថា សូម្បីព្រះទម្រង់នេះ ក៏មិនមែនព្រះទម្រង់របស់យើងដែរ ។ ស្ត្រីនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ឥឡូវនេះវៀរសច្ចកិរិយាចេញហើយ មនុស្សដទៃជាសាក្សីរបស់ខ្ញុំម្ចាស់មិនមាន បើទារកនេះ កើតព្រោះអាស្រ័យព្រះអង្គហើយ ខ្ញុំម្ចាស់គ្រវែងឡើងទៅហើយ ចូរនៅលើអាកាស បើមិនអាស្រ័យព្រះអង្គកើត ចូរធ្លាក់ចុះមកស្លាប់លើផែនដី ហើយចាប់ជើងទាំងពីររបស់ព្រះ-ពោធិសត្វគ្រវែងទៅលើអាកាស ។ ព្រះពោធិសត្វអង្គុយលើបល្ល័ង្កក្នុងអាកាស កាលនឹងពោលធម៌ដល់ព្រះបិតាដោយសំឡេងដ៏ពីរោះ ទើបត្រាស់ព្រះគាថានេះថា :

> បពិត្រមហារាជ ខ្ញុំជាបុត្ររបស់ព្រះអង្គ បពិត្រព្រះអង្គជាធំជាងពួកជន សូមព្រះអង្គចិញ្ចឹមខ្ញុំផង ព្រះសម្មតិទេពទ្រង់ចិញ្ចឹមពួកជនដទៃបាន ម្តេចព្រះសម្មតិទេពក៏មិនចិញ្ចឹមសត្វ ដែលជាបុត្ររបស់ព្រះអង្គផង ។



www.elibraryofcambodia.org

បណ្ដាបទទាំងនេះ បទថា **បុត្តោ ត្យាហំ** កាត់បទជា **បុត្តោ តេ អហំ** ប្រែថា ខ្ញុំជាឱរសរបស់ព្រះអង្គ។ ឈ្មោះថា បុត្រនេះ មាន ៤ ប្រភេទ គឺបុត្រដែលកើតក្នុងខ្លួន ១ បុត្រដែលកើតក្នុងដែន ១ អន្តេវាសិកជាសិស្ស ១ និងបុត្រគេឱ្យ ១ ។

បណ្ដាបុត្រទាំង ៤ ប្រភេទនោះ អ្នកអាស្រ័យខ្លួនកើត ឈ្មោះថា បុត្រកើតក្នុងខ្លួន។ បុត្រដែលកើតក្នុងទីទាំងឡាយ មាន លើកន្លែងដេក លើបល្ល័ង្ក និងត្រង់ទ្រូងឈ្មោះថា បុត្រកើតក្នុងដែន។ បុគ្គលដែលរៀនសិល្បសាស្ត្រក្នុងសម្នាក់ ឈ្មោះថា កូនសិស្ស។ បុត្រដែលគេឱ្យមកចិញ្ចឹម ឈ្មោះថា បុត្រដែលគេឱ្យ គឺបុត្រធម៌ តែក្នុងទីនេះ លោកសំដៅយកបុត្រ ដែលកើតក្នុងខ្លួន ទើបពោលថា បុត្រ ។

ដែលឈ្មោះថា ព្រះរាជា ព្រោះធ្វើជនឱ្យត្រេកអរដោយសង្គហវត្ថុ ៤ ។ ព្រះរាជាដែលជាធំ ឈ្មោះថា មហារាជា ព្រះពោធិសត្វ កាលនឹងត្រាស់ហៅព្រះរាជានោះ ទើបត្រាស់ថា មហារាជ បពិត្រព្រះរាជាដ៏ធំ ។



www.elibraryofcambodia.org

បទថា **ត្វំ មំ ទោស ជនាធិប** សេចក្តីថា បពិត្រព្រះអង្គជាធំក្នុងពួកមហាជន សូមព្រះអង្គចិញ្ចឹម គឺសូមចិញ្ចឹមខ្ញុំព្រះអង្គផងចុះ ។ **អញ្ញេបិ ទេវោ ពោសេតិ** សេចក្តីថា ជនជាច្រើនពួកដទៃ បានដល់ ពួកមនុស្សអ្នកចិញ្ចឹមដំរីជាដើម និងសត្វតិរច្ឆានមានដំរី និងសេះជាដើមព្រះអង្គចិញ្ចឹមបាន ។ សព្ទថា **កិញ្ចា** ក្នុងបទថា **កិញ្ចា ទេវោ សកំ បជំ** នេះ ជាសព្ទនិបាត ប្រើក្នុងន័យថា តិះដៀល និងន័យថា អនុគ្រោះ ។ ព្រះពោធិសត្វទ្រង់ឱ្យឱវាទថា ប្រជាជនរបស់ព្រះអង្គ គឺខ្ញុំព្រះអង្គជាឱរសរបស់ព្រះអង្គ ព្រះអង្គទ្រង់មិនចិញ្ចឹម ដូច្នេះ ឈ្មោះថា រមែងតិះដៀល ។ ទើបត្រាស់ថា មនុស្សដទៃជាច្រើន ព្រះអង្គចិញ្ចឹមបាន ដូច្នេះ ឈ្មោះថា រមែងអនុគ្រោះ ។ ដូច្នោះ ព្រះពោធិសត្វ កាលទ្រង់នឹងតិះដៀល ទើបត្រាស់ថា ម្តេចមិនទ្រង់ចិញ្ចឹមបុត្ររបស់ព្រះអង្គផង ។

ព្រះពោធិសត្វ កាលប្រថាប់គង់លើអាកាស សម្តែងធម៌យ៉ាងនេះ ព្រះរាជាទ្រង់បានស្តាប់ហើយ ទើបទ្រង់លាតព្រះហស្ត



www.elibraryofcambodia.org

ត្រាស់ថា ចូរមកចុះកូន យើងនឹងចិញ្ចឹមអ្នក មានដៃទាំងពាន់លាត មកហើយ ព្រះពោធិសត្វមិនចុះក្នុងដៃអ្នកដទៃ ចុះក្នុងព្រះហស្ត របស់ព្រះរាជាប៉ុណ្ណោះ ហើយប្រថាប់គង់លើភ្លៅ ព្រះរាជាទ្រង់ ប្រទានភាពជាឧបរាជដល់ព្រះពោធិសត្វនោះ ហើយទ្រង់បានតាំង មាតាជាអគ្គមហេសី ។ កាលព្រះបិតាសោយទីវង្គតទៅហើយ ព្រះពោធិសត្វនោះ បានជាព្រះរាជា ព្រះនាមថា **កដ្ឋវាហនៈ** គ្រង រាជសម្បត្តិដោយធម៌ ស្តេចបានទៅតាមយថាកម្ម ។

ព្រះសាស្តា កាលទ្រង់នាំសម្តែងព្រះធម្មទេសនានេះមក សម្តែងដល់ព្រះបាទកោសលហើយ ទ្រង់សម្តែងរឿងហើយ បន្ត អនុសន្ធិហើយ ទ្រង់ប្រជុំជាតកថា ព្រះមាតាក្នុងកាលនោះ បាន ជាព្រះមហាមយាទេវី ព្រះបិតាក្នុងកាលនោះ បានមកជាព្រះបាទ សុទ្ធោទនមហារាជា ចំណែក ព្រះកដ្ឋវាហនរាជ ក្នុងគ្រានោះ បាន ជាតថាគតនេះឯង ។

**កដ្ឋហារិជាតកទី ៧ ចប់**



www.elibraryofcambodia.org

## គាមណិជាតកទី ៨

**អបិ អតរមានានំ ផលាសាវ សមិជ្ឈតិ**
**វិបក្កព្រហ្មចរិយោស្មិ ឯវំ ជានាហិ គាមណីតិ។**

( គាមណិកុមារពោលថា ) ការប្រាថ្នានូវផល តែង សម្រេចព្រមដល់ពួកជនអ្នកមិនរួសរាន់ អញជាអ្នក មានព្រហ្មចារ្យចាស់ក្លាហើយ ម្នាលគាមណិ អ្នកចូរ ដឹងយ៉ាងនេះចុះ ។

## អដ្ឋកថា គាមណិជាតក

ព្រះសាស្តា កាលប្រថាប់នៅក្នុងព្រះវិហារជេតពន ទ្រង់ ប្រារព្ធភិក្ខុអ្នកលះបង់សេចក្តីព្យាយាម ទើបត្រាស់ព្រះធម៌ទេសនា នេះមានពាក្យផ្តើមថា **អបិ អតរមានានំ** ជាដើម។



www.elibraryofcambodia.org

ក៏រឿងបច្ចុប្បន្ន និងរឿងអតីតក្នុងជាតកនេះ នឹងមានជាក់ច្បាស់ក្នុងសំវរជាតក ឯកាទសកនិបាត ក្នុងសំវរជាតកនោះ និងជាតកនេះ រឿងប្រព្រឹត្តទៅដូចគ្នា តែគាថាផ្សេងគ្នា មានសេចក្តីសង្ខេបថា គាមណិកុមារតាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ និងជាព្រះកនិដ្ឋារបស់ព្រះភស្តា ១០០ ព្រះអង្គ ក៏ជាអ្នកដែលព្រះភដា ១០០ ហែហាម ប្រថាប់លើបល្ល័ង្កដ៏ប្រសើរ ខាងក្រោមស្វេតច្ឆត្រ ក្រឡេកមើលយសសម្បត្តិរបស់ព្រះអង្គ រីករាយព្រះទ័យថា យសសម្បត្តិរបស់យើងនេះ ជារបស់អាចារ្យយើង ទើបទ្រង់បញ្ចេញឧទាននេះថា :

**ការប្រាថ្នានូវផល តែងសម្រេចព្រមដល់ពួកជន**
**អ្នកមិនរួសរាន់ អញជាអ្នកមានព្រហ្មចារ្យចាស់ក្លា**
**ហើយ ម្នាលគាមណិ អ្នកចូរដឹងយ៉ាងនេះចុះ ។**

បណ្តាបទទាំងនេះ សព្ទថា *អបិ* គ្រាន់តែជានិបាត បទថា *អតរមានានំ* បានដល់ អ្នកតាំងនៅក្នុងឱវាទរបស់បណ្ឌិតទាំងឡាយ មិនប្រញាប់ ធ្វើការដោយឧបាយ ។



www.elibraryofcambodia.org

បទថា ផលាសាវ សមិជ្ឈតិ សេចក្តីថា សេចក្តីសង្ឃឹម ក្នុងផលដែលប្រាថ្នាទុក ឈ្មោះថា រមែងសម្រេចពិត ព្រោះសេចក្តីសម្រេចផលនោះតែម្យ៉ាង។ បទថា ផលាសា បានដល់ ផលនៃសេចក្តីសង្ឃឹម គឺផលដែលប្រាថ្នាទុក រមែងសម្រេចដោយពិត ក្នុងបទថា វិបក្កព្រហ្មចរិយោស្មិ នេះ សង្គហវត្ថុ ៤ ឈ្មោះថា ព្រហ្មចរិយៈ ព្រោះជាការប្រព្រឹត្តដ៏ប្រសើរ ព្រហ្មចរិយនោះ ឈ្មោះថា ចាស់ក្លាក្រៃលែង ព្រោះបានចំពោះបានយសសម្បត្តិ ដែលមានសង្គហវត្ថុនោះជាមូល របស់យសដែលសម្រេចដល់គាមណិកុមារនោះ ក៏ឈ្មោះថាព្រហ្មចរិយៈ ព្រោះអត្ថថា ប្រសើរ។ ដោយហេតុនោះ ទើបលោកពោលថា ខ្ញុំម្ចាស់ជាអ្នកមានព្រហ្មចរិយៈចាស់ក្លាហើយ។ បទថា ឯវំ ជានាហិ គាមណិ សេចក្តីថា ក្នុងទីកន្លែងនៃបុរសអ្នកស្រុកក្តី ប្រធានស្រុកក្តី ឈ្មោះថា គាមណិ អ្នកធំក្នុងភូមិ ( មេភូមិ ) តែក្នុងទីនេះ សំដៅយកខ្លួនឯង ដែលជាប្រធានមនុស្សទាំងពួង ទើបពោលថា ម្នាលនាយស្រុកដ៏ចម្រើន លោក



www.elibraryofcambodia.org

ចូរដឹងហេតុនេះយ៉ាងនោះថា យើងឈានកន្លងបងប្រុសទាំងរយនាក់ បានទទួលរាជ្យដ៏ធំនេះ ព្រោះអាស្រ័យអាចារ្យដូច្នេះ បញ្ចេញឧទានហើយ ។

កាលគាមណិកុមារនោះបានរាជសម្បត្តិ វេលាកន្លងទៅ ២-៣ ថ្ងៃ បងប្រុសគ្រប់គ្នា បានទៅកាន់លំនៅរបស់ខ្លួនៗ ព្រះបាទគាមណិគ្រងរាជសម្បត្តិដោយធម៌ ហើយទៅតាមយថាកម្ម ។ ឯព្រះពោធិសត្វ ធ្វើបុណ្យហើយ បានទៅតាមយថាកម្ម។ ព្រះសាស្ដា គ្រាទ្រង់នាំព្រះធម៌ទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសអរិយសច្ចទាំងឡាយ ក្នុងវេលាចប់សច្ច ភិក្ខុអ្នកលះបង់សេចក្ដីព្យាយាម បានតាំងនៅក្នុងព្រះអរហត្ត ។

ព្រះសាស្ដា ត្រាស់បន្តអនុសន្ធិហើយ ទ្រង់ប្រជុំជាតកថា ព្រះបាទគាមណិក្នុងកាលនោះ បានជាព្រះអានន្ទ ចំណែកអាចារ្យ គឺតថាគតនេះឯង ។

**គាមណិជាតកទី ៤ ចប់**



www.elibraryofcambodia.org

## មឃទេវជាតកទី ៩

ឧត្តមង្គរុហា មយ្ហំ ឥមេ ជាតា វយោហរា
បាតុភូតា ទេវទូតា បព្វជ្ជាសមយោ មមាតិ ។

( ព្រះរាជាពោធិសត្វទ្រង់ត្រាស់ថា ) សក់ទាំងឡាយនេះនាំទៅនូវវ័យ ( ស្កូវ ) កើតដល់អញហើយ ទេវទូតកើតប្រាកដហើយ ( នេះ ) ជាសម័យ នៃផ្នួសរបស់អញ ។

## អដ្ឋកថា មឃទេវជាតក

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធកាលស្តេចចេញរកអភិនិស្ក្រមណ៍ ទើបត្រាស់ព្រះធម្មទេសនានេះថា **ឧត្តមង្គរុហា មយ្ហំ** ជាដើម ។ កាលស្តេចចេញស្វែងរក



www.elibraryofcambodia.org

អភិនិស្ក្រមណ៍នោះ បានពោលទុកហើយ ក្នុងនិទានកថា នៅខាងក្រោមនោះឯង ក្នុងកាលនោះ ភិក្ខុទាំងឡាយអង្គុយពណ៌នាកាលព្រះអង្គចេញបព្វជ្ជារបស់ព្រះទសពល ។

គ្រានោះ ព្រះសាស្តាយាងមកកាន់រោងធម្មសភា ប្រថាប់លើពុទ្ធាសនៈ ត្រាស់ហៅភិក្ខុទាំងឡាយ សួរថា ម្នាលភិក្ខុទាំង-ឡាយ ឥឡូវនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី ? ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយមិនបានសន្ទនាគ្នាអំពីរឿងដទៃទេ តែពណ៌នាកាលដែលស្តេចយាងចេញបព្វជ្ជារបស់ព្រះអង្គប៉ុណ្ណោះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតចេញចាកនេក្ខម្មៈក្នុងកាលឥឡូវនេះ ក៏មិនមែនសូម្បីក្នុងកាលមុន ក៏បានចេញនេក្ខម្មៈដូចគ្នា ទើបភិក្ខុទាំងឡាយអារាធនាព្រះដ៏មានព្រះភាគ ដើម្បីត្រាស់រឿងនោះឱ្យជាក់ច្បាស់រវាងភពដែលកន្លងទៅឱ្យប្រាកដដូចតទៅ ។

ក្នុងអតីតកាល ក្នុងក្រុងមិថិលា វិទេហរដ្ឋ មានព្រះរាជាព្រះនាមថា **មឃទេវៈ** ជាព្រះមហាធម្មរាជ អ្នកតាំងនៅក្នុងធមិ



www.elibraryofcambodia.org

ព្រះបាទមឃទេវៈ ទ្រង់ឱ្យកាលវេលាដ៏វែងអស់ទៅ ថ្ងៃមួយ ត្រាស់ហៅជាងកាត់សក់មកថា នែជាងកាត់សក់សម្លាញ់ កាលឃើញសក់ស្កូវលើក្បាលរបស់យើងក្នុងកាលណា អ្នកចូរប្រាប់ដល់យើងក្នុងកាលនោះ ចំណែកជាងកាត់សក់ក៏បានធ្វើឱ្យវេលាដ៏វែងអស់ទៅថ្ងៃមួយ ឃើញព្រះកេសាស្កូវមួយសរសៃក្នុងរវាងព្រះកេសាទាំង-ឡាយ ដែលមានពណ៌ដូចផ្កាអញ្ចន់របស់ព្រះរាជា ទើបក្រាបទូលថា បពិត្រសម្មតិទេព ព្រះកេសាស្កូវមួយសរសៃ ប្រាកដដល់ព្រះអង្គ។ ព្រះរាជាត្រាស់ថា សម្លាញ់ បើយ៉ាងនោះ អ្នកចូរដកសក់ស្កូវនោះ របស់យើងដាក់ក្នុងបាតដៃ កាលព្រះរាជាត្រាស់យ៉ាងនោះ ទើបជាងកាត់សក់យកដង្កៀបមាសដក ហើយឱ្យព្រះកេសាស្កូវ ប្រតិស្ឋានទៅក្នុងបាតព្រះហស្ត របស់ព្រះរាជាក្នុងកាលនោះព្រះរាជានៅមានអាយុ ៨៤០០០ ឆ្នាំ សូម្បីជាយ៉ាងនេះ ព្រះរាជាបានឃើញសក់ស្កូវហើយ ក៏ទ្រង់សម្គាល់ប្រដូចជាយមរាជមកឈរនៅជិតៗ នឹងដូចជាខ្លួនឯងចូលមកក្នុងបណ្ណសាលា មានភ្លើងកំពុងឆេះ ដូច្នេះ ក៏ដល់នូវសេចក្ដីសង្វេគ ទើបទ្រង់ព្រះតម្រិះថា នែ



www.elibraryofcambodia.org

មឃទេវៈលួង់ខ្លៅ អ្នកនឹងមិនអាចលះកិលេសទាំងនេះ ដរាបណា សក់ស្កូវរមែងកើតឡើង កាលព្រះបាទមឃទេវៈនោះរំពឹងដល់សក់ស្កូវប្រាកដហើយ សេចក្ដីក្ដៅខាងក្នុងក៏ប្រាកដឡើង ព្រះសេទោក្នុងព្រះសីសៈហូរចេញមក សំពត់សាដកបានដល់អាការដែលនឹងត្រូវជូតយកព្រះសេទោចេញ ព្រះបាទមឃទេវៈនោះព្រះតម្រិះថា យើងគួរចេញទៅបួសក្នុងថ្ងៃនេះឯង ។ ទើបទ្រង់ប្រទានស្រុកដ៏ល្អដែលជាទីដែនកើតឡើងនៃទ្រព្យ ៧០០០ កហាបណៈ ដល់ជាងកាត់សក់ ហើយបញ្ជាឱ្យហៅព្រះឱរសព្រះអង្គមកត្រាស់ថា នែកូនសក់ស្កូវប្រាកដលើសីសៈរបស់បិតាហើយ បិតាជាមនុស្សចាស់ហើយ កាមរបស់មនុស្ស បិតាបានបរិភោគហើយ ឥឡូវនេះ បិតានឹងស្វែងរកកាមដ៏ជាទិព្វ នេះជាពេលដែលបិតាត្រូវចេញទៅបួស អ្នកចូរគ្រប់គ្រងរាជសម្បត្តិនេះ ចំណែកបិតាបួសហើយ នឹងធ្វើនូវសមណធម៌ក្នុងអម្ពវ័នឧទ្យានឈ្មោះមឃទេវៈ អាមាត្យទាំងឡាយចូលទៅគាល់ព្រះរាជា ដែលមានបំណងនឹងបួសយ៉ាងនោះ ហើយទូលសួរថា បពិត្រសម្មតិទេព អ្វីជាហេតុនៃព្រះផ្នួសរបស់ព្រះអង្គ?



www.elibraryofcambodia.org

ព្រះរាជាទ្រង់កាន់សក់ស្កូវ ត្រាស់ព្រះគាថានេះ ដល់អាមាត្យទាំងឡាយថា :

> សក់ទាំងឡាយនេះនាំទៅនូវវ័យ ( ស្កូវ ) កើតដល់អញហើយ ទេវទូតកើតប្រាកដហើយ ( នេះ ) ជាសម័យនៃផ្នួសរបស់អញ ។

បណ្តាបទទាំងនោះ បទថា **ឧត្តមង្គរុហា** បានដល់ សក់ពិតណាស់ សក់ទាំងឡាយហៅថា **ឧត្តមង្គរុហា** ព្រោះដុះឡើងលើ ខ្ពស់ជាងអវយវៈ មានដៃ និងជើងជាដើម គឺថា លើសីសៈ ។

បទថា **ឥមេ ជាតា វយោហរា** សេចក្តីថា អ្នកទាំងឡាយចូរមើលសក់ស្កូវទាំងនេះកើតហើយ ឈ្មោះថា ជាហេតុនាំវ័យទៅ ព្រោះនាំយកវ័យទាំង ៣ ទៅ ដោយភាវៈប្រាកដសក់ស្កូវ ។ បទថា **ជាតុភ្ជូត** បានដល់ កើតហើយ ។



www.elibraryofcambodia.org

មច្ចុ ឈ្មោះថា **ទេវៈ** ឈ្មោះថា **ទេវទូត** ព្រោះជាទូតនៃទេវៈនោះ ពិតណាស់ សក់ស្កូវទាំងឡាយប្រាកដលើសីសៈ បុគ្គលរមែងជាអ្នកឈរនៅក្នុងសម្នាក់របស់មច្ចុរាជ ព្រោះដូច្នោះ ទើបសក់ស្កូវទាំងឡាយ លោកហៅថា ទូតរបស់ទេវៈ គឺមច្ចុ ដែលឈ្មោះថា ទេវទូត ព្រោះទូតដូចទេវៈ ដូច្នេះក៏មាន ឧទាហរណ៍យ៉ាងនេះថា បុគ្គលរមែងដូចអ្នកដែលជាទេវតាអ្នកមានប្រដាប់និងតាក់តែងហើយ ឈរនៅក្នុងអាកាសពោលថា លោកនឹងស្លាប់ក្នុងថ្ងៃនោះ យ៉ាងណា កាលសក់ស្កូវទាំងឡាយប្រាកដហើយលើសីសៈ រមែងដូចទេវតាព្យាករដូច្នេះដូចគ្នា ព្រោះដូច្នោះ ទើបសក់ស្កូវទាំងឡាយ លោកពោលថា ជាទូតដូចទេព ដែលឈ្មោះថា ទេវទូត ព្រោះជាទូតរបស់វិសុទ្ធិទេពទាំងឡាយ ដូច្នេះក៏មាន។ ពិតណាស់ ព្រះពោធិសត្វគ្រប់ព្រះអង្គ ទតឃើញមនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងបព្វជិត ក៏ដល់សេចក្តីសង្វេគ ស្តេចចេញទៅបួស សមដូចដែលត្រាស់ថា :

**មហាបពិត្រ ព្រោះអាត្មាភាពឃើញមនុស្សចាស់ មនុស្ស**



www.elibraryofcambodia.org

**មានជំងឺ បាននូវសេចក្តីទុក្ខ មនុស្សស្លាប់ ដែលដល់នូវការអស់អាយុ និងបព្វជិត ជាអ្នកទ្រទ្រង់សំពត់កាសាវៈ ទើបចេញបួស** ដូច្នេះ ។

ដោយបរិយាយនេះ ទើបសក់ស្កូវទាំងឡាយ លោកហៅថា ទេវទូត ព្រោះជាទូតនៃវិសុទ្ធិទេពទាំងឡាយ ។ ដោយបទថា **បព្ពជ្ជា សមយោ មមំ** នេះ លោកសម្តែងថា នេះជាកាលនៃការកាន់យកសមណភេទ បានឈ្មោះថា បព្វជ្ជា ព្រោះអត្ថថា ចេញចាកភាពជាគ្រហស្ថរបស់ ។

ព្រះបាទមឃទេវៈនោះ កាលត្រាស់យ៉ាងនេះហើយ ទើបលះបង់រាជសម្បត្តិ បួសជាតាឥសី ក្នុងថ្ងៃនោះឯង។ ប្រថាប់នៅក្នុងមឃអម្ពវ័ននោះឯង ចម្រើនព្រហ្មវិហារ ៤ នៅ ៨៤០០០ ឆ្នាំ តាំងនៅក្នុងឈានដែលមិនសាបសូន្យ សោយទិវង្គតហើយ កើតក្នុងព្រហ្មលោក ចុតិចាកព្រហ្មលោកនោះ បានជាព្រះរាជាព្រះនាមថា **នេមិ** ក្នុងក្រុងមិថិលានោះឯងទៀត ។ វង្សរបស់ព្រះអង្គដែល



www.elibraryofcambodia.org

បាត់បង់ទៅ ( កន្លងទៅ ) ទើបទ្រង់បួសក្នុងអម្ពវ័ននោះឯង ។ ចម្រើនព្រហ្មវិហារ ៤ ត្រឡប់ទៅកើតក្នុងព្រហ្មលោក ដូចដើមវិញទៀត ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតចេញមហាភិនិស្ក្រមណ៍ក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនក៏បានចេញហើយដូចគ្នា លុះទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសអរិយសច្ច ៤ ក្នុងវេលាចប់អរិយសច្ចនោះ ភិក្ខុពួកខ្លះ បានជាព្រះសោតាបន្ន ពួកខ្លះបានជាសកទាគាមី ពួកខ្លះបានជាអនាគាមី ព្រះមានព្រះភាគត្រាស់រឿងនេះបន្តអនុសន្ធិ ដោយប្រការដូច្នេះ ហើយទ្រង់ប្រជុំជាតកថាជាងកោរកាត់ក្នុងកាលនោះ បានជាព្រះអានន្ទ ក្នុងឥឡូវនេះ បុត្រក្នុងគ្រានោះបានជារាហុលក្នុងកាលឥឡូវនេះ ឯព្រះបាទមឃទេវៈគឺតថាគតនេះឯង ។

**មឃទេវជាតកទី ៩ ចប់**



www.elibraryofcambodia.org

## សុខវិហារិជាតកទី ១០

យញ្ច អញ្ញេ ន រក្ខន្តិ
យោ ច អញ្ញេ ន រក្ខតិ
ស វេ រាជ សុខំ សេតិ
កាមេសុ អនបេក្ខវាតិ ។

( ឥសីពោធិសត្វពោលថា ) ពួកជនដទៃ មិនរក្សាជនណា ម្យ៉ាងទៀត ជនណាមិនរក្សាពួកជនដទៃ បពិត្រព្រះរាជា ជននោះឯង មិនមានសេចក្ដីអាឡោះអាល័យក្នុងកាមទាំងឡាយទេ រមែងដេកជាសុខ ។



www.elibraryofcambodia.org

# អដ្ឋកថា សុខវិហារិជាតក

ព្រះសាស្តា កាលទ្រង់អាស្រ័យអនុបិយនគរ ប្រថាប់នៅក្នុងអនុបិយអម្ពវ័ន ទ្រង់ប្រារព្ធព្រះភទ្ទិយត្ថេរអ្នកមានប្រក្រតីនៅជាសុខ ទើប ត្រាស់ព្រះធម៌ទេសនានេះមានពាក្យផ្តើមថា **យញ្ច អញ្ញេ ន រក្ខន្តិ** ជាដើម ។

ព្រះភទ្ទិយត្ថេរ អ្នកមានប្រក្រតីនៅជាសុខ មានឧបាលិជាទី៧ ( ជាគម្រប់ ៧ ) បួសក្នុងសមាគមនឹក្សត្រ ៦ ព្រះអង្គ បណ្តាព្រះថេរៈទាំងនោះ ព្រះភទ្ទិយៈ គិម្ពិលៈ ភគុ ឧបាលិ សម្រេចព្រះអរហត្ត ព្រះអានន្ទជាព្រះសោតាបន្ន ព្រះអនុរុទ្ធត្ថេរ ជាអ្នកមានទិព្វចក្ខុ ( សម្រេចព្រះអរហត្ត ) ព្រះទេវទត្ត ជាអ្នកបានឈានរឿងរ៉ាវរបស់ក្សត្រទាំង ៦ ព្រះអង្គ នឹងមានសម្តែងក្នុងកណ្ឌហាលជាតកអនុបិយនគរតែប៉ុណ្ណោះ ។ ព្រះភទ្ទិយត្ថេររក្សាឃុំគ្រងព្រះអង្គក្នុងកាលជាព្រះរាជា ញ៉ាំងឱ្យទ្រង់ឃើញភ័យដែលកើតឡើងចំពោះព្រះអង្គ ដែលគេរក្សាការពារនៅដោយការរក្សាច្រើន ដូចទេវតាចាត់ការរក្សា និងភ័យដែលកើតឡើងដល់ព្រះអង្គ អ្នកទ្រង់



www.elibraryofcambodia.org

យាងទៅ យាងមក នៅលើព្រះក្រឡាបន្ទំ នៅប្រាសាទជាន់លើ ឥឡូវនេះ សម្រេចអរហត្តហើយ សូម្បីនៅក្នុងទីណាមួយ មានព្រៃជាដើម ក៏ពិចារណាឈាន ឃើញភាពដែលព្រះអង្គជាអ្នកប្រាសចាកភ័យ ទើបបញ្ចេញឧទានថា សុខហ្ន៎ ! សុខហ្ន៎ ! ភិក្ខុទាំង-ឡាយបានស្តាប់ហើយ ទើបក្រាបទូលដល់ព្រះមានព្រះភាគថា ព្រះភទ្ទិយត្ថេរព្យាករព្រះអរហត្តផល ព្រះសម្មាសម្ពុទ្ធត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភទ្ទិយៈ មានប្រក្រតីនៅជាសុខក្នុងកាលនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏មានប្រក្រតីនៅជាសុខដូចគ្នា ទើបភិក្ខុទាំងឡាយទូលអារាធនាព្រះមានព្រះភាគ ដើម្បីត្រូវការឱ្យប្រាកដហេតុការណ៍ នៅក្នុងរវាងភពដែលកន្លងទៅហើយ ឱ្យប្រាកដដូចតទៅនេះ :

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វ ជាព្រាហ្មណ៍មហាសាល អ្នកកើតនៅក្នុងត្រកូលខ្ពង់ខ្ពស់ ឃើញទោសក្នុងកាមទាំងឡាយ និងអានិសង្សក្នុងការចេញបួស ទើបលះបង់កាមទាំងឡាយ ចូលទៅកាន់ព្រៃហិមពាន្ត បួសជាឥសី ធ្វើសមាបត្តិ ៨ ឱ្យកើតឡើង សូម្បី



www.elibraryofcambodia.org

បរិវាររបស់ព្រះពោធិសត្វនោះបានបរិវារច្រើន មានតាបស ៥០០ រូប ។ ក្នុងរដូវភ្លៀង ព្រះពោធិសត្វនោះ ចេញអំពីព្រៃហិមពាន្ត ហែហមដោយពួកតាបស ចារិកទៅក្នុងស្រុក និងនិគមជាដើម ទើប ទៅដល់ក្រុងពារាណសី ទ្រង់អាស្រ័យព្រះរាជាសម្រេចការ នៅក្នុងព្រះរាជឧទ្យាន ហើយគង់នៅក្នុងឧទ្យាននោះ ៤ ខែ រដូវភ្លៀង ហើយទើបទូលលាព្រះរាជា។ លំដាប់នោះ ព្រះរាជា ទ្រង់អង្វរព្រះពោធិសត្វថា លោកម្ចាស់ដ៏ចម្រើន លោកមាស់ក៏ ចាស់ហើយ ប្រយោជន៍អ្វីដោយព្រៃហិមពាន្ត សូមលោកម្ចាស់ បញ្ជូនអន្តេវាសិកទាំងឡាយទៅកាន់ព្រៃហិមពាន្ត ហើយគង់នៅ ក្នុងទីនេះចុះ។ ព្រះពោធិសត្វទ្រង់ផ្ញើតាបស ៥០០ រូបជាមួយ អន្តេវាសិកអ្នកជាធំ ហើយបញ្ជូនតាបសទាំងនោះឱ្យទៅ ដោយ ពាក្យថា ចូរលោកទៅកាន់ព្រៃហិមពាន្តជាមួយតាបសទាំងនេះ ឯយើងនៅក្នុងទីនេះឯង ហើយខ្លួនព្រះអង្គ ក៏សម្រេចនៅក្នុងព្រះ រាជឧទ្យាននោះ ប្រធានអន្តេវាសិករបស់ព្រះពោធិសត្វនោះ ជា រាជបព្វជិត លះបង់រាជសម្បត្តិដ៏ច្រើន ចេញបួស ធ្វើកសិណបរិកម្ម បានសមាបត្តិ ៨។ ប្រធានអន្តេវាសិកនោះ នៅក្នុងព្រៃហិមពាន្ត ជាមួយតាបសទាំងឡាយ មានបំណងនឹងឃើញអាចារ្យ ទើបហៅ



www.elibraryofcambodia.org

តាបសទាំងឡាយមកហើយ ពោលថា លោកទាំងឡាយ ចូរនៅក្នុងទីនេះសិនចុះ យើងឃើញអាចារ្យនោះហើយនឹងត្រឡប់មក ហើយទៅកាន់សម្នាក់របស់អាចារ្យ ថ្វាយបង្គំ ហើយធ្វើបដិសណ្ឋារៈក្រាលសំពត់មួយផ្ទាំង គង់នៅសម្នាក់របស់អាចារ្យនោះឯង។ ក៏សម័យនោះ ព្រះរាជាទ្រង់ព្រះតម្រិះថា នឹងសួរសុខទុក្ខព្រះតាបស ទើបស្តេចយាងទៅកាន់ឧទ្យាន ថ្វាយបង្គំហើយ អង្គុយក្នុងចំណែកម្ខាង តាបសដែលជាអន្តេវាសិក សូម្បីឃើញព្រះរាជាក៏មិនក្រោកឡើង នៅតែគង់នៅយ៉ាងនោះ បន្លឺឧទានថា សុខហ្ន៎ ! សុខហ្ន៎ ! ព្រះរាជាទ្រង់អន់ព្រះទ័យថា តាបសនេះសូម្បីឃើញយើង ក៏នៅមិនក្រោកឡើង ទើបត្រាស់នឹងព្រះពោធិសត្វថា លោកម្ចាស់ដ៏ចម្រើន តាបសនេះ គង់នឹងឆាន់តាមសេចក្តីត្រូវការ ទើបសម្រេចការយ៉ាងសប្បាយតែម្យ៉ាង បញ្ចេញនូវឧទាន ។ ព្រះពោធិសត្វត្រាស់ថា មហាបពិត្រ តាបសនេះ កាលពីមុនជាព្រះរាជាមួយអង្គដូចព្រះអង្គដែរ តាបសនោះគិតថា កាលពីមុន ជាគ្រហស្ថ យើងសោយរាជសម្បត្តិ សូម្បីមនុស្សជាច្រើន មានដៃកាន់អាវុធការពារនៅមិនបានសេចក្តីសុខបែបនេះ ទើបប្រារព្ធសុខក្នុងការបួស និងសុខក្នុងឈានរបស់ខ្លួន ហើយបន្លឺឧទាននេះ កាលត្រាស់យ៉ាងនេះ



www.elibraryofcambodia.org

ហើយ ដើម្បីនឹងត្រាស់ធម្មកថាដល់ព្រះរាជា ទើបត្រាស់គាថានេះថា :

**ពួកជនដទៃមិនរក្សាជនណាផង ហើយជនណាក៏មិនត្រូវការរក្សាពួកជនដទៃផង បពិត្រព្រះរាជា ជននោះឯងមិនមានសេចក្តីអាឡោះអាល័យក្នុងកាមទាំងឡាយ រមែងដេកនៅជាសុខ ។**

បណ្តាបទទាំងនោះ បទថា *យញ្ញេ អញ្ញេ ន រក្ខន្តិ* សេចក្តីថា បុគ្គលដទៃជាច្រើន រមែងមិនរក្សាបុគ្គលណា ។ បទថា *យោ ច អញ្ញេ ន រក្ខតិ* សេចក្តីថា សូម្បីបុគ្គលណាក៏មិនរក្សាមនុស្សដទៃជាច្រើន ដោយគិតថា យើងតែម្នាក់គ្រងរាជសម្បត្តិ ។

បទថា *ស វេ រាជសុខំ សេតិ* សេចក្តីថា មហាបពិត្រ បុគ្គលម្នាក់ មិនមានមិត្តភក្រ្ត ស្ងាត់ស្ងៀម ហើយជាអ្នកបរិបូណ៌ដោយសេចក្តីសុខផ្លូវកាយ និងផ្លូវចិត្ត រមែងដេកជាសុខ ពាក្យថា ដេកជាសុខនេះ ជាប្រធានបទទេសនាប៉ុណ្ណោះ រមែងដេកជាសុខតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន បុគ្គលបែបនេះ រមែងដើរ ឈរ អង្គុយ



www.elibraryofcambodia.org

ដេកជាសុខ គឺបានទទួលសេចក្តីសុខគ្រប់ឥរិយាបថតែម្យ៉ាង ។ បទថា **កាមេសុ អនបេក្ខវា** សេចក្តីថា មហាបពិត្រ បុគ្គលបែបនេះ វៀរចាកសេចក្តីវង្វេងក្នុងវត្ថុកាម និងកិលេសកាម គឺប្រាសចាកឆន្ទរាគៈ មិនមានតណ្ហា រមែងនៅជាសុខគ្រប់ឥរិយាបថ ។

ព្រះរាជា ទ្រង់បានស្តាប់ព្រះធម៌ទេសនាហើយ រមែងមានព្រះទ័យត្រេកអរ ថ្វាយបង្គំហើយ ស្តេចក៏ទៅកាន់រាជនិវេសន៍នោះឯង ។ ឯអន្តេវាសិក ក៏ថ្វាយបង្គំអាចារ្យ ហើយទៅកាន់ព្រៃហិមពាន្តដូចដើមវិញ ។ ចំណែកព្រះពោធិសត្វនៅទីនោះឯង មានឈានមិនសាបសូន្យ លះលោកនេះហើយ កើតក្នុងព្រហ្មលោក ។

ព្រះសាស្តា គ្រាដែលទ្រង់នាំធម្មទេសនានោះមកសម្តែងហើយ ទ្រង់បន្តអនុសន្ធិ ហើយទ្រង់ប្រជុំជាតកថា អន្តេវាសិកក្នុងកាលនោះ បានជាភទ្ទិយៈ ចំណែកគ្រូរបស់គណៈ គឺយើងតថាគតនេះឯង ។

**សុខវិហារិជាតកទី ១០ ចប់**



www.elibraryofcambodia.org

**ឧទ្ទានៃនអបណ្ណកវគ្គនោះ គឺ**

វរាបណ្ណក វណ្ណុបថ សេរិវោ
សុវិចក្ខណា តណ្ឌុលនាឡិកស្សា
ហិរិ បុត្ត វរុត្តកាមណិនា
យោ ច ន រក្ខតិ តេន ទស ។

និយាយអំពីបុគ្គលខ្លះ ប្រកាន់ហេតុមិនខុសដ៏ប្រសើរ ក្នុងអបណ្ណកជាតក ១ វណ្ណុបថជាតក ១ សេរិវវាណិជជាតក ១ បុគ្គលមានប្រាជ្ញាជាគ្រឿងពិចារណា ក្នុងចុល្លកសេដ្ឋីជាតក ១ តណ្ឌុលនាឡិជាតក ១ បុគ្គលមានហិរិក្នុងទេវធម្មជាតក ១ ព្រះរាជបុត្ត ក្នុងកដ្ឋហារិជាតក ១ គាមណិជាតក ១ មឃទេវជាតក ១ ជនណាមិនរក្សាជនដទៃ ក្នុងសុខវិហារិជាតក ១ ត្រូវជា ១០ ជាតក ។

**អបណ្ណកវគ្គទី ១ ចប់**



www.elibraryofcambodia.org

# ព្រះសុត្តន្តបិដក ខុទ្ទកនិកាយជាតក

## សីលវគ្គទី ២

### លក្ខណជាតកទី ១

ហោតិ សីលវតំ អត្ថោ បដិសន្ថារវុត្តិនំ
លក្ខណំ បស្ស អាយន្តំ ញាតិសង្ឃបុរក្ខិតំ
អថ បស្សសិមំ កាឡំ សុវិហីនំវ ញាតិភិ។

(ម្រឹគពោធិសត្វពោលថា) សេចក្តីចម្រើនតែងកើតមានដល់ពួកជនអ្នកមានសីល អ្នកប្រព្រឹត្តបដិសណ្ឋារៈ នាងចូរមើលម្រឹគឈ្មោះលក្ខណៈ កំពុងដើរមក ដែលពួកញាតិហែហមហើយ នាងឃើញម្រឹគឈ្មោះកាឡៈនេះ ដែលសាបសូន្យចាកពួកញាតិ (កំពុងដើរមក) ឬទេ។



www.elibraryofcambodia.org

# អដ្ឋកថាសីលវគ្គទី ២

## អដ្ឋកថា លក្ខណជាតក

ព្រះសាស្តា កាលស្តេចយាងចូលទៅនៅអាស្រ័យព្រះនគររាជគ្រឹះ គង់ប្រថាប់ក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្ត ទើបត្រាស់ព្រះធម្មទេសនានេះដោយមានពាក្យជាដើមថា **ហោតិ សីលវតំ អត្ថោ** ដូច្នេះជាដើម ។ រឿងព្រះទេវទត្តរហូតដល់ការប្រកបកម្ម គឺការសម្លាប់យ៉ាងធ្ងន់ នឹងមានសជាក់ច្បាស់ទុកក្នុង **កណ្ឌហាលជាតក** រឿងការលែងដំរី **ធនបាលកៈ** មាននៅក្នុង **ចុល្លហង្សជាតក** នឹងការដែលត្រូវផែនដីស្រូប ក៏មាននៅក្នុង **សមុទ្ទពាណិជ្ជជាតក** ក្នុងទ្វាទសកនិបាត ។

សម័យមួយ ទេវទត្តសូមវត្ថុ ៥ ប្រការ កាលមិនបាន ទើបបំបែកសង្ឃ នាំភិក្ខុ ៥០០ អង្គទៅកាន់គយាសីសប្រទេស កាលនោះញាណរបស់ភិក្ខុទាំងនោះ បានដល់សេចក្តីចាស់ក្លាហើយ ព្រះ



www.elibraryofcambodia.org

សាស្តាទ្រង់ជ្រាបដូច្នោះទើប ត្រាស់ហៅអគ្គសាវកទាំង ២ មកថា ម្នាលសារីបុត្រ នឹងមោគ្គល្លានភិក្ខុ ៥០០ អ្នកអាស្រ័យរបស់ពួកអ្នកពេញចិត្តលទ្ធិទេវទត្ត ហើយទៅជាមួយទេវទត្ត ក៏ឥឡូវនេះញាណរបស់ភិក្ខុទាំងនោះ ដល់នូវការចាស់ក្លាហើយ ពួកអ្នកចូរទៅទីនោះ ព្រមជាមួយភិក្ខុចំនួនច្រើន សម្តែងធមិដល់ភិក្ខុទាំងនោះ ដើម្បីឱ្យភិក្ខុទាំងនោះត្រាស់ដឹងនូវមគ្គផលហើយ ចូរនាំមក។ ទើបព្រះអគ្គសាវកទាំងពីរនោះ ទៅកាន់សីសប្រទេសនោះឯង ។ សម្តែងធមិដល់ភិក្ខុទាំងនោះឱ្យត្រាស់ដឹងធមិដោយមគ្គផលហើយ ដល់វេលាអរុណរះឡើង ទើបនាំភិក្ខុទាំងនោះមកកាន់វត្តវេឡុវ័ន វិហារនោះ ក្នុងវេលាដែលព្រះសារីបុត្តត្ថេរមកថ្វាយបង្គំព្រះមានព្រះភាគហើយ នៅឈរ ភិក្ខុទាំងឡាយនាំគ្នាសរសើរព្រះថេរៈ ហើយក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះធម្មសេនាបតីបងប្រុសធំរបស់ខ្ញុំព្រះអង្គទាំងឡាយ ដែលមានភិក្ខុទាំង ៥០០ ហែហាមមកហើយ រុងរឿងជាទីបំផុត ចំណែកទេវទត្តជាអ្នកមានបរិវារសាបសូន្យហើយ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ



www.elibraryofcambodia.org

ទាំងឡាយ សារីបុត្រដែលពួកភិក្ខុហែហមហើយ រមែងរុងរឿងតែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏ល្អរុងរឿងដូចគ្នាដែរ ឯទេវទត្តសាបសូន្យចាកពួកញាតិក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេដែរ សូម្បីក្នុងកាលមុន ក៏សាបសូន្យដូចគ្នា ភិក្ខុទាំងឡាយទូលអារាធនាព្រះមានព្រះ ភាគដើម្បីឱ្យទ្រង់ប្រកាសរឿងនោះជាក់ច្បាស់ ព្រះមានព្រះភាគ ទ្រង់បានធ្វើហេតុនោះឱ្យប្រាកដឡើងដូចតទៅនេះថា :

ក្នុងអតីតកាល ព្រះបាទមគធៈមួយអង្គ គ្រងរាជសម្បត្តិក្នុងនគររាជគ្រឹះ ក្នុងដែនមគធៈ ក្នុងកាលនោះ ព្រះពោធិសត្វទ្រង់បដិសន្ធិក្នុងកំណើតម្រឹគជាតិ លុះចម្រើនវ័យហើយ មានសត្វមួយពាន់ជាបរិវារនៅក្នុងព្រៃ ព្រះពោធិសត្វមានកូន ២ គឺ **លក្ខណៈ** និង **កាឡៈ** ក្នុងវេលាដែលខ្លួនចាស់ ព្រះពោធិសត្វនោះពោលថា កូន ទាំងពីរឥឡូវនេះ ឪពុកចាស់ហើយ អ្នកទាំងពីរ ចូរគ្រប់គ្រងពួកសត្វម្រឹគទាំងនេះ ហើយឱ្យបុត្រម្នាក់ៗ រក្សាម្រឹគចំនួន ៥០០ តាំងពីពេលនោះ សត្វទាំងពីរក៏គ្រប់គ្រងម្រឹគ។ ក្នុងដែនមគធៈ



www.elibraryofcambodia.org

ក្នុងសម័យដែលសម្បូរស្រូវ អន្តរាយក៏រមែងកើតមានដល់ម្រឹគទាំងឡាយក្នុងព្រៃ អំពីពួកដែលត្រូវការសម្លាប់ពួកសត្វម្រឹគដែលមកស៊ីស្រូវ ទើបគេជីករណ្តៅបិទបាំងដោយជន្ទួញ ព្យួរដុំថ្មទម្លាក់ពីលើជាអន្ទាក់មានអន្ទាក់បញ្ឆោតជាដើមសត្វ ជាច្រើនដល់នូវសេចក្តីវិនាស ព្រះពោធិសត្វដឹងកាល ទើបឱ្យហៅកូនទាំងពីរមកហើយពោលថា កូនទាំង ២ សម័យនេះជាសម័យដែលសម្បូរដោយស្រូវ សត្វជាច្រើននឹងដល់សេចក្តីវិនាស យើងចាស់ហើយ នឹងឈប់សម្រាកនៅកន្លែងមួយ ដោយឧបាយម្យ៉ាង ពួកកូនចូរនាំក្រុមម្រឹគរបស់ពួកកូន ចូលទៅកាន់ជើងភ្នំក្នុងព្រៃ ក្នុងវេលាគេធ្វើស្រូវហើយ ចាំចូលមក បុត្រទាំងពីរនោះទទួលពាក្យរបស់បិតាហើយព្រមដោយបរិវារ នាំគ្នាចេញទៅ ពួកមនុស្សទាំងឡាយ រមែងដឹងផ្លូវដែលពួកសត្វទាំងនោះទៅ និងមកថា ក្នុងវេលានេះ ពួកម្រឹគកំពុងចុះពីភ្នំ ក្នុងវេលានេះ កំពុងឡើងភ្នំ មនុស្សទាំងនោះ អង្គុយក្នុងទីកំបាំងក្នុងទីនោះ ក៏ចាក់សត្វជាច្រើនឱ្យស្លាប់ ចំណែកកាឡៈព្រោះហេតុតែខ្លួនល្ងង់ ទើបមិនដឹងថា ក្នុងវេលានេះគួរទៅ ទើប



www.elibraryofcambodia.org

នាំពួកសត្វទៅតាមទ្វារស្រុក ទាំងក្នុងវេលាព្រឹក វេលាល្ងាច ទាំងពេលព្រលប់ និងជិតភ្លឺ ពួកមនុស្សឈរ និងអង្គុយតាមប្រក្រតីនោះឯង នៅក្នុងទីនោះៗ ញុំាងពួកសត្វជាច្រើនឱ្យដល់នូវសេចក្តីវិនាស ម្រឹគកាឡៈនោះ ឱ្យម្រឹគជាច្រើន ដល់នូវសេចក្តីវិនាស ព្រោះតែខ្លួនជាមនុស្សល្ងង់ខ្លៅយ៉ាងនេះ ទើបចូលទៅកាន់ព្រៃដោយម្រឹគមានប្រមាណតិចតួចប៉ុណ្ណោះ។

ចំណែកម្រឹគលក្ខណៈជាបណ្ឌិតមានបញ្ញា ឆ្លាតក្នុងឧបាយដឹងថា វេលានេះគួរទៅ និងមិនគួរទៅម្រឹគលក្ខណៈនោះមិនទៅតាមទ្វារស្រុក មិនទៅក្នុងពេលកណ្តាលថ្ងៃ មិនទៅពេលព្រលប់ មិនទៅពេលជិតភ្លឺ នាំពួកម្រឹគទៅកណ្តាលយប់ប៉ុណ្ណោះ ព្រោះដូច្នោះ ទើបម្រឹគលក្ខណៈមិនធ្វើម្រឹគសូម្បីមួយឱ្យវិនាស ទៅកាន់ព្រៃហើយ ម្រឹគទាំងនោះនៅក្នុងព្រៃ ៥ ខែ កាលពួកមនុស្សធ្វើស្រូវសំរេចហើយ ទើបនាំគ្នាចុះពីលើភ្នំ ម្រឹគកាឡៈ សូម្បីទៅខាងក្រោយ ក៏ធ្វើសត្វម្រឹគទាំងអស់ដល់នូវសេចក្តីវិនាស ដោយន័យមុននោះឯង តែឯងប៉ុណ្ណោះមកហើយ ចំណែកម្រឹគលក្ខណៈ



www.elibraryofcambodia.org

សូម្បីម្រឹគមួយ ក៏មិនមានវិនាសដែរ មានម្រឹគ ៥០០ ហែហម មកកាន់សម្នាក់របស់បិតាមាតាជាធម្មតា ចំណែកព្រះពោធិសត្វ ឃើញបុត្រទាំងពីរមក កាលប្រឹក្សាជាមួយមេម្រឹគ ទើបពោល គាថានេះថា :

**សេចក្ដីចម្រើនតែងកើតមាន ដល់ពួកជនអ្នកមានសីល អ្នកប្រព្រឹត្តបដិសណ្ឋារៈ នាងចូរមើលម្រឹគឈ្មោះលក្ខណៈ កំពុងដើរមក ដែលពួកញាតិហែហមហើយ នាងឃើញ ម្រឹគឈ្មោះកាឡៈនេះ ដែលសាបសូន្យចាកពួកញាតិ (កំពុងដើរមក) ឬទេ ។**

បណ្ដាបទទាំងនោះ បទថា ***សីលវតំ*** សេចក្ដីថា ឈ្មោះថា អ្នកមានសីល គឺបរិបូណ៌ដោយអាចារៈព្រោះមានសេចក្ដីសុខជា ប្រក្រតី ។

បទថា *អត្ថោ* បានដល់សេចក្ដីចម្រើន ។ *បដិសន្ថារវុត្តិនំ* ឈ្មោះថា អ្នកមានប្រក្រតីប្រព្រឹត្តបដិសណ្ឋារៈ ព្រោះមានប្រក្រតី ប្រព្រឹត្តទៅក្នុងធម្មបដិសណ្ឋារៈ និងអាមិសបដិសណ្ឋារៈ ដល់ជន



www.elibraryofcambodia.org

ទាំងនោះ ដែលមានប្រក្រតីប្រព្រឹត្តក្នុងបដិសណ្ឋារៈ ក៏ក្នុងទីនេះ គប្បីជ្រាបធម្មបដិសណ្ឋារៈ ដូចការហាមមិនឱ្យធ្វើបាប ការឱ្យឱវាទ និងអនុសាសន៍ជាដើម គប្បីជ្រាបអាមិសបដិសណ្ឋារៈ ដូចជា ការឱ្យទីកន្លែង អាហារបរិភោគ ថ្នាំកែរោគ និងការរក្សាដែលប្រកបដោយធម៌ លោកពោលពាក្យអធិប្បាយនេះទុកថា ឈ្មោះថា ការចម្រើន តែងមានដល់ជនដែលជាបណ្ឌិតអ្នកដល់ព្រមហើយដោយអាចារៈ អ្នកតាំងនៅក្នុងបដិសណ្ឋារៈទាំង ២ នេះ ឥឡូវនេះ ព្រះពោធិសត្វកាលនឹងហៅមាតារបស់ម្រឹគ ដើម្បីសម្តែងនូវសេចក្តីចម្រើននោះ ទើបពោលពាក្យជាដើមថា នាងចូរមើលម្រឹគឈ្មោះលក្ខណៈ ដូច្នេះ ក្នុងពាក្យដែលពោលនោះ មានសេចក្តីសង្ខេបដូចតទៅនេះ :

នាងចូរមើលបុត្ររបស់នាង បរិបូណ៌ដោយអាចារៈ និងបដិសណ្ឋារៈ មិនធ្វើសូម្បីនូវម្រឹគមួយឱ្យវិនាស ដែលពួកញាតិបានធ្វើទុកខាងមុខ គឺកំពុងតែដើរមក តែអើ នាងចូរមើលម្រឹគឈ្មោះកាឡៈនេះ អ្នកមានបញ្ញាល្ងង់ខ្លៅ ជាអ្នកមិនមានសម្បទា គឺអាចារៈ



www.elibraryofcambodia.org

និងបដិសណ្ឋារៈ ដែលសាបសូន្យចាកញាតិទាំងឡាយ មិនមានញាតិសូម្បីត្រឹមតែម្នាក់ ។

ព្រះពោធិសត្វជួបជុំបុត្រយ៉ាងនេះហើយ តាំងនៅរហូតអស់អាយុ បានទៅតាមយថាកម្ម ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្រដែលពួកញាតិហែហម រមែងរុងរឿងក្នុងពេលឥឡូវប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនក៏ដូចគ្នាដែរ ទេវទត្តសាបសូន្យចាកពួកញាតិក្នុងកាលឥឡូវនេះក៏ប៉ុណ្ណោះក៏ទេ សូម្បីក្នុងកាលមុនក៏សាបសូន្យដូចគ្នាដែរ លុះទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់បន្តអនុសន្ធិ រួចទ្រង់ប្រជុំជាតកថា ម្រឹគកាឡៈក្នុងកាលនោះ បានជាទេវទត្ត សូម្បីបរិស័ទរបស់ម្រឹគកាឡៈក្នុងកាលនោះ បានជាបរិស័ទរបស់ទេវទត្ត ម្រឹគឈ្មោះលក្ខណៈក្នុងកាលនោះ បានជាសារីបុត្រ សូម្បីបរិស័ទរបស់ម្រឹគឈ្មោះលក្ខណៈក្នុងកាលនោះ បានជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯមាតាក្នុងកាលនោះ បានជារាហុលមាតា ឯបិតាក្នុងគ្រានោះ បានជាតថាគត ។

**លក្ខណៈជាតកទី ១ ចប់**



www.elibraryofcambodia.org

## និគ្រោធមិគជាតកទី ២

និគ្រោធមេវ សេវេយ្យ
ន សាខំ ឧបសំវសេ
និគ្រោធស្មឹ មតំ សេយ្យោ
យញ្ចេ សាខស្មិ ជីវិតន្តិ។

( មេម្រឹគពោលថា ) បុគ្គលគប្បីសេព នូវម្រឹគឈ្មោះនិគ្រោធតែម្យ៉ាង កុំគប្បីសេពនូវម្រឹគឈ្មោះសាខៈឡើយ ការស្លាប់ក្នុងសម្នាក់នៃម្រឹគឈ្មោះនិគ្រោធ ជាការប្រសើរ ការរស់នៅក្នុងសម្នាក់នៃម្រឹគ ឈ្មោះសាខៈពុំប្រសើរឡើយ ។



www.elibraryofcambodia.org

# អដ្ឋកថា និគ្រោធមិគជាតក

ព្រះសាស្តា កាលទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុនី ដែលជាមាតារបស់កុមារកស្សបត្ថេរ ទើបត្រាស់ធម្មទេសនានេះថា **និគ្រោធមេវ សេវេយ្យ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនីនោះ បានជាធីតារបស់សេដ្ឋីអ្នកមានទ្រព្យច្រើន ក្នុងនគររាជគ្រឹះ មានកុសលមូលគ្រប់គ្រាន់មានសង្ខារដែលញ៉ាំញីហើយ ជាបច្ឆិមភវិកសត្វ គឺមានភពចុងក្រោយ ឧបនិស្ស័យនៃព្រះអរហត្តភ្លឺក្នុងព្រះទ័យរបស់នាង ដូចប្រទីបដែលបំភ្លឺក្នុងឆ្នាំងដូច្នោះ។ គ្រានោះ ចាប់ផ្តើមតាំងពីកាលដែលដឹងក្តីហើយ សេដ្ឋីធីតានោះមិនត្រេកអរក្នុងការនៅគ្រប់គ្រងផ្ទះ មានបំណងនឹងបួស ទើបពោលនឹងមាតាបិតាថា បពិត្រលោកឪពុក និងអ្នកម្តាយ ចិត្តរបស់ខ្ញុំមិនត្រេកអរក្នុងភាពជាឃរាវាស ខ្ញុំមានបំណងនឹងបួសក្នុងព្រះពុទ្ធសាសនា ដែលជាគ្រឿងនាំចេញចាកទុក្ខ សូមលោកទាំងឡាយឱ្យខ្ញុំបួសចុះ។ មាតាបិតាពោលថា កូននិយាយអ្វី ត្រកូល



www.elibraryofcambodia.org

នេះទ្រព្យសម្បត្តិច្រើន ហើយកូនក៏ជាធីតាតែម្នាក់របស់យើងទាំងឡាយ កូនមិនគួរនឹងបួសទេ ។ នាងសូម្បីអង្វរជារឿយៗ ក៏មិនបានការបព្វជ្ជាអំពីសម្នាក់របស់មាតាបិតានាងឡើយ ទើបគិតថា មិនអីទេ យើងទៅកាន់ត្រកូលស្វាមី នឹងញុំាងស្វាមីឱ្យអនុញ្ញាត ហើយនឹងបួស ។ នាងចម្រើនវ័យហើយ ក៏បានទៅកាន់ត្រកូលនៃស្វាមីជាអ្នកមានសីល មានកល្យាណធម៌ គ្រប់គ្រងផ្ទះ ។ លំដាប់នោះព្រោះអាស្រ័យការនៅរួម នាងក៏តាំងគភ៌ ។ នាងមិនដឹងថាតាំងគភ៌ ។ គ្រានោះ គេអំពាវនាវបុណ្យនក្ខត្តឫក្សក្នុងនគរ អ្នកនគរទាំងអស់នាំគ្នាលេងនក្ខត្តឫក្ស ព្រះនគរមានប្រដាប់តាក់តែង ដូចទេពនគរ កាលលេងបុណ្យនក្ខត្តឫក្សសូម្បីធំយ៉ាងនេះ ប្រព្រឹត្តទៅនាងក៏មិនលាប និងតាក់តែងរាងកាយរបស់នាង គឺមិនប្រដាប់តាក់តែង នាងត្រាច់ទៅតាមលក្ខណៈធម្មតាប្រក្រតីនោះឯង ។

លំដាប់នោះ ស្វាមីពោលនឹងនាងថា នាងដ៏ចម្រើន នគរទាំងអស់អាស្រ័យនក្ខត្តឫក្ស តែនាងមិនបដិបត្តិ គឺប្រដាប់រាងកាយ មិនធ្វើការតាក់តែង ព្រោះហេតុអ្វី ?



www.elibraryofcambodia.org

ទើបនាងពោលថា បពិត្រអ្នកជាម្ចាស់ រាងកាយពេញដោយសាកសព ៣២ ប្រការតែម្យ៉ាង ប្រយោជន៍អ្វីដោយរាងកាយនេះ ដែលប្រដាប់ហើយ ព្រោះកាយនេះ ទេវតា ព្រហ្មមិនបាន និម្មិតមិន មិនមែនកើតអំពីត្របកនៃផ្កាបុណ្ឌរិក ផ្កាកុមុទ និងផ្កាឧប្បលខៀវ តែពេញដោយលាមក មិនស្អាត មិនមែនពេញដោយអមតឱសថឡើយ ដែលពិត កើតក្នុងសាកសព មានមាតាបិតាជាដែនកើត មានការលាបពណ៌ខាត់ពណ៌ និងការគក់ច្របាច់ជានិច្ច និងមានការបែកធ្លាយ និងខ្ចាត់ខ្ចាយទៅជាធម្មតា ហើយចោលក្នុងព្រៃប៉ាឆាប៉ុណ្ណោះ ដែលតណ្ហារួបរឹត ជាហេតុនៃសេចក្តីសោក ជាវត្ថុដែលតាំងនៅនៃសេចក្តីរំខាន ជាទីអាស្រ័យនៃរោគទាំងពួង ជាទីទទួលគ្រឿងកម្មករណ៍ របស់ខូចខាងក្នុង ហូរចេញមកខាងក្រៅជានិច្ច ជាកន្លែងរបស់ពួកដង្កូវច្រើនត្រកូល នឹងទៅកាន់ព្រៃប៉ាឆាមានការស្លាប់ជាទីបំផុត សូម្បីនឹងផ្លាស់ប្តូរទៅក្នុងក្រសែចក្ខុរបស់មនុស្សលោកទាំងពួង ។

កាយប្រកបដោយឆ្អឹង និងសរសៃ គ្របដណ្តប់ដោយស្បែក



www.elibraryofcambodia.org

និងសាច់ ជាកាយដែលត្រូវស្បែកបិទបាំង មិនប្រាកដតាមសេចក្តីពិត ពេញដោយពោះវៀនធំ ខួរក្បាល សាច់បេះដូង សួត តម្រងទឹកនោម ប្រមាត់ លំពែង ឈាម និងសំបោរ ទាច ញើស ខ្លាញ់ខាប់ តម្រងឈាម ទឹកមាត់ និងខ្លាញ់រាវ កាលបើដូច្នោះ សុទ្ធតែជារបស់មិនស្អាត រមែងហូរចេញចាកទ្វារទាំង ៩ របស់កាយនោះគ្រប់ពេល គឺអាចម៍ភ្នែកហូរចេញមកអំពីភ្នែក អាចម៍ត្រចៀកហូរចេញពីត្រចៀក និងទឹកសំបោរហូរចេញពីច្រមុះ គ្រាខ្លះ ក៏ហូរចេញពីមាត់ ហូរចេញពីកាយ ជាញើស កាលបើយ៉ាងនោះ សរីរៈរបស់កាយនោះពោរពេញទៅដោយខ្លាញ់ ខួរមនុស្សពាលត្រូវអវិជ្ជារួបរឹត ទើបសម្គាល់ថា ជារបស់ស្អាត កាយនេះ មានទោសច្រើនប្រៀបដូចដើមឈើពិស ជាទីនៅរបស់រោគ សុទ្ធតែជាកងទុក្ខ បើលាត់យកក្នុងកាយនេះចេញមកខាងក្រៅ ក៏នឹងត្រូវជាកាយមិនស្អាត មានក្លិនស្អុយ ជាសាកសព ប្រៀបដូចបង្គន់ អ្នកមានបញ្ញារមែងតិះដៀល តែមនុស្សពាល រមែងភ្លើតភ្លើន ដែលស្បែកសុទ្ធៗបិទបាំងទុក មានទ្វារ ៩ មានដំបៅដ៏ច្រើន របស់មិនស្អាត មានក្លិន



www.elibraryofcambodia.org

ស្អុយ ហូរចេញគ្រប់ផ្នែក ក៏ក្នុងកាលណា កាយនេះដេកស្លាប់លើផែនដី ហើមប៉ោង មានពណ៌ខៀវ ត្រូវបោះបង់ចោលទុកក្នុងព្រៃស្មសាន ក្នុងកាលនោះ ញាតិទាំងឡាយរមែងមិនហួងហែង មិនអាល័យ សុនខស្រុក សុនខព្រៃ រមែងស៊ីកាយនេះ និងសត្វត្រដក់ ដង្កូវ ក្អែក ត្មាត និងសត្វទាំងឡាយដទៃៗ រមែងទំពាស៊ី ភិក្ខុអ្នកមានញាណក្នុងសាសនានេះឯង បានស្តាប់ព្រះពុទ្ធវចនៈហើយ រមែងដឹងច្បាស់នូវកាយនេះ រមែងឃើញតាមសេចក្តីពិតថា កាយនេះយ៉ាងណា កាយនោះក៏ដូច្នោះដែរ ខ្ញុំដកចេញការភ្លើតភ្លើនក្នុងកាយ ទាំងខាងក្នុង និងខាងក្រៅចេញហើយ ។

បពិត្រអ្នកជាម្ចាស់ នឹងប្រដាប់តាក់តែងរាងកាយនេះធ្វើអ្វី ការប្រដាប់តាក់តែងកាយនេះ រមែងដូចជាងធ្វើវិចិត្រកម្មខាងក្រៅឆ្នាំង ឬបង្គន់ដែលពេញទៅដោយលាមក ។

សេដ្ឋីបុត្របានស្តាប់ពាក្យរបស់នាងហើយ ទើបពោលថា នាងដ៏ចម្រើន នាងឃើញទោសទាំងឡាយយ៉ាងនេះនៃរាងកាយហើយ ព្រោះហេតុអ្វី ទើបនាងមិនបួស។ នាងពោលថា បពិត្រ



www.elibraryofcambodia.org

អ្នកជាម្ចាស់ បើអ្នកអនុញ្ញាតឱ្យខ្ញុំបួស ខ្ញុំនឹងបួសក្នុងថ្ងៃនេះឯង ។

សេដ្ឋីបុត្រពោលថា ល្អហើយ ខ្ញុំនឹងឱ្យនាងបួស។ ហើយបំពេញមហាទាន ធ្វើមហាសក្ការៈ ហើយនាំនាងទៅក្នុងសម្នាក់ភិក្ខុនីដោយបរិវារជាច្រើន កាលនឹងឱ្យនាងបួស បានបួសក្នុងសម្នាក់ភិក្ខុនីដែលជាបក្ខពួករបស់ទេវទត្តភិក្ខុ។ នាងបានបព្វជ្ជាហើយមានសេចក្តីត្រិះរិះពេញបរិបូណ៌ ត្រេកអរហើយ។ គ្រានោះ កាលគភ៌របស់នាងចាស់ហើយ ភិក្ខុនីទាំងឡាយឃើញភាវៈដែលឥន្ទ្រិយទាំងឡាយប្រែទៅជាដទៃ កាលដែលខ្នងដៃ និងជើងហើមហើយ និងពោះក៏កាន់តែធំឡើងៗ ទើបសួរនាងថា នាងម្ចាស់ នាងដូចជាមានគភ៌ តើនេះជាអ្វីទៅ ? ភិក្ខុនីនោះពោលថា មេម្ចាស់ទាំងឡាយ ខ្ញុំមិនដឹងហេតុនេះទេ តែសីលរបស់ខ្ញុំម្ចាស់នៅបរិបូណ៌ ។ លំដាប់នោះ ទើបភិក្ខុនីទាំងនោះ នាំនាងភិក្ខុនីនោះទៅកាន់សម្នាក់របស់ភិក្ខុទេវទត្ត ហើយទូលថា បពិត្រលោកម្ចាស់ កុលធីតានេះញ៉ាំងស្វាមីឱ្យអនុញ្ញាតបានដោយលំបាក ទើបបានបព្វជ្ជា ឥឡូវនេះគភ៌របស់នាងក៏ប្រាកដឡើង ខ្ញុំម្ចាស់ទាំងឡាយមិនដឹងថា កុលធីតា



www.elibraryofcambodia.org

នេះបានតាំងគភ៌ក្នុងពេលនៃខ្លួនជាគ្រហស្ថ ឬក្នុងពេលដែលបួសហើយទេ ឥឡូវនេះ ខ្ញុំម្ចាស់ទាំងឡាយនឹងធ្វើដូចម្តេច? ព្រោះការដែលខ្លួនមិនដឹង និងព្រោះខន្តី មេត្តា ករុណា និងការអាណិតអាសូរមិនមាន ទើបទេវទត្តគិតយ៉ាងនេះថា សេចក្តីនិន្ទានឹងកើតមានដល់យើងថា ភិក្ខុនីអ្នកនៅក្នុងសម្នាក់ភិក្ខុទេវទត្តមានគភ៌ តែទេវទត្តត្រឡប់មិនអើពើ យើងឱ្យភិក្ខុនីនេះសឹកទើបគួរ ។ ទេវទត្តមិនបានពិចារណា ពោលថា ពួកនាងចូរឱ្យភិក្ខុនីនេះសឹក ភិក្ខុនីទាំងនោះស្តាប់ពាក្យរបស់ទេវទត្តហើយ ក្រោកឡើងថ្វាយបង្គំបានទៅកាន់សម្នាក់ លំដាប់នោះ ភិក្ខុនីនោះពោលនឹងភិក្ខុនីទាំងឡាយថា មេម្ចាស់ទាំងឡាយ ព្រះទេវទត្ត មិនមែនជាព្រះពុទ្ធទេ ការបព្វជ្ជារបស់យើងក្នុងសម្នាក់របស់ព្រះទេវទត្តនោះ ក៏មិនមែនទេ បព្វជ្ជារបស់យើងក្នុងសម្នាក់របស់ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរក្នុងលោក ម្យ៉ាងទៀត បព្វជ្ជានោះយើងបានដោយលំបាក នាងទាំងឡាយកុំធ្វើឱ្យការបព្វជ្ជានេះអន្តរធានឡើយ មកនាងទាំងឡាយ សូមនាំខ្ញុំទៅកាន់វត្តជេតពន ក្នុងសម្នាក់របស់ព្រះសាស្តា



www.elibraryofcambodia.org

ទើបភិក្ខុនីទាំងឡាយនាំភិក្ខុនីនោះទៅអំពីក្រុងរាជគ្រឹះ អស់ចម្ងាយផ្លូវ ៤៥ យោជន៍ ដល់វត្តជេតពនមហាវិហារដោយលំដាប់ ថ្វាយបង្គំព្រះសាស្ដាហើយ ក្រាបទូលរឿងឱ្យទ្រង់ជ្រាប ។

ព្រះសាស្ដា ទ្រង់ព្រះតម្រិះថា ភិក្ខុនីនេះតាំងគភ៌ក្នុងវេលាជាគ្រហស្ថដោយពិត ទោះយ៉ាងនោះ ពួកតិរ្ថិយនឹងបានឱកាសថា ព្រះសមណគោតម នាំភិក្ខុនីដែលទេវទត្តលះបង់ហើយ ត្រាច់ទៅព្រោះដូច្នេះ ដើម្បីនឹងកាត់ពាក្យនេះ គួរនឹងវិនិច្ឆ័យអធិករណ៍នេះក្នុងចំណោមបរិស័ទ មានព្រះរាជាជាប្រធាន ស្អែកឡើង ទើបឱ្យយាងព្រះបាទកោសល និងអញ្ជើញមហាអនាថបិណ្ឌិកសេដ្ឋី ចុល្ល-អនាថបិណ្ឌិកសេដ្ឋី នាងវិសាខាមហាឧបាសិកា និងត្រកូលធំៗ ដទៃៗដែលមានឈ្មោះបោះសំឡេង ក្នុងវេលាល្ងាច កាលបរិស័ទទាំង ៤ ប្រជុំគ្នាហើយ ទើបត្រាស់ហៅព្រះឧបាលិត្ថេរមកថា អ្នកចូរទៅជម្រះកម្មរបស់ភិក្ខុនីនេះ ក្នុងចំណោមមបរិស័ទទាំង ៤។ ព្រះថេរៈទទួលព្រះតម្រាស់ថា ហើយទើបទៅកាន់កណ្ដាលបរិស័ទ គង់លើអាសនៈដែលគេក្រាលទុកដើម្បីខ្លួន ហើយឱ្យហៅនាងវិសាខាឧបាសិកាមក



www.elibraryofcambodia.org

ខាងមុខព្រះភក្រ្តរបស់ព្រះរាជា ឱ្យទទួលអធិករណ៍នេះថា នែនាង វិសាខា នាងចូរទៅ ចូរដឹងដោយពិតថា ភិក្ខុនីនេះបួសក្នុងខែនោះ ថ្ងៃនោះ ហើយចូរដឹងថា នាងមានគភ៌នេះមុន ឬក្រោយបួស មហាឧបាសិកាទទួលពាក្យព្រះថេរៈហើយ ទើបឱ្យគេបាំងវាំងននហើយ ត្រួតមើលទីបំផុតដៃ ជើង ផ្ចិត និងពោះរបស់ភិក្ខុនីខាងក្នុងវាំងនន រាប់ខែ និងថ្ងៃ ដឹងថា នាងបានតាំងគភ៌ក្នុងភាវៈជាគ្រហស្ថដោយពិត ទើបទៅកាន់សម្នាក់របស់ព្រះឧបាលិ ហើយប្រាប់សេចក្ដីនុ៎ះដល់ព្រះថេរៈ។ ព្រះថេរៈស្ដាប់ហើយ បានធ្វើឱ្យភិក្ខុនីនោះ ជាអ្នកបរិសុទ្ធ ក្នុងចំណោមបរិស័ទទាំង ៤។ ភិក្ខុនីនោះជាអ្នកបរិសុទ្ធហើយ ថ្វាយបង្គំភិក្ខុសង្ឃ និងថ្វាយបង្គំព្រះសាស្ដា ហើយទៅកាន់សម្នាក់ជាមួយនឹងភិក្ខុនីទាំងឡាយ ភិក្ខុនីនោះអាស្រ័យគភ៌ចាស់ហើយបានប្រសូតបុត្រ មានអានុភាពច្រើន ជាអ្នកតាំងសេចក្ដីប្រាថ្នាទុកទាបបាទមូលរបស់ព្រះពុទ្ធព្រះនាមថា បទុមុត្តរៈ ។

ថ្ងៃមួយ ព្រះរាជាស្ដេចយាងទៅជិតៗ សម្នាក់ភិក្ខុនី ទ្រង់បានឮសំឡេងទារកយំ ទើបត្រាស់សួរអមាត្យទាំងឡាយ។ អមាត្យ



www.elibraryofcambodia.org

ទាំងឡាយដឹងហេតុនោះ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ភិក្ខុនីនោះប្រសូតបុត្រហើយ នុ៎ះជាសំឡេងបុត្ររបស់ភិក្ខុនីនោះឯង។ ព្រះរាជាត្រាស់ថា នែនាយ ឈ្មោះថា ការបដិបត្តិទារកជាគ្រឿងកង្វល់សម្រាប់ភិក្ខុនីទាំងឡាយ ពួកយើងបដិបត្តិទារកនោះ។ ព្រះរាជា ទ្រង់ឱ្យបញ្ជូនទារកនោះដល់ស្រីស្នំមេដោះទាំងឡាយ ឱ្យចម្រើនដោយគ្រឿងរក្សារបស់ក្មេងនោះ ក្នុងថ្ងៃដាក់ឈ្មោះទារកនោះ បានដាក់ឈ្មោះថា កុមារកស្សប គ្រានោះ មនុស្សទាំងឡាយហៅថា កុមារកស្សប ព្រោះចម្រើនធំដោយគ្រឿងរក្សារបស់ទារក មានអាយុ ៧ ខួប កុមារកស្សប បានបួសក្នុងសម្នាក់របស់ព្រះសាស្តា លុះអាយុ ២០ ឆ្នាំបរិបូណ៌ ក៏បានឧបសម្បទាពេលវេលាកន្លងទៅ បានជាអ្នកពោលធមិដ៏វិចិត្រ ក្នុងបណ្តាធម្មកថិកទាំងឡាយ ។

លំដាប់នោះ ព្រះសាស្តាទ្រង់តាំងព្រះកុមារកស្សបទុកក្នុងតំណែងឯតទគ្គៈ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ កុមារកស្សបនេះ ប្រសើរជាងសាវកទាំងឡាយ របស់តាគតដែលជាអ្នក



www.elibraryofcambodia.org

ពោលធម៌វិចិត្រ ក្រោយមក ព្រះកុមារកស្សបនោះបានសម្រេចព្រះអរហត្ត ក្នុងវម្មិកសូត្រ ។ ភិក្ខុនីជាមាតារបស់ព្រះកុមារកស្សបនោះ ឃើញច្បាស់ហើយសម្រេចព្រះអរហត្ត ។ ព្រះកុមារកស្សបប្រាកដក្នុងព្រះពុទ្ធសាសនា ប្រៀបដូចព្រះចន្ទពេញវង់ នៅក្នុងលម្ហមេឃ ដូច្នោះឯង ។

ថ្ងៃមួយ ព្រះសម្ពុទ្ធត្រឡប់អំពីបិណ្ឌបាត ខាងក្រោយភត្តប្រទានឱវាទដល់ភិក្ខុទាំងឡាយ ហើយយាងចូលទៅកាន់ព្រះគន្ធកុដិ ភិក្ខុទាំងឡាយបានទទួលព្រះឱវាទហើយ ពេលថ្ងៃអស្តង្គតក៏ទៅកាន់ទីកន្លែងសម្រាកក្នុងពេលយប់ និងកន្លែងសម្រាកក្នុងពេលថ្ងៃរបស់ខ្លួនរៀង១ ខ្លួន ក្នុងពេលល្ងាច ប្រជុំគ្នាក្នុងរោងធម្មសភាអង្គុយពណ៌នាពីព្រះពុទ្ធគុណថា អាវុសោទាំងឡាយ ទេវទត្តភិក្ខុធ្វើមនុស្សទាំងពីរ គឺព្រះកុមារកស្សបត្ថេរ និងព្រះថេរីឱ្យវិនាសព្រោះការដែលខ្លួនមិនឈ្លាស និងព្រោះការមិនមានខន្តី មេត្តាជាដើម តែព្រះសម្មាសម្ពុទ្ធជាបច្ច័យដល់លោកទាំងពីរនោះ ព្រោះព្រះអង្គជាធម្មរាជា និងប្រកបព្រមដោយព្រះខន្តី ព្រះមេត្តា និង



www.elibraryofcambodia.org

ការអាណិតអាសូរ ។ ព្រះសាស្តាទ្រង់យាងមកកាន់រោងធម្មសភា ដោយពុទ្ធលីលា ប្រថាប់លើអាសនៈដែលគេក្រាលទុកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី ?

ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងព្រះគុណរបស់ព្រះអង្គប៉ុណ្ណោះ ហើយក៏ក្រាបទូលរឿងទាំងឡាយឱ្យទ្រង់ជ្រាប ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាបច្ច័យ និងជាទីពឹងដល់ជនទាំងពីរនាក់នោះ តែក្នុងកាលនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏បានជាទីពឹងរបស់ជនទាំងពីរនោះដូចគ្នា ។ ទើបភិក្ខុទាំងឡាយ អារាធនាព្រះដ៏មានព្រះភាគដើម្បីដឹងរឿងនោះឱ្យបានជាក់ច្បាស់ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើហេតុដែលបិទបាំងទុក ( ភពមុន ) ឱ្យប្រាកដដូចតទៅនេះ :

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិ ក្នុងនគរពារាណសី ចំណែកព្រះពោធិសត្វបដិសន្ធិក្នុងកំណើតម្រឹគជាតិ ។ ព្រះពោធិសត្វកាលចេញចាកផ្ទៃរបស់មាតា មានពណ៌សម្បុរដូចមាស



www.elibraryofcambodia.org

ភ្នែកទាំងពីររបស់ម្រឹគនោះ ដូចជាគ្រាប់កែវមណីមូលក្លំ ជើងទាំងពីរមានពណ៌ដូចប្រាក់ មុខមានពណ៌ដូចជាដុំសំពត់កម្ពលពណ៌ក្រហម ចុងជើងមុខ និងចុងជើងក្រោយ ដូចបរិកម្មដោយរសទឹកល័ក រោមកន្ទុយដូចរោមសត្វចាមរី ក៏រាងកាយរបស់ម្រឹគនោះ មានខ្នាតប៉ុនកូនសេះម្រឹគនោះមានបរិវារ ៥០០ មានឈ្មោះថា និគ្រោធមិគរាជ ដែលរស់នៅក្នុងព្រៃ។ នៅក្នុងទីមិនឆ្ងាយនៃស្តេចម្រឹគឈ្មោះនិគ្រោធនោះ មានម្រឹគដទៃទៀតដែលមានម្រឹគជាបរិវារ ៥០០ ជាបរិវារ មានឈ្មោះថា សាខៈ នៅអាស្រ័យ សូម្បីម្រឹគសាខៈនោះក៏មានពណ៌ដូចជាមាស ។

សម័យនោះ ព្រះបាទពារាណសី ទ្រង់ខ្វាយខ្វល់ក្នុងការសម្លាប់ម្រឹគ វៀរចាកសាច់មិនបាន ទ្រង់ធ្វើឱ្យពួកមនុស្សឱ្យខាតការងារ ញុំាងអ្នកនិគម និងអ្នកជនបទទាំងពួងឱ្យប្រជុំគ្នា ហើយទ្រង់យាងទៅសម្លាប់សត្វរាល់ថ្ងៃ។ ពួកមនុស្សគិតគ្នាថា ព្រះរាជានេះ ទ្រង់ធ្វើពួកយើងឱ្យខាតការងារប៉ុណ្ណោះ ពួកយើងដាក់នុយរបស់ម្រឹគ ទុកក្នុងព្រះរាជឧទ្យាន ដាក់ទឹកផឹកទុកឱ្យគ្រប់គ្រាន់



www.elibraryofcambodia.org

ហើយកៀងម្រឹគជាច្រើន ឱ្យចូលទៅកាន់ព្រះរាជឧទ្យាន ហើយបិទទ្វារ ថ្វាយព្រះរាជា មនុស្សទាំងអស់នោះ ទើបដាំបន្លែដែលជានុយរបស់ម្រឹគទុកក្នុងព្រះរាជឧទ្យាន ចាត់ដាក់ទឹកផឹកទុកឱ្យព្រម ហើយប្រកបទ្វារ យកអន្ទាក់ដៃ កាន់អាវុធនានា មានញញួរជាដើមចូល ព្រៃស្វែងរកម្រឹគគិតថា ពួកយើងនិងចាប់ម្រឹគទាំងឡាយត្រង់ពាក់កណ្តាលផ្លូវ ទើបនាំគ្នាឡោមព័ទ្ធទីប្រមាណ ១ យោជន៍ កាលចូលមក បានព័ទ្ធកន្លែងជាទីនៅរបស់ម្រឹគនិគ្រោធ និងម្រឹគសាខៈត្រង់កណ្តាល កាលឃើញពួកម្រឹគ ទើបយកដំបងវាយដើមឈើ គុម្ពឈើជាដើម និងវាយផែនដី ដេញពួកម្រឹគចេញអំពីទីរុក្ខជាតិ ដែលដុះរាត់រាយនាំគ្នា ងាអាវុធទាំងឡាយ មានដាវលំពែង និងធ្នូជាដើម បន្លឺសំឡេងខ្លាំងៗ ដេញពួកម្រឹគនោះឱ្យចូលព្រះរាជឧទ្យាន ហើយបិទទ្វារ នាំគ្នាទៅគាល់ព្រះរាជា ក្រាបទូលថា បពិត្រព្រះសម្មតិទេព កាលព្រះអង្គយាងទៅសម្លាប់ម្រឹគជាប្រចាំ ធ្វើការងាររបស់ ខ្ញុំព្រះអង្គទាំងឡាយឱ្យវិនាស ពួកខ្ញុំបានដេញម្រឹគទាំឡាយមកពីព្រៃ ពេញព្រះរាជឧទ្យាន របស់ព្រះអង្គហើយ



www.elibraryofcambodia.org

ចាប់ពីពេលនេះទៅ ព្រះអង្គនឹងបានសោយសាច់របស់ម្រឹគទាំងនោះ ហើយទូលាព្រះរាជា នាំគ្នាចេញទៅ ។

ព្រះរាជា បានស្តាប់ពាក្យរបស់មនុស្សទាំងនោះហើយ ក៏ស្តេចយាងទៅព្រះរាជឧទ្យាន ទតមើលម្រឹគទាំងឡាយ ទ្រង់ឃើញម្រឹគពណ៌ដូចមាស ២ ក្បាល ទើបបានព្រះរាជទានអភ័យដល់ម្រឹគទាំងពីរនោះ ចាប់ពីពេលនោះមក គ្រាខ្លះ ស្តេចយាងទៅខ្លួនឯង ទ្រង់សម្លាប់សត្វម្រឹគមួយក្បាលហើយនាំយកមក ពេលខ្លះ ចុងភៅរបស់ព្រះអង្គទៅសម្លាប់ហើយនាំមក ម្រឹគទាំងឡាយឃើញធ្នូប៉ុណ្ណោះ ត្រូវសេចក្តីខ្លាចស្លាប់គំរាម នាំគ្នាគេចទៅ បានទទួលការប្រហារ ២-៣ ដង លំបាកខ្លះ ឈឺខ្លះ ដល់សេចក្តីស្លាប់ខ្លះ ទើបពួកម្រឹគប្រាប់ហេតុនោះដល់ព្រះពោធិសត្វ ព្រះពោធិសត្វឱ្យហៅម្រឹគសាខៈមកហើយពោលថា នែសម្លាញ់ ម្រឹគជាច្រើននាំគ្នាភ័យខ្លាច កាលម្រឹគមាននឹងត្រូវស្លាប់តែម្យ៉ាង តាំងពីពេលនេះអ្នកសម្លាប់ចូរកុំយកកូនសរមកបាញ់ម្រឹគ វារៈរបស់ម្រឹគទាំងឡាយចូរមានត្រង់គល់ឈើរបស់អ្នកពិឃាត វារៈចូរមានដល់បរិស័ទរបស់



www.elibraryofcambodia.org

យើងមួយថ្ងៃ ចូរមានដល់បរិស័ទរបស់លោកមួយថ្ងៃ ម្រឹគគួយក្បាលដែលដល់វេនហើយ ចូរទៅដេកដាក់ក្បាលត្រង់គល់ឈើរបស់អ្នកសម្លាប់ កាលបើដូច្នោះ ម្រឹគទាំងឡាយនឹងមិនខ្លាច ម្រឹគសាខៈទទួលពាក្យហើយ ចាប់ពីពេលនោះមក ម្រឹគដែលដល់វេន នឹងទៅដេកដាក់កនៅទីគល់ឈើ ចុងភៅមកចាប់យកម្រឹគដែលដេកនៅក្នុងទីនោះៗ ឯងទៅ នៅថ្ងៃមួយ ដល់វេនមេម្រឹគដែលមានគភ៌ជាបរិស័ទរបស់ម្រឹគសាខៈ មេម្រឹគនោះចូលទៅរកម្រឹគសាខៈហើយពោលថា លោកម្ចាស់ ខ្ញុំមានគភ៌ ប្រសូតកូនហើយ ពួកយើងទាំងពីរនឹងទៅតាមវេន សូមលោកឱ្យខ្ញុំឆ្លងវេនរបស់ខ្ញុំសិនចុះ ម្រឹគសាខៈពោលថា យើងមិនអាចធ្វើវេនរបស់នាងឱ្យទៅម្រឹគដទៃៗ ឡើយ នាងប៉ុណ្ណោះចូរដឹងថា នាងមានបុត្រ នាងចូរទៅចុះមេម្រឹគនោះ កាលមិនបានការអនុគ្រោះពីសម្នាក់របស់សាខៈ ទើបចូលទៅរកព្រះពោធិសត្វប្រាប់នូវសេចក្តីនុ៎ះ ព្រះពោធិសត្វបានស្តាប់ពាក្យរបស់មេម្រឹគនោះ ទើបគិតថា ព្រះពោធិសត្វទាំងឡាយក្នុងកាលមុន ឃើញទុក្ខរបស់អ្នដទៃ រមែងមិនហួងហែងជីវិតរបស់ខ្លួន



www.elibraryofcambodia.org

ប្រយោជន៍របស់ជនដទៃ ក៏ដូចប្រយោជន៍របស់ខ្លួននោះឯង ជារឿងដែលធ្ងន់សម្រាប់ព្រះពោធិសត្វនោះ ។

ពួកសត្វបក្សី បសុសត្វ ម្រឹគក្នុងព្រៃទាំងអស់ រមែងជាអ្នករស់នៅដោយខ្លួនឯង អ្នកប្រាជ្ញទាំងឡាយ ជាអ្នកស្ងប់ ត្រេកអរហើយក្នុងប្រយោជន៍ជួយដល់សត្វដទៃ រមែងញុំាងអ្នកដទៃនោះឱ្យរស់នៅ ក៏អ្នកប្រាជ្ញទាំងនោះ លះបង់ទ្រព្យ អវយវៈ និងជីវិតដើម្បីប្រយោជន៍ដល់អ្នកដទៃ យើងនោះជាអ្នកអាចនឹងញុំាងពួកសត្វជាច្រើន ព្រមទាំងទេវលោកឱ្យឆ្លងបានផង ក៏ការមិនមានបុណ្យ ព្រោះកាយដែលគ្មានសារៈនេះ យើងនឹងបានលាភរបស់ទានជានិច្ច ដោយខ្លួនឯងពិតប្រាកដ ។

កាលគិតដូច្នេះហើយ ទើបពោលថា នាងចូរទៅចុះ យើងនឹងឱ្យវេនរបស់នាងឆ្លងផុតទៅ កាលពោលហើយ ខ្លួនឯងក៏ទៅដេកដាក់សីសៈត្រង់កំណោត់ឈើពិឃាត មេចុងភៅឃើញដូច្នេះទើបគិតថា ម្រឹគនេះបានទទួលព្រះរាជទានអភ័យ ដេកនៅកន្លែងកំណោត់ឈើ ហេតុអ្វីហ្ន៎ ទើបប្រញាប់ទៅក្រាបទូលដល់ព្រះរាជា



www.elibraryofcambodia.org

ព្រះរាជាស្ដេចទ្រង់ឡើងរថភ្លាមនោះឯង ស្ដេចទៅដោយបរិវារជាច្រើន បានឃើញព្រះពោធិសត្វហើយ ត្រាស់ថា ម្រឹគជាសម្លាញ់ យើងឱ្យអភ័យដល់អ្នកហើយមិនមែនឬ ព្រោះហេតុអ្វី ទើបអ្នកដេកនៅក្នុងទីនេះ ម្រឹគទូលថា បពិត្រមហារាជ មេម្រឹគដែលមានគភ៌ពោលថា សូមលោកឱ្យវេនរបស់ខ្ញុំឱ្យដល់ម្រឹគដទៃ ខ្ញុំព្រះអង្គមិនអាចបោះបង់ចោលនូវមរណៈទុក្ខរបស់ម្រឹគដទៃ ទើបខ្ញុំព្រះអង្គនេះឯងផ្ដល់ជីវិតរបស់ខ្លួនឯងដល់មេម្រឹគនោះ កាន់យកសេចក្ដីស្លាប់ ជារបស់មេម្រឹគនោះហើយ ទើបដេកនៅក្នុងទីនេះ បពិត្រមហារាជ សូមព្រះអង្គ កុំសង្ស័យហេតុដទៃឡើយ ព្រះរាជាត្រាស់ថា ម្នាលសុវណ្ណមិគរាជ អ្នកជាធំ សូម្បីពួកមនុស្សទាំងឡាយ យើងមិនធ្លាប់ឃើញមនុស្សអ្នកដល់ព្រមដោយខន្តី មេត្តា និងសេចក្ដីករុណា អាណិតអាសូរដូចអ្នកទេ ដោយហេតុនោះ យើងមានសេចក្ដីជ្រះថ្លានឹងអ្នក ក្រោកឡើងចុះ យើងឱ្យអភ័យដល់អ្នក និងដល់ម្រឹគដទៃនោះ ស្ដេចម្រឹគពោលថា បពិត្រព្រះអង្គជាកំពូលមនុស្ស កាលខ្ញុំព្រះអង្គទាំងពីរបានអភ័យហើយ ម្រឹគដ៏សេសអំពី



www.elibraryofcambodia.org

នោះនឹងធ្វើដូចម្តេច ? ព្រះរាជាត្រាស់ថា យើងឱ្យអភ័យដល់ម្រឹគដែលសេសសល់ផង ម្រឹគពោធិសត្វក្រាបទូលថា បពិត្រមហារាជ កាលដូច្នោះ ម្រឹគទាំងឡាយក្នុងព្រះឧទ្យានទាំងនោះ នឹងបានអភ័យ ម្រឹគដ៏សេសទ្រង់ធ្វើដូចម្តេច ? យើងឱ្យអភ័យដល់ម្រឹគទាំងនោះ ម្រឹគពោធិសត្វក្រាបទូលថា ម្រឹគទាំងឡាយបានទទួលអភ័យ សត្វជើង ៤ ដ៏សេសនឹងធ្វើដូចម្តេច ? ព្រះរាជាត្រាស់ថា យើងនឹងឱ្យអភ័យដល់សត្វជើង ៤ ទាំងអស់ ម្រឹគពោធិសត្វក្រាបទូលថា បពិត្រមហារាជ សត្វជើង ៤ បានទទួលព្រះរាជទានអភ័យហើយ សត្វបក្សីនឹងធ្វើដូចម្តេច ? ព្រះរាជាត្រាស់ថា សូម្បីពួកសត្វបក្សីទាំងនោះ យើងក៏ឱ្យអភ័យដែរ ម្រឹគពោធិសត្វក្រាបទូលថា ពួកសត្វបក្សីនឹងបានទទួលព្រះរាជអភ័យ ពួកត្រីដែលនៅក្នុងទឹកនឹងធ្វើដូចម្តេច ? ព្រះរាជាត្រាស់ថា សូម្បីពួកត្រីទាំងអស់ យើងឱ្យអភ័យផងដែរ ព្រះពោធិសត្វក្រាបទូលសូម អភ័យដល់ពួកសព្វសត្វនឹងព្រះរាជាយ៉ាងនេះហើយ បានក្រោកឈរឡើងហើយ ឱ្យព្រះរាជាតាំងនៅក្នុងសីល ៥ ហើយសម្តែងធម៌ដល់ព្រះរាជា



www.elibraryofcambodia.org

ដោយសីលរបស់ព្រះពុទ្ធជាម្ចាស់ថា បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ក្នុងជនក ជននី ក្នុងព្រះឱរស ព្រះធីតា ក្នុងព្រាហ្មណ៍គហបតី និងអ្នកនិគមជនបទ កាលទ្រង់ប្រព្រឹត្តធម៌ ប្រព្រឹត្តស្មោះស្មើ ខាងមុខអំពីសេចក្តីស្លាប់ ព្រោះកាយបែកធ្លាយ នឹងចូលទៅកាន់សុគតិសួគ៌ ដូច្នេះ ហើយនៅក្នុងឧទ្យាន ២-៣ ថ្ងៃ ឱ្យឱវាទដល់ព្រះរាជា ពួកម្រឹគហែហមចូលទៅកាន់ព្រៃហើយ មេម្រឹគនោះក៏កើតកូន ដូចជាគេបាចផ្កាឈើ កូនម្រឹគនោះ កាលរត់លេងបានទៅកាន់សម្នាក់របស់ម្រឹគសាខៈ ។ លំដាប់នោះ មេម្រឹគឃើញកូនកំពុងនឹងទៅកាន់សម្នាក់របស់ម្រឹគសាខៈនោះ ទើបពោលថា កូនអើយ ចាប់ពីពេលនេះទៅ កូនកុំទៅកាន់សម្នាក់របស់ម្រឹគសាខៈនោះឡើយ កូនគប្បីទៅកាន់សម្នាក់របស់ម្រឹគ ឈ្មោះនិគ្រោធបានហើយ កាលនឹងឱ្យឱវាទ ទើបពោលគាថានេះថា :

**បុគ្គលគប្បីសេពនូវម្រឹគ ឈ្មោះនិគ្រោធតែម្យ៉ាង**
**កុំគប្បីសេពនូវម្រឹគឈ្មោះសាខៈឡើយ ការស្លាប់**
**ក្នុងសម្នាក់នៃម្រឹគឈ្មោះនិគ្រោធ ជាការប្រសើរ**



www.elibraryofcambodia.org

**ជាងការរស់នៅក្នុងសម្នាក់នៃម្រឹគ ឈ្មោះសាខៈ ពុំប្រសើរឡើយ ។**

បណ្តាបទទាំងនោះ បទថា **និគ្រោធមេវ សេវេយ្យ** សេចក្តីថា នៃកូន កូន ឬមនុស្សដទៃក្តី ដែលប្រាថ្នាប្រយោជន៍ដល់ខ្លួន គួរសេព ឬគួរគោរពរកម្រឹគឈ្មោះនិគ្រោធនោះ ។

បទថា **ន សាខំ ឧបសំវសេ** សេចក្តីថា ម្រឹគឈ្មោះសាខៈមិនគួរចូលទៅនៅរួមទេ គឺមិនគួរចូលទៅជិត ហើយនៅរួមបានដល់ មិនគួរអាស្រ័យម្រឹគឈ្មោះសាខៈនោះចិញ្ចឹមជីវិតឡើយ ។

បទថា **និគ្រោធស្មិំ មតំ សេយ្យោ** សេចក្តីថា ការស្លាប់នៅទ្បៀបបាទា របស់ម្រឹគឈ្មោះថានិគ្រោធប្រសើរជាង គឺប្រសើរខ្ពង់ខ្ពស់បំផុត ។

បទថា **យញ្ចេ សាខស្មិំ ជីវិតំ** សេចក្តីថា ការនៅក្នុងសម្នាក់ម្រឹគឈ្មោះថា សាខៈនោះ មិនប្រសើរ គឺ មិនប្រសើរ មិនខ្ពង់ខ្ពស់ឡើយ ។

ចាប់តាំងពីពេលនោះមក ពួកម្រឹគដែលបានអភ័យ នាំគ្នា



www.elibraryofcambodia.org

ស៊ីស្រូវសំណាបរបស់ពួកមនុស្ស មនុស្សទាំងឡាយមិនអាចវាយ ឬដេញ ដោយគិតថា ម្រឹគទាំងនេះ បានទទួលព្រះរាជទានអភ័យ ទើបនាំគ្នាប្រជុំត្រង់ទីព្រះលានហ្លួង ក្រាបទូលសេចក្ដីនុំះដល់ព្រះរាជា ទើបព្រះរាជាត្រាស់ថា យើងមានសេចក្ដីជ្រះថ្លា ឱ្យពរដល់ស្ដេចម្រឹគឈ្មោះនិគ្រោធ ទោះបីជាយើងនឹងលះរាជសម្បត្តិ ក៏នឹងមិនទម្លាយបេ្ដជ្ញានោះឡើយ លោកទាំងឡាយទៅចុះ នរណាៗក៏ដោយ មិនប្រហារម្រឹគទាំងឡាយ ក្នុងដែនរបស់យើង ម្រឹគនិគ្រោធបានស្ដាប់ហេតុការណ៍នោះ ទើបឱ្យពួកម្រឹគប្រជុំគ្នា ផ្ដល់ឱវាទដល់ម្រឹគទាំងឡាយថា ពីពេលនេះទៅ អ្នកទាំងឡាយ កុំបរិភោគស្រូវសំណាបរបស់មនុស្ស ដូច្នេះ ក៏ប្រាប់ដល់មនុស្សទាំងឡាយថា ពីពេលនេះទៅ មនុស្សទាំងឡាយ ចូរកុំធ្វើរបងដើម្បីរក្សាស្រូវសំណាប តែចូរចងសញ្ញាដោយស្លឹកឈើទុកខាងមុខស្រែ ។

បានឮថា ចាប់ផ្ដើមពីពេលនោះមក ទើបកើតសញ្ញាក្នុងការចងស្លឹកឈើឡើងក្នុងស្រែទាំងឡាយ ។ តាំងពីនោះ ឈ្មោះថាម្រឹគកន្លងល្មើសសញ្ញាក្នុងការចងស្លឹកឈើ រមែងមិនមាន ។ បានឮថា នេះជាឱវាទដែលពួកម្រឹគទាំងនោះបានអំពីព្រះពោធិសត្វ



www.elibraryofcambodia.org

ព្រះ ឱ្យឱវាទពួកម្រឹគយ៉ាងនេះហើយ តាំងនៅរហូតអស់អាយុ ព្រមទាំងម្រឹគទាំងឡាយ បានទៅតាមយថាកម្ម ។ ឯព្រះរាជាទ្រង់បានតាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ទ្រង់ធ្វើបុណ្យទាំងឡាយ ស្តេចបានទៅតាមយថាកម្ម ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាទីពឹងអាស្រ័យរបស់ព្រះថេរី និងព្រះកុមារកស្សបក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏បានជាទីពឹងអាស្រ័យហើយដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់ត្រឡប់មកសម្តែងអរិយសច្ច ៤ បន្តអនុសន្ធិ ហើយទ្រង់ប្រជុំជាតកថា ម្រឹគឈ្មោះសាខៈក្នុងកាលនោះ បានមកជាទេវទត្ត សូម្បីបរិស័ទរបស់ម្រឹគឈ្មោះសាខៈនោះ ក៏បានជាបរិស័ទរបស់ទេវទត្តនោះឯង មេម្រឹគក្នុងកាលនោះ បានជានាងថេរី កូនក្នុងកាលនោះ បានមកជាកុមារកស្សប ព្រះរាជាបានជាអានន្ទ ឯស្តេចម្រឹគឈ្មោះនិគ្រោធ គឺតថាគតនេះឯង ។

**និគ្រោធជាតកទី ២ ចប់**



www.elibraryofcambodia.org

# កណ្ឌិនជាតកទី ៣

ធិរត្ថុ កណ្ឌិនំ សល្លំ បុរិសំ គាឡ្ហវេធិនំ

ធិរត្ថុ តំ ជនបទំ យត្ថិត្ថី បរិណាយិកា

តេ ចាបិ ធិក្កិតា សត្តា

យេ ឥត្ថីនំ វសំ គតាតិ។

( រុក្ខទេវតាពោធិសត្វពោលថា ) ចូរតិះដៀលនូវបុរស អ្នកមានសរមុតចូលទៅ ដែលមានរបួសយ៉ាងខ្លាំង ស្រីជាបរិណាយិកា ( អ្នកត្រួតត្រា ) នៅក្នុងជនបទណា ចូរតិះដៀលនូវជនបទនោះ ម្យ៉ាងទៀត សត្វទាំងឡាយណា លុះក្នុងអំណាចពួកស្រី សត្វទាំងឡាយនោះ ក៏បណ្ដោះតិះដៀលហើយ ។



www.elibraryofcambodia.org

# អដ្ឋកថា គណ្ឋិនជាតក

ព្រះសាស្តា កាលទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធការលួងលោមរបស់ភរិយាចាស់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យជាដើមថា **ធិរត្ថុ កណ្ឋិនំ សល្លំ** ដូច្នេះជាដើម ។

ការប្រលោមលួងលោមនោះ មានសម្តែងជាក់ច្បាស់ក្នុងឥន្ទ្រិយជាតក អដ្ឋកនិបាត ។ ព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះនឹងភិក្ខុនោះថា ម្នាលភិក្ខុ សូម្បីក្នុងកាលមុន អ្នកអាស្រ័យនឹងមាតុគ្រាមនេះ ដល់នូវការអស់ជីវិត ស្រែកហៅនូវធ្យូងភ្លើងដែលប្រាសចាកអណ្តាត ភិក្ខុទាំងឡាយអារាធនាឱ្យព្រះមានព្រះភាគ ទ្រង់ប្រកាសរឿងនោះឱ្យជាក់ច្បាស់ ព្រះមានព្រះភាគ ទ្រង់ធ្វើហេតុនោះរវាងភព ដែលកន្លងទៅហើយឱ្យប្រាកដហើយ ។ បន្ទាប់អំពីនេះទៅ តថាគតនឹងមិនពោលដល់ហេតុការណ៍ដែលភិក្ខុទាំងឡាយអារាធនា និងការដែលហេតុរវាងភពដែលកន្លងទៅនឹងពោលចំពោះពាក្យមានប្រមាណប៉ុណ្ណោះថា **អតីតំ អាហរិ**



www.elibraryofcambodia.org

ប្រែថា ទ្រង់នាំអតីតនិទានមកដូច្នេះ ។ សូម្បីកាលពោលពាក្យមានប្រមាណប៉ុណ្ណេះ ក៏គប្បីប្រកបហេតុការណ៍នេះទាំងអស់ គឺការទូលអារាធនាការប្រៀបធៀប ដូចនាំព្រះចន្ទចេញចាកដុំពពក និងហេតុដែលរវាងភពដែលបិទបាំង ដោយន័យដូចពោលទុកក្នុងខាងក្រោយនោះឯង គប្បីជ្រាបដូចតទៅនេះ ។

ក្នុងកាលអតីត កាលព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិក្នុងនគររាជគ្រឹះ ដែនមគធៈ ក្នុងសម័យស្រូវសំណាបរបស់អ្នកស្រុកមគធៈកើតឡើង ពួកម្រឹគទាំងឡាយ មានសេចក្តីអន្តរាយជាច្រើនសម្រាប់ម្រឹគទាំងនោះ ទើបម្រឹគទាំងនោះចូលទៅកាន់ភ្នំ។ ម្រឹគភ្នំមួយដែលនៅក្នុងព្រៃមួយក្បាល បានធ្វើការស្និទស្នាលជាមួយកូនម្រឹគញីស្រុកមួយក្បាល ក្នុងពេលដែលពួកម្រឹគទាំងនោះចុះអំពីភ្នំ ត្រឡប់មកកាន់ជាយដែនស្រុកវិញ ម្រឹគភ្នំបានចុះមកជាមួយម្រឹគទាំងនោះឯង ព្រោះតែមានចិត្តប្រតិព័ទ្ធលើកូនម្រឹគញីស្រុកនោះ ។ លំដាប់នោះ ម្រឹគញីបានពោលនឹងម្រឹគភ្នំនោះថា បពិត្រលោក លោកជាម្រឹគភ្នំដែលល្ងង់ ធម្មតាក្នុងដែនរបស់ភូមិស្រុកគួរតែប្រយ័ត្ន ព្រោះមានភ័យនៅចំពោះមុខ លោកកុំចុះមក



www.elibraryofcambodia.org

ជាមួយពួកយើងឡើយ ម្រឹគភ្នំនោះមិនព្រមត្រឡប់ព្រោះមានចិត្តស្រឡាញ់ចំពោះម្រឹគញីនោះ ក៏បានមកជាមួយម្រឹគញីនោះឯង ។

អ្នកស្រុកមគធៈដឹងថា ឥឡូវនេះ ជាវេលាដែលពួកម្រឹគត្រូវចុះអំពីចង្កេះភ្នំអ្នកស្រុកទើបទៅឈរពួន ដើម្បីស្ទាក់ពួកម្រឹគក្នុងទីដែលកំបាំងក្បែរផ្លូវ ក្នុងពេលដែលម្រឹគទាំងពីរនោះដើរមក មានព្រានម្នាក់ឈរស្ទាក់នៅក្នុងទីដែលបាំងជិត ។ គ្រានោះ ម្រឹគញីបានដឹងក្លិនមនុស្ស ទើបគិតថា នឹងមានព្រានឈរស្ទាក់នៅទីកន្លែងដែលបាំងបិទ ទើបធ្វើម្រឹគភ្នំដែលល្ងង់នោះឱ្យនៅខាងមុខ ចំណែកខ្លួនឯងទៅខាងក្រោយ ។ នាយព្រានបានធ្វើម្រឹគនោះ ឱ្យដួលចុះត្រង់ទីនោះ គឺបាញ់ដោយកូនសរតែមួយគ្រាប់ុណ្ណោះ ។ ម្រឹគញីដឹងថា ម្រឹគនោះត្រូវព្រានបាញ់ ទើបផ្លោះគេចចេញ ទៅដោយកម្លាំងយ៉ាងឆាប់រហ័សហាក់បីដូចជាខ្យល់ ។ នាយព្រាន ក៏ចេញមកអំពីកន្លែងពួន អារសាច់ជាកង់ៗ បង្កាត់ភ្លើង ឆ្អើសាច់យ៉ាងឆ្ងាញ់ នៅលើធ្យូងភ្លើងដែលប្រាសចាកអណ្តាត ទំពាស៊ី ហើយផឹកទឹក រែកសាច់ដែលសល់ទៅដោយដងរែក មានតំណក់ឈាមហូរ បានទៅកាន់ផ្ទះឱ្យពួកក្មេងត្រេកអរផង ។

ក្នុងកាលនោះ ព្រះពោធិសត្វបានឃើញហេតុនោះ ទើបគិត



www.elibraryofcambodia.org

ថា ម្រឹគល្ងង់នេះស្លាប់ ព្រោះអាស្រ័យមាតា ព្រោះអាស្រ័យបិតា ក៏មិនមែន គឺស្លាប់ព្រោះអាស្រ័យកាម ពិតណាស់ ព្រោះកាមជានិមិត្តហេតុ ទើបសត្វទាំងឡាយដល់នូវទុក្ខជាអនេកប្បការ មានការកាត់ផ្តាច់ជាដើម ក្នុងសុគតិ និងការចងចាំ ៥ ប្រការជាដើម ក្នុងទុគ្គតិ ឈ្មោះថាការធ្វើទុក្ខ គឺសេចក្តីស្លាប់ឱ្យកើតឡើងដល់អ្នកដទៃ ក៏ត្រូវតិះដៀលក្នុងលោកនេះ ជនបទណាមានស្ត្រីជាអ្នកដឹកនាំ ចាត់ចែង គ្រប់គ្រង ក៏ត្រូវតិះដៀល ពួកសត្វអ្នកធ្លាក់នៅក្នុងអំណាចរបស់មាតុគ្រាម ក៏ត្រូវតិះដៀលដូចគ្នា។ ហើយសម្តែងរឿងសម្រាប់តិះដៀល ៣ ប្រការ ដោយគាថា ១ គាថា កាលទេវតាទាំងឡាយនៅក្នុងព្រៃឱ្យសព្ទសាធុការ ហើយបូជាដោយគ្រឿងក្រអូប និងផ្កាកម្រងជាដើម កាលដែលញ៉ាំងព្រៃនោះឱ្យបន្លឺឡើងដោយសំឡេងដ៏ពីរោះ ទើបសម្តែងធម៌ដោយគាថានេះថា :

**ចូរតិះដៀលនូវបុរសអ្នកមានសរមុតចូលទៅ ដែលមានរបួសយ៉ាងខ្លាំង ស្រីជាបរិណាយិកា ( អ្នកត្រួតត្រា ) នៅក្នុងជនបទណា ចូរតិះដៀលនូវជនបទនោះម្យ៉ាងទៀត សត្វទាំងឡាយណា លុះអំណាចពួកស្រី សត្វទាំងឡាយនោះ ក៏បណ្ឌិតតិះដៀលហើយ ។**



www.elibraryofcambodia.org

សព្ទថា ជិរត្តុ ក្នុងគាថានេះ ជាសព្ទនិបាត ប្រើក្នុងអត្ថន័យថា តិះដៀល ។ ក្នុងទីនេះ សព្ទថា ជិរត្តុ នោះ គប្បីឃើញថា ប្រើក្នុងការតិះដៀលដោយអំណាចសេចក្តីភ្ញាក់ផ្អើល និងសេចក្តីស្រៀវស្រើប ញាប់ញ័រ ពិតណាស់ ព្រះពោធិសត្វជាអ្នកភ្ញាក់ផ្អើល និងស្រៀវ ទើបពោលយ៉ាងនេះ អ្នកដែលឈ្មោះថា កណ្ឌី ព្រោះមានកូនសរ ។ ដែលអ្នកមានកូនសរនោះ ។ កូនសរនោះ គេហៅថា សល្ល ព្រោះអត្ថថា ដោតចូលទៅ ព្រោះដូច្នេះ ក្នុងពាក្យថា កណ្ឌិនំ សល្លំ នេះ ទើបមានអត្ថថា អ្នកមានកូនសរម្យ៉ាងទៀត ដែលឈ្មោះថាអ្នកមានសល្លៈ ព្រោះមានកូនសរ ។ អ្នកមានសរនោះ ។ ឈ្មោះថា គាឡ្ហវេធី អ្នកបាញ់ទៅពេញកម្លាំង ព្រោះកាលនឹងឱ្យការប្រហារយ៉ាងខ្លាំងក្លា ទើបបាញ់ខ្លាំងយ៉ាងពេញទី ដោយធ្វើឱ្យមានដំបៅធំ អ្នកបាញ់ទៅយ៉ាងពេញទីនោះ ក្នុងប្រការនេះ មានអធិប្បាយដូច្នេះថា យើងតិះដៀលអ្នកដែលប្រកបដោយអាវុធ មានប្រការផ្សេងៗ ឈ្មោះថា សល្លៈ កូនសរ ព្រោះបាញ់ទៅត្រង់ៗ ដោយមានសណ្ឋានដូចស្លឹកកោមុទជាផល របស់អ្នកបាញ់ទៅយ៉ាងខ្លាំងក្លា ។ បទថា បរិណាយិកា



www.elibraryofcambodia.org

បានដល់ អ្នកជាធំ គឺជាអ្នកចាត់ចែង។ បទថា **ជិគ្ឃិតា** ប្រែថា តិះដៀលហើយ ពាក្យដ៏សេសក្នុងគាថានេះ ងាយទាំងអស់ ។

ខាងមុខតអំពីនេះទៅ ខ្ញុំនឹងមិនពោលពាក្យមានប្រមាណប៉ុណ្ណេះ នឹងពណ៌នាពាក្យដែលលំបាកប៉ុណ្ណោះ។ ព្រះពោធិសត្វកាលសម្ដែងរឿងសម្រាប់តិះដៀល ៣ ប្រការ ដោយគាថាតែម្យ៉ាងនេះហើយ ធ្វើឱ្យមានព្រៃបន្លឺឡើង ហើយសម្ដែងធម៌ដ៏ពីរោះដូចព្រះសម្មាសម្ពុទ្ធ ។

ព្រះសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ។ ក្នុងវេលាចប់សច្ចៈ ភិក្ខុអ្នកពេញចិត្តនឹងការសឹក បានតាំងនៅក្នុងសោតាបត្តិផល ព្រះសាស្ដាបន្តអនុសន្ធិហើយទ្រង់ប្រជុំជាតកថា ម្រឹគភ្នំក្នុងកាលនោះ បានជាភិក្ខុចង់សឹកក្នុងកាលឥឡូវនេះ ចំណែកទេវតាអ្នកឃើញទោសក្នុងកាមទាំងឡាយក្នុងកាលនោះ បានជាតថាគតនេះឯង ។

**កណ្ឌិនជាតកទី ៣ ចប់**



www.elibraryofcambodia.org

## វាតមិគជាតកទី ៤

ន កិរត្ថិ រសេហិ បាបិយោ
អាវាសេហិ វា សន្ថវេហិ វា
វាតមិគំ គហននិស្សិតំ
វសមានេសិ រសេហិ សញ្ជយោតិ ។

( ព្រះរាជាទ្រង់មានព្រះឱង្ការថាឆន្នភាគ ) ដោយអាវាសៈទាំងឡាយ ឬដោយការស្និទ្ធស្នាលទាំងឡាយ ជាសភាវៈលាមកជាងឆន្នភាគ ដោយរសទាំងឡាយមិនមានទេ ឧយ្យានបាលឈ្មោះសញ្ជ័យ បាននាំសត្វឈ្លួស ដែលអាស្រ័យនូវព្រៃស្បាត មកកាន់អំណាច ( របស់ខ្លួន ) បានព្រោះតែរសទាំងឡាយ ។



www.elibraryofcambodia.org

# អដ្ឋកថា ខារតមិគជាតក

ព្រះសាស្ដា កាលទ្រង់គង់ក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធព្រះថេរបិណ្ឌបាតិកតិស្សត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះជាដើមថាៈ **កិរត្តិ រសេហិ ចាបិយោ** ដូច្នេះជាដើម ។

បានឮថា កាលព្រះសាស្ដាទ្រង់គង់នៅនគររាជគ្រឹះ នៅក្នុងវត្តវេឡុវ័ន ថ្ងៃមួយ បុត្ររបស់សេដ្ឋីអ្នកមានទ្រព្យច្រើន ឈ្មោះថាតិស្សកុមារ បានទៅកាន់ព្រះវេឡុវនវិហារ ស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដាហើយ បំណងចង់បួស ទើបទូលសូមបព្វជ្ជា តែមាតាបិតាមិនអនុញ្ញាត ទើបត្រូវបដិសេធ បានអត់អាហារអស់ ៧ ថ្ងៃ ហើយឱ្យមាតាបិតាអនុញ្ញាត ដូចព្រះរដ្ឋបាលត្ថេរ បានបួសក្នុងសម្នាក់របស់ព្រះសាស្ដាហើយ ។ ព្រះសាស្ដា កាលទ្រង់ឱ្យតិស្សកុមារនោះបួសហើយ ប្រថាប់នៅក្នុងវត្តវេឡុវ័នប្រមាណកន្លះខែ រួចស្ដេចបានយាងទៅកាន់វត្តជេតពន កាលនៅក្នុងវត្តជេតពននោះ កុលបុត្រនេះ សមាទាននូវធុតង្គទាំង ១៣ ត្រាច់ទៅបិណ្ឌបាតតាមលំដាប់ច្រក ក្នុងនគរសាវត្ថី ញុំាងកាលវេលាឱ្យកន្លងទៅ នរណាៗ



www.elibraryofcambodia.org

ក៏ហៅថាព្រះចូឡបិណ្ឌបាតិកតិស្សត្ថេរ បានជាអ្នកមាននាមប្រាកដស្គាល់ទូទៅក្នុងព្រះពុទ្ធសាសនា ដូចព្រះចន្ទពេញវង់ ស្ថិតនៅក្នុងផ្ទៃមេឃ ដូច្នោះ ។

ក្នុងកាលនោះ ជាកាលលេងនក្ខត្តឫក្ស ធ្វើដំណើរទៅក្នុងនគររាជគ្រឹះ មាតាបិតារបស់ព្រះថេរៈបានទុករបស់ដែលជាគ្រឿងប្រដាប់លេងដែលមាននៅក្នុងគ្រាព្រះថេរៈនៅជាគ្រហស្ថ ទុកក្នុងប្រអប់ប្រាក់យក មកដាក់ត្រង់ទ្រូង យំបណ្តើរ និយាយបណ្តើរថា ក្នុងការលេងនក្ខត្តឫក្សដទៃៗ បុត្ររបស់ពួកយើងនេះប្រដាប់ដោយគ្រឿងប្រដាប់នេះលេងនក្ខត្តឫក្ស ព្រះសមណគោតមនាំយកបុត្ររបស់យើងទៅកាន់នគរសាវត្ថី ឥឡូវនេះ បុត្ររបស់ពួកយើងទាំងឡាយនោះ អង្គុយទីណាហ្ន៎ ឈរនៅទីណាហ្ន៎ លំដាប់នោះ នាងវណ្ណទាសីម្នាក់ ទៅកាន់ត្រកូលនោះ ឃើញភរិយារបស់សេដ្ឋីកំពុងយំ ទើបសួរថា ម៉ែម្ចាស់ អ្នកយំធ្វើអ្វី ? ទើបភរិយាសេដ្ឋីនោះប្រាប់សេចក្តីនោះ ។ នាងវណ្ណទាសីពោលថា ម៉ែម្ចាស់ លោកម្ចាស់ស្រឡាញ់អ្វី ? ភរិយាសេដ្ឋីពោលថា ស្រឡាញ់របស់នេះ ស្រឡាញ់របស់នោះ។ នាងវណ្ណទាសីពោលថា បើម៉ែម្ចាស់ឱ្យភាពជាធំទាំង



www.elibraryofcambodia.org

អស់ក្នុងផ្ទះនេះដល់នាងខ្ញុំ នាងខ្ញុំនឹងនាំបុត្ររបស់ម៉ែម្ចាស់មក ភរិយាសេដ្ឋីទទួលថា បាន ហើយឱ្យស្បៀង បញ្ជូននាងវណ្ណទាសីទៅដោយបរិវារជាច្រើន ដោយនិយាយថា ចូរនាងទៅនាំបុត្ររបស់យើងមកតាមសមត្ថភាពរបស់ខ្លួន នាងវណ្ណទាសីនោះអង្គុយក្នុងយានតូចដែលបាំងបិទនោះ ទៅកាន់នគរសាវត្ថី កាន់យកការនៅអាស្រ័យជិតថ្នល់ ដែលព្រះថេរៈត្រាច់ទៅដើម្បីភិក្ខាចារ មិនឱ្យព្រះថេរៈឃើញ ពួកមនុស្សដែលមកអំពីត្រកូលសេដ្ឋីហែហមដោយបរិវាររបស់ខ្លួនទាំងនោះ កាលព្រះថេរៈចូលទៅបិណ្ឌបាត បានថ្វាយយាគូមួយបោយ និងភិក្ខាមានរស ពាក់ព័ន្ធដោយការមានចំណង់ក្នុងរសទុកអំពីខាងដើម ហើយឱ្យគង់ក្នុងផ្ទះ ថ្វាយភិក្ខាដោយលំដាប់ ដឹងថា ព្រះថេរៈធ្លាក់ក្នុងអំណោចរបស់ខ្លួន ទើបសម្តែងអាការឈឺ ដេកក្នុងបន្ទប់។ ឯព្រះថេរៈត្រាច់ទៅតាមលំដាប់ច្រក ក្នុងវេលាភិក្ខាចារ បានទៅដល់ទ្វារផ្ទះ ជនដែលជាបរិវារទទួលបាត្ររបស់ព្រះថេរៈ ហើយនិមន្តព្រះថេរៈឱ្យគង់ក្នុងផ្ទះ។ ព្រះថេរៈគង់ហើយ សួរថា ឧបាសិកាទៅណា? ជនជាបរិវារពោលថា លោកម្ចាស់ដ៏ចម្រើន ឧបាសិកាឈឺ ប្រាថ្នានឹងឃើញ



www.elibraryofcambodia.org

លោកម្ចាស់ ព្រះថេរៈត្រូវតណ្ហាក្នុងរសចងជាប់ ទម្លាយការដែលសមាទានវត្តរបស់ខ្លួន ចូលទៅកាន់ទីកន្លែងនាងវណ្ណទាសីកំពុងដេកនោះ នាងវណ្ណទាសីដឹងហេតុនៃការមកដើម្បីខ្លួន ទើបល្បួងលោមព្រះថេរៈនោះ ចងដោយតណ្ហាក្នុងរស ឱ្យសឹកហើយ ឱ្យតាំងនៅក្នុងអំណាចរបស់ខ្លួន ឱ្យអង្គុយក្នុងយាន បានទៅកាន់ក្រុងរាជគ្រឹះនោះឯង ដោយបរិវារជាច្រើន ដំណឹងនោះបានប្រាកដហើយ ។

ភិក្ខុទាំងឡាយ បានអង្គុយប្រជុំគ្នាក្នុងរោងធម្មសភា សន្ទនាគ្នាថា បានឮថា នាងវណ្ណទាសីម្នាក់ ចងព្រះចូឡបិណ្ឌបាតិកតិស្សៈដោយតណ្ហាក្នុងរស បាននាំទៅហើយ ព្រះសាស្តាបានយាងចូលទៅកាន់រោងធម្មសភា ទ្រង់ប្រថាប់លើអាសនៈដែលគេតាក់តែងទុកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី? ភិក្ខុទាំងនោះក្រាបទូលរឿងរ៉ាវនោះ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ ជាប់ក្នុងរសតណ្ហាទាំងឡាយ ធ្លាក់នៅក្នុងអំណោចរបស់នាងវណ្ណទាសីនោះ ក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនក៏ធ្លាក់ក្នុងអំណាចរបស់នាងដូចគ្នា ហើយទ្រង់នាំអតីតនិទានមកថា :



www.elibraryofcambodia.org

ក្នុងអតីតកាល នៅក្នុងនគរពារាណសី មាននាយឧទ្យាន ម្នាក់ អ្នករក្សាឧទ្យានរបស់ព្រះបាទព្រហ្មទត្ត ឈ្មោះថា សញ្ជ័យ គ្រានោះ មានសត្វឈ្លូសមួយក្បាលមកកាន់ឧទ្យាននោះ ឃើញ នាយរក្សាឧទ្យាន ទើបរត់គេចចេញទៅ ចំណែកនាយសញ្ជ័យមិន បានគំរាមសត្វឈ្លូសនោះឱ្យចេញទៅទេ សត្វឈ្លូសនោះ ទើបមក លេងក្នុងឧទ្យាននោះឯងជារឿយៗ នាយរក្សាឧទ្យាននាំយកផ្កា ឈើ និងផ្លែឈើមានប្រការផ្សេងៗ មកអំពីឧទ្យានតាំងពីព្រលឹម នាំទៅថ្វាយព្រះរាជារៀងរាល់ថ្ងៃ។ លុះថ្ងៃមួយ ព្រះរាជាត្រាស់ សួរនាយឧទ្យានបាលនោះថា ម្នាលឧទ្យានបាល អ្នកឃើញសេចក្តី អស្ចារ្យអ្វីនៅក្នុងឧទ្យានខ្លះទេ ? នាយឧទ្យានបាលក្រាបទូលថា បពិត្រសម្មតិទេព ខ្ញុំព្រះអង្គមិនបានឃើញរឿងដទៃ តែមានសត្វ ឈ្លូសមួយក្បាលមកលេងក្នុងឧទ្យាន ខ្ញុំព្រះអង្គបានឃើញរឿង នេះ ព្រះរាជាត្រាស់សួរថា តើអ្នកអាចចាប់វាបានទេ ? នាយ ឧទ្យានបាលក្រាបទូលថា កាលខ្ញុំព្រះអង្គបានទឹកឃ្មុំបន្តិចបន្តួចនឹង អាចនាំសត្វឈ្លូសនោះមក ក្នុងព្រះរាជនិវេសន៍នេះ ព្រះរាជាបាន ឱ្យទឹកឃ្មុំដល់នាយឧទ្យានបាលនោះ។ នាយឧទ្យានបាលទទួលទឹក ឃ្មុំហើយ ទៅកាន់ឧទ្យាន រួចយកទឹកឃ្មុំលាបស្មៅទាំងឡាយក្នុង



www.elibraryofcambodia.org

ទីកន្លែងសត្វឈ្លូសត្រាច់ទៅ ។ សត្វឈ្លូសមកស៊ីស្មៅកន្លែងលាប ដោយទឹកឃ្មុំ ជាប់ក្នុងរសតណ្ហា មិនទៅទីដទៃ មកឆ្ពោះឧទ្យាន នោះប៉ុណ្ណោះ។ នាយឧទ្យានបាលបានដឹងថា សត្វឈ្លូសនេះ ជាប់ ក្នុងរសស្មៅលាបដោយទឹកឃ្មុំ ទើបសម្តែងខ្លួនឱ្យឃើញដោយ លំដាប់។ សត្វឈ្លូសនោះកាលឃើញនាយឧទ្យានបាល ២-៣ ថ្ងៃ ដំបូងគេចទៅ លុះឃើញញយៗ ទើបស្គាល់ ស៊ីស្មៅដែលនៅក្នុង ដៃរបស់នាយឧទ្យានបាលដោយលំដាប់។ នាយឧទ្យានបាលដឹងថា សត្វឈ្លូសនោះស្គាល់ ( ស៊ាំង ) ហើយ ទើបយកផ្ទាំងក្រណាត់បាំង ថ្កល់ រហូតដល់ព្រះរាជនិវេសន៍ ហើយយកមែកឈើបាក់ៗ ទុកក្នុង ទីនោះៗ ស្ពាយផ្លែឃ្លោកដែលផ្ទុកទឹកឃ្មុំ ក្បៀបបាច់ស្មៅ ហើយ រោយស្មៅដែលលាបដោយទឹកឃ្មុំចុះខាងមុខ។ ម្រឹគបានទៅកាន់ ខាងក្នុងព្រះរាជនិវេសន៍ កាលម្រឹគចូលទៅខាងក្នុងហើយ ទើប មនុស្សទាំងឡាយបិទទ្វារ ម្រឹគឃើញមនុស្សទាំងឡាយ ខ្លួនញ័រ ខ្លាចដល់មរណភ័យ រត់ទៅរត់មក ក្នុងព្រះលានក្នុងរាជនិវេសន៍ ព្រះរាជាស្តេចចុះអំពីប្រាសាទ ឃើញសត្វឈ្លូសនោះភ័យ ទើប ត្រាស់ថា ធម្មតាសត្វរមែងមិនទៅកាន់ទីដែលមានមនុស្ស រមែង មិនទៅកាន់ទីត្រូវគំរាមរហូតអស់មួយជីវិត សត្វឈ្លូសដែលអាស្រ័យ



www.elibraryofcambodia.org

នៅក្នុងព្រៃបែបនេះ សត្វនោះត្រូវចងដោយចំណង់ក្នុងរស មកកាន់ទីបែបនេះ ក្នុងឥឡូវនេះ អ្នកដ៏ចម្រើនទាំងឡាយ ដែលឈ្មោះថា វត្ថុដ៏លាមកជាងចំណង់ក្នុងរស រមែងមិនមានក្នុងលោកហ្ន៎ ទ្រង់ផ្តើមព្រះធម្មទេសនាដោយគាថានេះថា :

**ដោយអាវាសៈទាំងឡាយ ឬដោយការស្និទ្ធស្នាល**

**ទាំងឡាយ ជាសភាវៈលាមកជាងឆន្ទរាគ ដោយ**

**រសទាំងឡាយមិនមានទេ ឧយ្យានបាលឈ្មោះ**

**សញ្ជ័យបាននាំសត្វឈ្លូស ដែលអាស្រ័យនៅព្រៃ**

**ស្បាតមកកាន់អំណាច ( របស់ខ្លួន ) បានព្រោះតែ**

**រសទាំងឡាយ ។**

សព្ទថា *កិរ* បានឮថា ក្នុងគាថានេះ ជានិបាតប្រើក្នុងអត្ថថា បានឮ បានស្តាប់ ។

បទថា *រសេហិ* ជាងរសទាំងឡាយ សេចក្តីថា ជាងរសផ្អែម និងរសជូជាដើម ដែលគប្បីដឹងដោយក្លិន ។

បទថា *ធាបិយោ* ប្រែថា អាក្រក់ជាង ។

បទថា *អាវាសេហិវាសន្ថវេហិវា* សូម្បីជាងកន្លែង



www.elibraryofcambodia.org

ដែលរស់នៅសូម្បីជាងសេចក្តីស្និទ្ធស្នាល សេចក្តីថា សេចក្តីរីករាយដោយអំណាចសេចក្តីពេញចិត្តក្នុងកន្លែងដែលមានរស់នៅ គឺកន្លែងរស់នៅ មានប្រចាំថ្ងៃក្តី ក្នុងការស្និទ្ធស្នាលដោយអំណាចភាពជាមិត្តក្តី លាមកពិត តែរសក្នុងការបរិភោគដែលប្រព្រឹត្តទៅជាមួយឆន្ទរាគៈនោះឯង ជាសភាវៈអាក្រក់ជាងទីដែលរស់នៅ ជាងការស្និទ្ធស្នាលដោយភាពជាមិត្ត ដែលមានការបរិភោគដោយឆន្ទរាគៈទាំងនេះ ដោយរយដោយពាន់ ព្រោះអត្ថថា ត្រូវសេពជាប្រចាំ និងព្រោះវៀរចាកអាហារ ការរក្សាជីវិតិន្ទ្រិយក៏មិនមានព្រះពោធិសត្វទ្រង់ធ្វើសេចក្តីនេះឱ្យដូចសត្វឈ្លូស ដែលតាមមកដោយល្អ ទើបត្រាស់ថាបានឮថា សភាវៈដែលអាក្រក់ជាងរសទាំងឡាយ រមែងមិនមាន រសជាសភាវៈលាមកជាងទីរស់នៅ ជាងសេចក្តីស្និទ្ធស្នាលឥឡូវនេះ ព្រះពោធិសត្វកាលនឹងសម្តែងថា រសទាំងនោះលាមកទើបត្រាស់ពាក្យមានជាដើមថា **វាតមិគ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គហនសិស្សិតំ** ប្រែថាអាស្រ័យដែលជាព្រៃស្បាត លោកអធិប្បាយទុកថា អ្នកទាំងឡាយចូរមើលរសទាំងឡាយ ជាសភាវៈលាមក នាយសញ្ជ័យឧទ្យានបាល



www.elibraryofcambodia.org

នាំសត្វឈ្លូសឈ្មោះនេះ ដែលអាស្រ័យនៅក្នុងព្រៃស្បាត មកកាន់អំណាចរបស់ខ្លួនដោយរសទឹកឃ្មុំ វត្ថុដទៃដែលលាមកជាង គឺអាក្រក់ជាង ឈ្មោះថា លាមកជាងរសទាំងឡាយ ដែលមានការបរិភោគដោយឆន្ទរាគៈ រមែងមិនមាន ដោយប្រការទាំងពួង ។ ព្រះពោធិសត្វត្រាស់ថា ទោសនៃតណ្ហាក្នុងរសដោយប្រការដូច្នេះ កាលត្រាស់ហើយ ទើបទ្រង់ឱ្យបញ្ជូនសត្វនោះទៅកាន់ព្រៃនោះឯងវិញ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នាងវណ្ណទាសីអ្នកចងភិក្ខុនោះដោយតណ្ហាក្នុងរស ធ្វើឱ្យធ្លាក់ក្នុងអំណាចរបស់ខ្លួនក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏បានធ្វើហើយដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកបន្តអនុសន្ធិហើយ ទ្រង់ប្រជុំជាតកថា នាយសញ្ជ័យក្នុងកាលនោះ បានជានាងវណ្ណ-ទាសីនេះសត្វឈ្លូសក្នុងកាលនោះ បានជាចូឡបិណ្ឌបាតិកតិស្សត្ថេរ ចំណែកព្រះបាទពារាណសី បានជាតថាគតនេះឯង ។

**វាតមិគជាតកទី ៤ ចប់**



www.elibraryofcambodia.org

## ខរាទិយជាតកទី ៥

**អដ្ឋក្ខុរំ ខរាទិយេ មិគំ វង្កាតិវង្កិនំ**
**សត្តកាលេហតិក្កន្តំ ន នំ ឱវទិតុស្សហេតិ។**

( ម្រឹគពោធិសត្វពោលថា ) ម្នាលនាងខរាទិយា យើងមិនអាចទូន្មានម្រឹគ មានក្រចក ៨ មានស្នែងវៀចគល់ និងស្រួចចុងដ៏ក្រៃលែង ជាសត្វកន្លងនូវកាលនៃដំបូន្មាន ៧ នោះបានឡើយ ។

## អដ្ឋកថា ខរាទិយជាតក

ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុរឹងត្អឹងមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានផ្តើមពាក្យថា **អដ្ឋក្ខុរំ ខរាទិយេ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះរឹងត្អឹងមិនទទួលឱវាទ លំដាប់នោះ ព្រះ



www.elibraryofcambodia.org

សាស្តាបានត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ តថាគតបានឮថា អ្នកជាអ្នកចចេសរឹងត្អឹងមិនទទួលឱវាទពិតឬ ? ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពិត ព្រះអង្គ។ ព្រះសាស្តាទ្រង់ត្រាស់ថា សូម្បីក្នុងកាលមុន អ្នកក៏មិនទទួលឱវាទរបស់បណ្ឌិតទាំងឡាយដូច្នេះដែរ ព្រោះភាពជាអ្នករឹងត្អឹងនេះហើយ ទើបអ្នកជាប់អន្ទាក់ដល់នូវការអស់ជីវិត រួចព្រះអង្គទ្រង់នាំអតីតនិទានមកថា :

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វ ជាម្រឹគហែហមដោយពួកម្រឹគក្នុងព្រៃលំដាប់នោះ ម្រឹគញីជាប្អូននោះបានបង្ហាញកូនតូច ហើយឱ្យទទួលយកដោយពាក្យថា បពិត្របងប្រុសនេះជាក្មួយរបស់បង សូមបងបង្រៀនមាយារបស់ម្រឹគណាមួយ ម្រឹគនោះពោលនឹងក្មួយនោះថា ក្នុងវេលាថ្មើរនេះ អ្នកចូរមករៀននូវមាយាចុះ ម្រឹគជាក្មួយមិនមកតាមវេលាដែលនិយាយទុក វេលាកន្លងទៅ ៧ ថ្ងៃ សូម្បីមួយថ្ងៃក៏ក្មួយមិនបានរៀនមាយារបស់ម្រឹគចាស់ដែរ ត្រាច់ទៅ ទើបជាប់អន្ទាក់ ឯមាតារបស់ម្រឹគនោះ ចូលទៅរកម្រឹគជាបងប្រុសហើយសួរថា បងប្រុសតើបងឱ្យក្មួយរៀនមាយារបស់ម្រឹគហើយឬ ? ព្រះពោធិសត្វពោលថា នាងកុំគិតខូចចិត្តថ្មីចំពោះបុត្ររបស់



www.elibraryofcambodia.org

នាង បុត្រនាងមិនព្រមទទួលឱវាទនោះ បុត្ររបស់នាងមិនរៀន យកមាយារបស់ម្រឹគខ្លួនឯង មិនមែនជាអ្នកមិនប្រាថ្នានឹងឱវាទម្រឹគនោះឡើយ ទើបពោលគាថានេះថា :

**ម្នាលនាងខរាទិយា យើងមិនអាចទូន្មានម្រឹគមាន**
**ក្រចក ៨ មានស្នែងវៀចគល់ និងស្រួចចុងដ៏ក្រៃលែង**
**ជាសត្វកន្លងនូវកាលនៃឱវាទ ៧ បានឡើយ ។**

បណ្តាបទទាំងនេះ បទថា **អដ្ឋក្ខុរំ** បានដល់ មានក្រចក ៨ ដោយជើងមុខនីមួយៗ មានក្រចកពីរ ព្រះពោធិសត្វហៅនាងម្រឹគនោះដោយ ឈ្មោះថា **ខរាទិយា** ។

បទថា **មិគំ** ជាពាក្យរួមយកម្រឹគគ្រប់ប្រភេទ ។

បទថា **វង្កាតិវង្កិនំ** បានដល់ ស្នែងវៀចជាងស្នែង គឺតាំងពីគល់ស្នែងទៅដល់ចុងស្នែង ឈ្មោះថា អ្នកមានស្នែងវៀចតាំងពីគល់រហូតដល់ចុងស្នែង ព្រោះម្រឹគមានស្នែងដូច្នេះ ។ ទើបឈ្មោះថាស្នែងវៀចតាំងពី គល់រហូតដល់ចុងស្នែង គឺមានស្នែងវៀចតាំងពីគល់ស្នែងរហូតដល់ចុង ស្នែងនោះឯង ។



www.elibraryofcambodia.org

បទថា **សត្តកាលេហាតិក្កន្តំ** បានដល់ អ្នកកន្លងនូវឱវាទ ដោយវេលាជាកន្លែងឱ្យឱវាទ ៧ ថ្ងៃ។ ដោយបទថា **ឯតំ ឱវទិតុស្សហេ** នេះ លោកសម្តែងថា យើងមិនអាចឱ្យឱវាទដល់ម្រឹគអ្នករឹងត្អឹងនេះ សូម្បីនឹងគិតដើម្បីឱ្យឱវាទម្រឹគនេះ ក៏មិនកើតឡើងដល់យើង ។

កាលនោះ នាយព្រានសម្លាប់ម្រឹគរឹងត្អឹងនោះ ដែលជាប់អន្ទាក់ កាន់យកសាច់ហើយចៀសចេញទៅ ។

ចំណែកព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ អ្នកជាអ្នករឹងត្អឹងលំបាកទូន្មាន មិនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ជាអ្នករឹងត្អឹងដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកបន្តអនុសន្ធិហើយ ទ្រង់ប្រជុំជាតកថា ម្រឹគជាក្មួយក្នុងកាលនោះបានជាភិក្ខុអ្នកប្រដៅដោយលំបាកក្នុងកាលឥឡូវនេះ មេម្រឹគប្អូនស្រីក្នុងកាលនោះ បានជាព្រះឧបលវណ្ណាក្នុងកាលឥឡូវនេះ ឯម្រឹគអ្នកឱ្យឱវាទក្នុងកាលនោះ បានជាតថាគតនេះឯង ។

**ខរាទិយជាតកទី ៥ ចប់**



www.elibraryofcambodia.org

# តិបល្លត្ថមិគជាតកទី ៦

មិគំ តិបល្លត្ថមនេកមាយំ

អដ្ឋក្ខុរំ អឌ្ឍរត្តាបចាយិំ

ឯកេន សោតេន ឆមាស្សសន្តោ

ឆហិ កលាហាតិភោតិ ភាគិនេយ្យោតិ។

(ម្រឹគពោធិសត្វពោលថា) អញបានញុំាងម្រឹគមានដំណេក ៣ មានក្រចក ៨ ជាសត្វផឹកទឹកក្នុងពេលអធ្រាត្រ ឱ្យរៀនមាយាច្រើនហើយ ម្រឹគជាក្មួយបានដកដង្ហើមខ្ចប់នឹងផែនដី ដោយរន្ធច្រមុះម្ខាង បញ្ឆោត (ព្រានព្រៃ) ដោយកល ៦ យ៉ាង។



www.elibraryofcambodia.org

# អដ្ឋកថា តិបល្លត្ថមិគជាតក

ព្រះសាស្តា កាលប្រថាប់នៅក្នុង **ពទរិការាម** នគរកោសម្ពី ទ្រង់ប្រារព្ធព្រះរាហុលត្ថេរ អ្នកប្រាថ្នាចំពោះការសិក្សា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **មិគំ តិបល្លត្ថំ** ដូច្នេះ ។

សេចក្តីពិស្តារថា គ្រាមួយ ពេលព្រះសាស្តាស្តេចយាងចូលទៅអាស្រ័យក្នុងក្រុងអាឡវី ប្រថាប់នៅក្នុងអគ្គាឡវចេតិយ ឧបាសក ឧបាសិកា ភិក្ខុ និងភិក្ខុនីចំនួនច្រើន ទៅកាន់វិហារដើម្បីស្តាប់ធម៌ ។ ពេលពាក់កណ្តាលថ្ងៃ មានការស្តាប់ធម៌ ឯពេលវេលាកន្លងទៅ ឧបាសិកា និងភិក្ខុនីទាំងឡាយមិនទៅ មានតែពួកភិក្ខុ និងឧបាសកប៉ុណ្ណោះ ចាប់តាំងពីពេលនោះមក ទើបកើតមានការស្តាប់ធម៌នៅពេលពាក់កណ្តាលយប់ ក្នុងវេលាសម្រេចការស្តាប់ធម៌ ភិក្ខុទាំងឡាយជាថេរៈ នាំគ្នាទៅកាន់ទីកន្លែងរបស់ខ្លួន ភិក្ខុកម្លោះ និងពួកឧបាសក ដេកនៅត្រង់ឧបដ្ឋានសាលា គឺរោងឆាន់ ។ កាលពួកភិក្ខុកម្លោះ និងពួកឧបាសកទាំងនោះចូលដល់ការលង់លក់



www.elibraryofcambodia.org

អ្នកខ្លះដេកស្រមុកសំឡេងគ្រឺតៗ ដេកមមើ ពួកខ្លះដេកមួយស្របក់ហើយក្រោកឡើង។ ពួកឧបាសកឃើញអាការប្លែករបស់ភិក្ខុកម្លោះ ទើបក្រាបទូលដល់ព្រះមានព្រះភាគ ។

ព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា បើភិក្ខុណាដេករួមជាមួយនឹងអនុបសម្បន្ន ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ដូច្នេះហើយ ស្ដេចបានយាងទៅកាន់នគរកោសម្ពី ក្នុងសេចក្ដីដែលទ្រង់បញ្ញត្តសិក្ខាបទនោះ ទើបភិក្ខុទាំងឡាយពោលនឹងរាហុលថា អាវុសោរាហុល ព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទទុកហើយឥឡូវនេះ លោកចូរដឹងទីនៅរបស់ខ្លួន។ កាលមុនភិក្ខុទាំងឡាយបានសង្គ្រោះរាហុលនោះដែមកកាន់ទីនៅរបស់ខ្លួនយ៉ាងល្អ ព្រោះអាស្រ័យការគោរពក្នុងព្រះមានព្រះភាគ និងការដែលរាហុលនោះជាអ្នកមានសេចក្ដីប្រាថ្នាចំពោះការសិក្សា បានលាតគ្រែតូច ដាក់ចីវរដើម្បីកល់សីសៈ។ បន្ទាប់ថ្ងៃនោះ សូម្បីទីនៅមាន ក៏មិនបានឱ្យ ព្រោះខ្លាចចំពោះសិក្ខាបទ។ ឯព្រះរាហុលក៏មិនទៅកាន់សម្នាក់របស់ព្រះទសពល ដោយគិតថាជា បិតារបស់យើង ឬរបស់ព្រះ



www.elibraryofcambodia.org

ធម្មសេនាបតី ដោយគិតថា ជាឧបជ្ឈាយ៍របស់យើង ឬរបស់ព្រះមហាមោគ្គល្លាន ដោយគិតថា ជាអាចារ្យរបស់យើង ឬរបស់ព្រះអានន្ទ ដោយគិតថា ជាពូរបស់យើង ហើយបានចូលទៅកាន់វច្ចកុដិសម្រាប់ព្រះទសពល ។ ប្រៀបដូចចូលទៅកាន់វិមានរបស់ព្រហ្មសម្រេចការនៅហើយ ។ ទ្វារវច្ចកុដិសម្រាប់ប្រើប្រាស់របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយ ដែលបិទជិតនោះ ធ្វើការប្រោះព្រំដោយគ្រឿងក្រអូប មានកម្រងផ្កា និងប្រទីបទាំងយប់ ទាំងថ្ងៃ ។ ព្រះរាហុលអាស្រ័យសម្បត្តិនេះនៃកុដិនោះ ទើបចូលទៅនៅក្នុងវច្ចកុដិនោះ ។ម្យ៉ាងទៀត ព្រោះភិក្ខុទាំងឡាយពោលថា អ្នកចូរដឹងទីនៅ និងព្រោះភាពជាអ្នកប្រាថ្នាចំពោះការសិក្សា ដោយគោរពក្នុងឱវាទទើបចូលទៅនៅក្នុងវច្ចកុដិនោះ ក្នុងរវាងភិក្ខុទាំងឡាយ ឃើញលោកអ្នកមានអាយុនោះមកអំពីចម្ងាយ ដើម្បីត្រូវការសាកល្បងលោកអ្នកមានអាយុនោះ ទើបបោះបង់ល្អីកឈើ ឬភាជនៈសំរាប់ចោលទុកខាងក្នុង កាលលោកអ្នកមានអាយុនោះមកដល់ ទើបពោលថា អាវុសោ នរណាចោលរបស់នេះ ? ក្នុងការធ្វើនោះ



www.elibraryofcambodia.org

ភិក្ខុពួកខ្លះពោលថា រាហុលមកតាមផ្លូវនេះ ។ តែរាហុលមិនពោលថា លោកម្ចាស់ដ៏ចម្រើនខ្ញុំ មិនដឹងរឿងនេះទេ តែត្រឡប់ជាប្រមូលវត្ថុនោះ ហើយសូមខមាទោសថា លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយអត់ទោសដល់ខ្ញុំផងហើយ ទើបចៀសចេញទៅ ព្រះរាហុលជាអ្នកប្រាថ្នាចំពោះការសិក្សាយ៉ាងនេះ ។ ព្រះរាហុលជាអ្នកប្រាថ្នាការសិក្សានោះឯង។ ទើបចូលទៅក្នុងវច្ចកុដិនោះ។

វេលាមុនអរុណរះឡើង ព្រះសាស្តា ប្រថាប់ឈរត្រង់ទ្វារវច្ចកុដិ ហើយទ្រង់ព្រះគ្រហែមឡើង ឯរាហុលមានអាយុនោះ ក៏គ្រហែមឡើង ព្រះសាស្តាត្រាស់សួរថា នរណោនេះ ? ព្រះរាហុលក្រាបទូលថា ខ្ញុំព្រះអង្គរាហុល ហើយក៏ចេញមកថ្វាយបង្គំ ព្រះសាស្តាត្រាស់សួរថា រាហុល ហេតុអ្វី ទើបអ្នកដេកនៅទីនេះ ? ព្រះរាហុលក្រាបទូលថា ព្រោះមិនមានទីកន្លែងនៅ បពិត្រព្រះអង្គដ៏ចម្រើន កាលមុន ភិក្ខុទាំងឡាយធ្វើសេចក្តីសង្គ្រោះដល់ខ្ញុំព្រះអង្គ តែឥឡូវនេះ មិនមានទីកន្លែងស្នាក់នៅ ព្រោះខ្លាចខ្លួនត្រូវអាបត្តិ ខ្ញុំព្រះអង្គគិតថា ទីនេះជាកន្លែងមិនចង្អៀតដល់អ្នកដទៃ ដោយ



www.elibraryofcambodia.org

ហេតុនេះ ទើបដេកក្នុងទីនេះ។ លំដាប់នោះ ព្រះមានព្រះភាគ កើតធម្មសង្វេគកើតឡើងថា ខាងដើម ភិក្ខុទាំងឡាយ លះបង់រាហុលបានយ៉ាងនេះ ( តទៅ ) ឱ្យក្មេងក្នុងត្រកូលទាំងឡាយដទៃបួសហើយ នឹងធ្វើដូចម្តេច ។

លំដាប់នោះ ព្រះមានព្រះភាគ ឱ្យភិក្ខុទាំងឡាយប្រជុំគ្នាអំពីព្រលឹម ហើយត្រាស់សួរព្រះធម្មសេនាបតីថា សារីបុត្រ តើអ្នកដឹងទេ ថ្ងៃនេះ រាហុលនៅកន្លែងណា ? ព្រះសារីបុត្រក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានដឹងទេ ព្រះអង្គ។ ព្រះសាស្តាត្រាស់ថា សារីបុត្រ ថ្ងៃនេះ រាហុលនៅត្រង់វច្ចកុដិ ម្នាលសារីបុត្រ អ្នកទាំងឡាយលះបង់រាហុលបានយ៉ាងនេះ ( តទៅខាងមុខ ) ឱ្យក្មេងត្រកូលទាំងឡាយពួកដទៃបួសហើយ នឹងធ្វើដូចម្តេច កាលបើដូច្នោះ កុលបុត្រអ្នកបួសក្នុងព្រះពុទ្ធសាសនានេះនឹងជាអ្នកមិនមានទីពឹង ឥឡូវនេះ តាំងពីពេលនេះទៅ អ្នកទាំងឡាយចូរឱ្យអនុបសម្បន្នទាំងឡាយ នៅក្នុងសម្នាក់របស់ខ្លួនមួយថ្ងៃ ពីរថ្ងៃ ក្នុងថ្ងៃទីបី ចូរដឹងទីកន្លែងជាទីនៅរបស់អនុបសម្បន្នទាំងនោះ



www.elibraryofcambodia.org

ហើយឱ្យចូរនៅខាងក្រៅ ដូច្នេះហើយ ទ្រង់បញ្ញត្តសិក្ខាបទទៀត ទ្រង់ធ្វើឱ្យជាអនុប្បញ្ញត្តិក្នុងសេចក្តីនេះ ។

សម័យនោះ ភិក្ខុទាំងឡាយ អង្គុយប្រជុំគ្នាក្នុងរោងធម្ម-សភា ហើយពោលគុណរបស់រាហុលថា ចូរមើលចុះលោកដ៏មានអាយុទាំងឡាយ រាហុលនេះ ប្រាថ្នាតែចំពោះការសិក្សាជាកំណត់ ត្រូវភិក្ខុទាំងឡាយពោលថា អ្នកចូរដឹងទីនៅរបស់អ្នក ក៏មិនតបតភិក្ខុរូបណាឡើយថា យើងជាឱរសរបស់ព្រះទសពល លោកម្ចាស់ទាំងឡាយជានរណា ពួកលោកម្ចាស់នោះឯង សូមចេញទៅ ដូច្នេះហើយ បានសម្រេចការនៅក្នុងវច្ចកុដិនោះ។ កាលភិក្ខុទាំងនោះនាំគ្នាពោលយ៉ាងនេះ ព្រះសាស្តាក៏យាងចូលទៅកាន់រោងធម្មសភាប្រថាប់លើអាសនៈដែលតាក់តែងទុក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី? ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គអង្គុយសន្ទនាគ្នាដោយសិក្ខាកាមកថា ពោលដោយសេចក្តីប្រាថ្នាចំពោះការសិក្សារបស់ព្រះរាហុល មិនមែនដោយរឿងដទៃឡើយ



www.elibraryofcambodia.org

ព្រះអង្គ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រាហុល ជាអ្នកប្រាថ្នាចំពោះការសិក្សា ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេ សូម្បីក្នុងកាលមុន កាលកើតក្នុងកំណើតតិរច្ឆាន ក៏ជាអ្នកប្រាថ្នាចំពោះការសិក្សាដូចគ្នា ហើយទ្រង់នាំអតីតនិទានមកថា :

ក្នុងអតីតកាល ព្រះបាទមគធៈរាជមួយព្រះអង្គ គ្រប់គ្រងរាជសម្បត្តិនៅក្នុងនគររាជគ្រឹះ ក្នុងកាលនោះ ព្រះពោធិសត្វកើតក្នុងកំណើតម្រឹគ ដែលពួកម្រឹគហែហមនៅក្នុងព្រៃ។ ក្នុងកាលនោះមេម្រឹគជាប្អូនស្រីរបស់ព្រះពោធិសត្វនោះ នាំបុត្រតូចរបស់ខ្លួនចូលមកកាន់សម្នាក់ព្រះពោធិសត្វ ហើយពោលថា បពិត្របងប្រុសសូមបងឱ្យក្មួយរបស់បង សិក្សាមាយារបស់ម្រឹគផង។ ព្រះពោធិ-សត្វទទួលពាក្យ ហើយពោលថា នែក្មួយ ក្មួយចូរទៅក្នុងវេលាឈ្មោះនោះ ក្មួយចូរមកសិក្សា។ ម្រឹគជាក្មួយនោះ មិនកន្លងវេលាដែលអ៊ំប្រាប់ ក៏ចូលទៅរកអ៊ំ ហើយសិក្សាមាយារបស់ម្រឹគ។ ថ្ងៃមួយ ម្រឹគនោះត្រាច់ទៅក្នុងព្រៃ ជាប់អន្ទាក់ ទើបស្រែកប្រាប់ឱ្យដឹងថាជាប់អន្ទាក់ ពួកម្រឹគនាំគ្នាគេចទៅប្រាប់ដល់មាតារបស់ម្រឹគ



www.elibraryofcambodia.org

នោះថា បុត្ររបស់នាងជាប់អន្ទាក់ហើយ ទើបមេម្រឹគទៅកាន់សម្នាក់របស់បងប្រុស ហើយសួរថា បងប្រុស តើបងឱ្យក្មួយសិក្សាអំពីមាយារបស់ម្រឹគហើយឬនៅ ? ព្រះពោធិសត្វពោលថា នាងកុំរង្កៀសកម្មដ៏លាមកអ្វីៗ របស់បុត្រនាងឡើយ យើងឱ្យបុត្ររបស់នាងសិក្សាមាយារបស់ម្រឹគយ៉ាងល្អហើយ ឥឡូវនេះ បុត្ររបស់នាងនឹងរួចអំពីអន្ទាក់នោះហើយគេចទៅ នឹងត្រឡប់មក ហើយទើបពោលនូវគាថានេះថា :

**អញបានញុំាងម្រឹគ មានដំណោក ៣ មានក្រចក ៨ ជាសត្វផឹកទឹកក្នុងពេលអធ្រាត្រ ឱ្យរៀនមាយាច្រើនហើយ ម្រឹគជាក្មួយបានដកដង្ហើមខ្ចប់នឹងផែនដី ដោយរន្ធច្រមុះម្ខាង បញ្ឆោត ( ព្រានព្រៃ ) ដោយកល ៦ យ៉ាង ។**

បណ្តាបទទាំងនោះ បទថា **មិគំ** បានដល់ម្រឹគអ្នក ជាក្មួយ។ បទថា **តិបល្លត្ថំ** សេចក្តីថា ការដេក ហៅថា បល្លត្ថៈ ឈ្មោះថា អ្នកមានការដេកដោយអាការ ៣ យ៉ាង គឺដោយខាងទាំងពីរ និងដោយអាការដែលដេកត្រង់ ម្យ៉ាងទៀត ព្រោះមាន



www.elibraryofcambodia.org

ការដេកដោយអាការ ៣ យ៉ាងនេះ ដែលម្រឹគនោះអ្នកមានការដេក ៣ យ៉ាង។ បទថា **អនេកមាយំ** បានដល់ មានមាយាច្រើន គឺមានល្បិចកលច្រើន។ បទថា **អដ្ឋក្ខុរំ** បានដល់ អ្នកប្រកបដោយក្រចក ៨ ដោយជើងម្ខាងៗ មានក្រចក ២ ។

បទថា **អឌ្ឍរត្តាបចាយិំ** សេចក្តីថា ម្រឹគឈ្មោះនេះផឹកទឹកក្នុងវេលាអធ្រាត្រ ព្រោះផុតយាមដំបូងទៅហើយ ក្នុងវេលាមជ្ឈិមយាម ទើបមកអំពីព្រៃ ហើយផឹកទឹក ព្រោះហេតុនោះទើបឈ្មោះថា ផឹកទឹកក្នុងវេលាអធ្រាត ។ គឺម្រឹគនោះ ។

អធិប្បាយថា ម្រឹគដែលផឹកទឹកក្នុងវេលាអធ្រាត្រ ។ យើងឱ្យម្រឹគជាក្មួយប្រុសរបស់យើង រៀនមាយារបស់ម្រឹគល្អហើយ ។ សួរថា ឱ្យរៀនដូចម្តេច ? ឆ្លើយថា ម្នាលប្អូនស្រី យើងឱ្យរៀនដោយប្រការដែលម្រឹគជាក្មួយប្រុសដកដង្ហើមខ្ទប់ផ្ទៃផែនដី ដោយរន្ធច្រមុះម្ខាង បញ្ឆោតនាយព្រាន ដោយកល ៦ ប្រការ លោកពោលអធិប្បាយទុកថា យើងឱ្យបុត្ររបស់នាងរៀនយកហើយ ដោយប្រការ ដែលម្រឹគជាក្មួយប្រុសបិទខ្យល់ក្នុងរន្ធច្រមុះផ្នែក



www.elibraryofcambodia.org

ខាងលើម្ខាង ហើយដកដង្ហើមត្រង់ផ្ទៃដីនោះឯង ដោយរន្ធច្រមុះផ្នែកខាងក្រោមម្ខាងដែលជាប់នឹងដី ទើបបិទ អធិប្បាយថា ទើបបញ្ឆោតនាយព្រានដោយកល ៦ ប្រការ គឺដោយចំណែក ៦ យ៉ាង តើកល ៦ ប្រការដូចខ្លះ ? កល ៦ ប្រការ គឺដោយការសណ្ដូកជើងបួនដេកផ្ទៀង ១ ដោយការប្រើក្រចកទាំងឡាយកកាយស្មៅ និងដីបាក់ ១ ដោយធ្វើអណ្ដាតលានចេញមក ១ ដោយការបិទខ្យល់ ១ ដោយការធ្វើពោះឱ្យប៉ោង ១ ដោយការបញ្ចេញឧច្ចារបស្សាវៈឱ្យចេញមក ១ ។

ម្យ៉ាងទៀត លោកសម្ដែងថា នែប្អូនស្រី យើងឱ្យម្រឹគជាកូនប្រុសនោះ រៀនមាយារបស់ម្រឹគហើយដោយការ ដែលគេនឹងបញ្ឆោតធ្វើឱ្យនាយព្រានយល់ថា ម្រឹគនេះស្លាប់ហើយ ដោយកល ៦ ប្រការនេះ គឺដោយការកកាយយកអាចម៍ដីមកទុកខាងមុខ ១ ដោយការធ្វើខ្លួនឱ្យទន់ ១ ដោយការធ្វើពោះឱ្យប៉ោងឡើង ១ ដោយការធ្វើពោះឱ្យបាក់ចុះ ១ ដោយការធ្វើជើងឱ្យត្រង់ ១ ។

ម្យ៉ាងទៀត យើងឱ្យម្រឹគជាកូនប្រុសនោះរៀនយកហើយ



www.elibraryofcambodia.org

ដោយប្រការដែលម្រឹគជាក្មួយប្រុសនោះ ដកដង្ហើមលើផែនដីដោយរន្ធច្រមុះម្ខាង ធ្វើដោយកល ៦ ប្រការ គឺធ្វើកលដោយហេតុ ៦ ប្រការ ដែលបានសម្ដែងទុកក្នុងន័យទាំងពីរ អធិប្បាយថា នឹងធ្វើកល គឺនឹងបញ្ឆោតនាយព្រាន។ ព្រះពោធិសត្វ ហៅម្រឹគប្អូនស្រីថា **ភោតិ** នាងដ៏ចម្រើន។ ដោយបទថា **ភាគិនេយ្យោ** នេះ ព្រះពោធិសត្វ សំដៅដល់ម្រឹគជាក្មួយប្រុសបញ្ឆោនាយព្រានដោយកល ៦ ប្រការ ដោយប្រការយ៉ាងនេះ ។

ព្រះពោធិសត្វ កាលសម្ដែងសេចក្ដីដែលម្រឹគជាក្មួយប្រុសរៀនមាយារបស់ម្រឹគល្អហើយ ទើបលួងលោមម្រឹគជាប្អូនស្រីឱ្យធូរចិត្ត ដោយប្រការយ៉ាងនេះ កូនម្រឹគនោះជាប់អន្ទាក់ មិនបម្រះឡើយ ដេកសណ្ដូកជើងទាំងបួន ទៅផ្នែកម្ខាងដែលមានផ៉ាសុកច្រើនលើផែនដី យកក្រចកទាំងឡាយនោះកកាយក្នុងទីជិត១ជើងទាំង ៤ ធ្វើដី និងស្មៅឱ្យខ្ចាយឡើង បញ្ចេញឧច្ចារបស្សាវៈឱ្យចេញមក ធ្វើអណ្ដាតលានចេញមក ធ្វើសីសៈឱ្យប្រឡាក់ដោយទឹកមាត់ ធ្វើពោះ និងខ្លួនឱ្យប៉ោងឡើង ដោយអាការទប់ខ្យល់ ធ្វើភ្នែកទាំ



www.elibraryofcambodia.org

ងពីរឱ្យក្រឡាប់ ញុំាងខ្យល់ឱ្យចេញតាមច្រមុះខាងក្រោម បិទខ្យល់ច្រមុះខាងលើ ធ្វើក្បាលឱ្យរឹង សម្ដែងអាការរបស់ម្រឹគដែលស្លាប់ហើយ ឯរុយក្បាលខៀវក៏ទំលើទីនោះ (លើខ្លួន និងក្បាល) ក្អែកទាំងឡាយនាំគ្នាអែបក្នុងទីនោះៗ ចំណែកនាយព្រានមកយកដៃគោះពោះ គិតថា ម្រឹគនេះ ប្រហែលជាប់អន្ទាក់តាំងអំពីព្រលប់ទើបស្អុយ ព្រានលើកឡើងមក ទើបស្រាយខ្សែរដែលចងម្រឹគនោះចេញមក គិតថា ឥឡូវនេះ យើងនឹងកាប់ម្រឹគនេះក្នុងទីនេះឯង យកតែសាច់ទៅ ជាអ្នកមិនសង្ស័យ ទើបយកស្លឹកឈើ និងមែកឈើមកគ្រប ។ ឯកូនម្រឹគក្រោកឡើងដោយជើងទាំងបួនរលាស់កាយសន្ធឹងក ហើយបានរត់ទៅកាន់សម្នាក់មាតាដោយរហ័ស ដូចមេឃភ្លៀង ត្រូវខ្យល់ព្យុះធំផាត់មក ដូច្នោះ ។

ព្រះបរមសាស្ដា ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រាហុលជាអ្នកប្រាថ្នាចំពោះការសិក្សា ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេ សូម្បីក្នុងកាលមុន ក៏ជាអ្នកប្រាថ្នាចំពោះការសិក្សាដូចគ្នា កាលទ្រង់នាំព្រះធម្មទេសនានេះមកបន្តអនុសន្ធិហើយ ទើបទ្រង់ប្រជុំជាតកថា



www.elibraryofcambodia.org

កូនម្រឹគជាក្មួយក្នុងកាលនោះ បានមកជារាហុល ក្នុងកាលឥឡូវនេះ ឯមាតាក្នុងគ្រានោះ បានមកជាឧប្បលវណ្ណា ក្នុងកាលឥឡូវនេះ ម្រឹគអ្នកជាអាំក្នុងគ្រានោះ គឺតថាគតនេះឯង ។

**តិបល្លត្ថជាតកទី ៦ ចប់**

## មាលុតជាតកទី ៧

កាឡេ វា យទិ វា ជុណ្ហេ
យទា វាយតិ មាលុតោ
វាតជានិ ហិ សីតានិ
ឧភោត្ថមបរាជិតាតិ ។

( ឥសីពោធិសត្វពោលថា ) កាលណា ខ្យល់បក់ ទោះខាងរនោចក្តី ខាងខ្នើតក្តី កាលនោះ ត្រជាក់ទាំងឡាយ ក៏កើតអំពីខ្យល់ អ្នកទាំងពីរមិនចាលចាញ់ក្នុងប្រស្នានេះឡើយ ។



www.elibraryofcambodia.org

# អដ្ឋកថា មាលុតជាតក

ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធបព្វជិតអ្នកបួស ២ រូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កាឡេ វា យទិ វា ជុណ្ហេ** ដូច្នេះជាដើម ។

បានឮថា បព្វជិតទាំងពីររូបនោះ នៅក្នុងព្រៃមួយ ក្នុងកោសលជនបទ បព្វជិតមួយរូបឈ្មោះថា កាឡត្ថេរ មួយរូបទៀតឈ្មោះថា ជុណ្ហត្ថេរ នៅថ្ងៃមួយព្រះជុណ្ហៈសួរព្រះកាឡៈថា កាឡៈដ៏ចម្រើន ធម្មតារងា តើកើតមានក្នុងវេលាណា ? ព្រះកាឡនោះពោលថា ការរងាមានខាងក្នុងរនោច ។ ថ្ងៃមួយ ព្រះកាឡៈសួរព្រះជុណ្ហៈថា លោកម្ចាស់ជុណ្ហៈដ៏ចម្រើន ធម្មតាការរងាតើតែងមានក្នុងវេលាណា ? ព្រះជុណ្ហៈនោះពោលថា មាននៅខាងខ្នើតបព្វជិតទាំងពីររូបនោះ ក៏មិនអាចកាត់សេចក្តីសង្ស័យរបស់ខ្លួនបានទើបនាំគ្នាទៅកាន់សម្នាក់របស់ព្រះបរមសាស្តា ថ្វាយបង្គំហើយទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មតាការរងាមានក្នុងកាលណា ព្រះអង្គ ? ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងពីរនោះហើយ ត្រាស់ថាម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុន តថាគតឆ្លើយ



www.elibraryofcambodia.org

បញ្ហានេះដល់អ្នកទាំងពីរហើយ តែអ្នកទាំងឡាយកំណត់មិនបាន ព្រោះនៅក្នុងសង្ខេបនៃភព ហើយទ្រង់ក៏នាំអតីតនិទានមកសម្តែង ដូចតទៅនេះ :

